អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 27-May-2016, 15:10
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦**

**ម៉ោង ០៩:០០នាទី**

**សវនាការលើកទី៤០០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*

លោក ឯម ហ៊ីយ

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ស្រ៊ា រតនៈ

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

លោក ត្រាវីស ហ្វារ*(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក សំ សុគង់

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក សំ សុគង់ | ខ្មែរ |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គូរ៉ូដ៍ | បារាំង |
| លោក ញ៉ែម អេន (2-TCW-919) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ញ៉ៀម អេន** (2-TCW-919)


សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ........................................ ទំព័រ ៥
សួរដោយលោក ឌេល លីសាក់ ផ្តើមពី ........................................ ទំព័រ ២០
សួរដោយលោក សំ សុគង់ ផ្តើមពី ........................................ ទំព័រ ៥៨
សួរដោយលោក ពេជ អង្គ ផ្តើមពី ........................................ ទំព័រ ៦៥
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ........................................ ទំព័រ ៧២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៤៦]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ញ៉ែម អេន បញ្ចប់ ហើយនិងផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-868។ ហើយនៅថ្ងៃនេះផងដែរ ក៏មានសាក្សីបម្រុង 2-TCW-919 ហើយក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នេះរឿងក្ដីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោក ញ៉ែម អេន។ នៅថ្ងៃនេះដែរ មានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-865។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធ ជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយ នៅចំពោះមុខលោកតាដំបងដែក។ សាក្សីមានមេធាវីប្រឹក្សា គឺលោក ម៉ម រិទ្ធា។ សូមអរគុណលោកប្រធាន។

[០៩:០៣:១២]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយបញ្ហាទី១ យើងបានទទួលព័ត៌មានថ្មីៗ ថាលោកមានបញ្ហាសុខភាព លោក ញៀម អេន ដែលត្រូវ អាចនឹងត្រូវទៅបន្ទប់ទឹក ហើយបើសិនបើមានអាការៈដូច្នោះមែន គឺលោកកុំអល់អែកអី លោកលើកដៃទៅ គ្រាន់តែជាសញ្ញា យើងនឹងអនុញ្ញាតឲ្យលោកចាកចេញទៅបន្ទប់ទឹក កុំឲ្យវាមានបញ្ហា ប៉ះពាល់សុខភាពរបស់លោក។ ហើយបញ្ហាមួយទៀត គឺយើងបានទទួលនូវសៀវភៅ និពន្ធដោយសាក្សីរូបនេះ បានផ្ដល់មកខាងអង្គជំនុំជម្រះរួចហើយ ហើយលោក សុន អរុណ មន្ត្រីរដ្ឋបាលតុលាការ សូមចែកចាយជូនទៅភាគី ដែលយើងបានកំណត់ធ្វើការបែងចែករួចអម្បាញ់មិញនេះ ចែកជូនទៅភាគី។ រួមទាំងចៅក្រមនៃអង្គជំនុំជម្រះផង ដើម្បីបានពិនិត្យមើល បានអាន ហើយនិងអាចសម្រេចបញ្ហានេះ ដែលយើងកំពុងបាន កំពុងបង្អង់ក្នុងការសម្រេចលើបញ្ហានេះ។

បាទ ហើយអង្គជំនុំជម្រះជាបន្ទាប់នេះ គឺសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ដង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦។

[០៩:០៥:៣៣]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ បានកំណត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈឈឺខ្នង និងឈឺចង្កេះរ៉ាំរ៉ៃ អង្គុយយូរមិនបាន និងបានផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៦:២៦]

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោល ហើយក៏សូមរំឭកបញ្ជាក់ថា សហមេធាវីទាំងពីរក្រុម គឺនៅពេលវេលាតែមួយវគ្គនៃសវនាការព្រឹកនេះប៉ុណ្ណោះ។ សូមអញ្ជើញ!

តើមានការបែងចែកពេលវេលាយ៉ាងម៉េចដែរទេ បើសិនជាបែងចែកពេលវេលា ហើយត្រូវការប្រើប្រាស់ពេលវេលាចុងក្រោយ យើងនឹងផ្តល់ ព្រោះបើសិនជាស្របគ្នា។ នេះយើងផ្តល់នេះក្នុងន័យថាជាគោលការណ៍គឺខាង ខៀវ សំផន ប្រើមុន ប៉ុន្តែឃើញ ខៀវ សំផន ប្រើពេលវេលាតិចជាង។ ហើយបើសិនជាលោកសម្រេចថាលោកមិនបន្តការតាំងសំណួរបន្តិចបន្តួចទេនោះ គឺលោកអាចប្រើប្រាស់នៅពេលចុងក្រោយជាមួយនឹងក្រុមសហមេធាវីការពារក្តី ខៀវ សំផន ក៏បាន។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនប្រាកដថា តើជាការត្រឹមត្រូវដែរឬទេ ដែលយើងខ្ញុំនៅសល់មួយពេលនោះ ព្រោះកាលពីម្សិលមិញ យើងចាប់ផ្តើមនៅម៉ោងបី ដប់ប្រាំមួយ ហើយយើងមានពេលត្រឹមតែ<៤៤>នាទី គឺថា<មិនមែនជាវគ្គទាំងមូល>ក្រោយពេលឈប់សម្រាក<ទេ> គឺខ្ញុំអត់ទទួលបាននូវមួយវគ្គពេញនោះទេ។ ដូច្នេះខ្ញុំគិតថា<យើងមិនត្រឹមតែមាន>មួយវគ្គ<ដំបូង>នោះទេ <ប៉ុន្តែគឺវគ្គដែលនៅសល់ពីវគ្គទី៤ពីម្សិលមិញនោះផងដែរ>។ ដូច្នេះខ្ញុំចង់ស្នើសុំថា ខ្ញុំពួកខាងយើងទទួលបាន<>វគ្គ<ទី១នេះ> ហើយ<>បន្ថែម៣០នាទី<>ទៀតក្រោយពេលឈប់សម្រាក<ទី១>នោះ។

[០៩:០៨:២៨]

**ប្រធានអង្គជំនុំ៖**

ឥឡូវយើងផ្តល់នេះក្នុងន័យឲ្យពិភាក្សាគ្នាផង ហើយនិងលៃពេលដើម្បីឲ្យមួយក្រុមមេធាវីការពារក្តី ខៀវ សំផន គាត់អាចឡើងសួរដេញដោលបាន ព្រោះសាក្សី ហើយជាគោលការណ៍ដែលយើងអនុវត្តកន្លងមក ទាំងតាមសំណើសុំរបស់គាត់ គឺសុំសួរចុងក្រោយ។ ឥឡូវនេះពេលវេលាហ្នឹង គឺអាច យើងអាចនឹងពិនិត្យលើបញ្ហានេះបាន ប៉ុន្តែវាមិនហួសហេតុពេក ដូចថាវាច្រើនពេកនោះទេ ប៉ុន្តែ

សួរថាតើយើងដោះស្រាយបញ្ហានោះដូចម្តេច ពីព្រោះបញ្ហាគឺគាត់ទាមទារសុំសួរដេញដោលក្រោយគេ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមជម្រាបសួរលោកប្រធាន។ យើងចង់សួរទៅសាក្សី ហើយបើតាមការគណនាទៅ មេធាវីការពារក្តីមិនទាន់បានប្រើមួយវគ្គអស់កាលពីម្សិលមិញនៅឡើយទេ។ បើពិនិត្យមើលតាមប្រតិចារឹកកាលពីម្សិលមិញហ្នឹង គឺគាត់ចាប់ផ្តើមសួរនៅម៉ោងបី ដប់ប្រាំនាទី អ៊ីចឹងគាត់នៅសល់ប៉ុន្មាននាទីបន្ថែមទៀត ដើម្បីឲ្យគ្រប់មួយវគ្គសម្រាប់គាត់។ នេះជាអ្វីដែលខ្ញុំអាចជម្រាបជូនបាន ហើយយើង ៗក៏មានបំណងចង់សួរសាក្សីហ្នឹងនៅចុងក្រោយគេបង្អស់ ដូចសព្វមួយដងអ៊ីចឹងលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លើកលែងតែខ្ញុំភ័ន្តច្រឡំ សាក្សីនេះត្រូវបានគ្រោងស្តាប់ចម្លើយសម្រាប់រយៈពេលមួយថ្ងៃ។ អ៊ីចឹងមេធាវីការពារក្តីមានរយៈពេលពីរវគ្គទាំងពីរក្រុម។ <អ្វីដែល>ខ្ញុំមិនយល់<គឺ>តើបែងចែក<ពេលវេលា>គ្នាយ៉ាងម៉េចចំពោះក្រុមទាំងពីរនេះ? ពីរក្រុមហ្នឹងចែកគ្នាយ៉ាងម៉េច ហើយពេលណាមេធាវី កូប៉េ សួរចប់ ហើយពេលណាដែលមេធាវីការពារក្តីលោក ខៀវ សំផន ចង់ចាប់ផ្តើមសួរ?

[០៩:១០:៣០]

**កញ្ញា អង់តា ហ្គីសសេ៖**

តាមរយៈការគណនារបស់យើង លោកចៅក្រម ឡាវែន៍ គឺខាងយើង គឺមានពេលប្រហែលជា ៤០ទៅ៤៥នាទី។ អ៊ីចឹងមេធាវី កូប៉េ គាត់អាចប្រើពេលដែលនៅសេសសល់បាន។ <ប៉ុន្តែក្រៅពីបញ្ហានៃការបែងចែកពេលវេលាគ្នានេះ> ខ្ញុំបាននិយាយអម្បាញ់មិញនេះ និយាយអំពីកាលពីម្សិលមិញនោះ <>មេធាវី កូប៉េ មិនទាន់បានសួរមួយវគ្គពេញទេ ដោយសារតែគាត់ចាប់ផ្តើមនៅម៉ោងបី ដប់ប្រាំនាទីទៅហើយ មិនមែនម៉ោងបីគត់ទេ គឺម៉ោងបី ដប់ប្រាំនាទី។ អ៊ីចឹងគាត់នៅសល់ពេលខ្លះទៀត។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំគិតថា យើងផ្តល់ជូនពីរវគ្គ អ៊ីចឹងអ្នកទាំងពីរ ពីរក្រុមហ្នឹងរៀបចំខ្លួនឯងទៅ សួរយ៉ាងម៉េចសួរទៅឲ្យតែគ្រប់ពីរវគ្គ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក វ៉ិចទ័រ កូប៉េ៖**

យើងបានចំណាយពេលវេលាដ៏មានតម្លៃ១០នាទីអស់បាត់ទៀតទៅហើយ។ ឥឡូវនេះខ្ញុំសូមចាប់ផ្តើមតែម្តង។

[០៩:១១:២២]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំនឹងរំលងនូវប្រធានបទពីរបីចោលសិន ហើយខ្ញុំបន្តប្រធានបទសំខាន់។ កាលពីម្សិលមិញលោកបានថា លោកមកស-២១ គឺមានការច្រឡំបន្តិចថា តើលោកមកនៅពេលណា? ដូច្នេះខ្ញុំនឹងសួរដេញដោលលោក ដោយផ្អែកទៅលើអ្វីដែលប្រធានកងថតរូប គឹម ស្រេង បាននិយាយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ គឺ E3/7618 អង់គ្លេសមានលេខ 00164441, ខ្មែរមានលេខ 00164438 និងបារាំងមានលេខ 00164441 *(ស៊ីក)*។ គាត់បាននិយាយដូចតទៅនេះ៖ "<ក្រុម>អ្នកថតរូប<នៅពេលក្រោយមកបានទទួលមនុស្ស៤នាក់បន្ថែមទៀត ក្នុងនោះរួមមាន ញ៉ែម អេន>។ ញ៉ែម អេន បានមកធ្វើការជាមួយខ្ញុំនៅពាក់កណ្តាលឆ្នាំ៧៨ ប្រហែលជា៦ខែមុនពេល<ភ្នំពេញ>ដួលរលំ។ មុននេះ ញ៉ែម អេន នៅក្នុងកងកុមារ រស់នៅជាមួយ ឌុច។"

សាក្សីមួយរូបទៀត គឺមនុស្សម្នាក់ទៀតដែលធ្វើការនៅស-២១ ដែលមានឈ្មោះថា សួស ធី គាត់និយាយថា មិនដែលឮ<ឈ្មោះ>លោកទេ។ ហើយ ឌុច នៅក្នុងសក្ខីកម្មរបស់គាត់ចំពោះមុខអង្គអង្គជំនុំជម្រះសាលាដំបូង គឺឯកសារ E3/7468 <ផ្តល់សក្ខីកម្មនៅថ្ងៃទី៤ ខែសីហា> បាននិយាយថា លោកគឺជាកូនរបស់កម្មាភិបាល ស-២១ ប៉ុន្តែគេមិនដែលឲ្យលោកទៅថតរូបខាងក្រៅស-២១ នោះទេ។

ដូច្នេះវាហាក់ដូចមានការច្របូកច្របល់ <មកពីសមាជិក>កម្មាភិបាលនៅស-២១ ទាក់ទងថា តើលោកធ្វើអ្វី ហើយនិងតើលោកមកដល់នៅពេលណា។ ដូច្នេះតើលោកអាចបញ្ជាក់បំភ្លឺឲ្យបានច្បាស់បន្តិចទេ ទៅលើចំណុចទាំងអស់នេះ?

[០៩:១៣:៣៤]

**លោក ញ៉ែម អេន៖**

**ឆ៖** បាទ លោកមេធាវី បាទ សូមគោរពលោកប្រធាន។ ទាក់ទងនឹងបញ្ហានេះ ខ្ញុំនិយាយឲ្យឮបន្តិចទាក់ទឹងនឹង មិត្តស្រ៊ាង ខ្ញុំបាទមកធ្វើការនៅក្នុងគុកទួលស្លែងនេះ នៅចុងខែ៧ ខែ៧ ឆ្នាំ១៩៧៦។

01247152



ហើយដូចជាករណីលោក ស្ងួស ធី បាទលោក ស្ងួស ធី នេះ ខ្ញុំស្គាល់ច្បាស់ណាស់ បានថាខ្ញុំស្គាល់ច្បាស់ ម៉េច លោក ស្ងួស ធី បើនិយាយសព្វថ្ងៃគាត់ប្រៀបធៀបទៅនឹងរដ្ឋបាល។ គាត់អ្នកកាន់បញ្ជីអ្នកទោសចូល អ្នកទោសចេញ អ្នកសម្លាប់ប៉ុន្មានអីប៉ុន្មានលើគាត់ទាំងអស់។ អ៊ីចឹងគឺខ្ញុំដឹងច្បាស់តែម្ដង។ អ៊ីចឹងការថតរូប ការថតរូបរបស់ខ្ញុំនៅតាមភូមិភាគទាំងប្រាំ ទាំងប្រាំមួយ តំបន់ស្វយ័តពីរ គឺខ្ញុំបាទបានធ្វើដំណើរ។ ជួនកាលពេលវេលាខ្លះ ខាងអង្គការគាត់អញ្ជើញខាងគាត់ ខាងពេលខ្លះគាត់អញ្ជើញខ្ញុំ។ អ៊ីចឹងថាអាហ្នឹងប្រធានបទចាកប្រធានម៉េច ខ្ញុំអត់យល់ដែរលោកមេធាវី។ ប៉ុន្តែអ្វីដែលជាសក្ខីកម្មមួយសម្រាប់បង្ហាញដល់ខ្មែរក្រហមនេះ គឺខ្ញុំ ញ៉ែម អេន ច្បាស់ណាស់ស-២១ ទាំង ស្ងួស ធី, ទាំងតាម៉េង, ទាំងតាហ៊ុយ អ្នកណាដែលធ្វើចលនានៅគុកទួលស្លែងនេះ ខ្ញុំស្គាល់ច្បាស់ណាស់។ ប៉ុន្តែដូចជា តាឌុច អ៊ីចឹងគាត់បដិសេធថា អត់ដែលស្គាល់ខ្ញុំ។ អាហ្នឹងជាសិទ្ធិ ជាកាតព្វកិច្ច ជាសិទ្ធិរបស់គាត់ អាហ្នឹងខ្ញុំអត់មានទៅបដិសេធទេ ជាសិទ្ធិរបស់គាត់ ព្រោះនៅក្នុងប្រទេសកម្ពុជាសម័យនោះ មិនមែនតែគាត់ធ្វើការតែឯងអីណា។ បាទ ដូចខ្ញុំវ័យ១៨ឆ្នាំ ១៩ឆ្នាំនេះ ខ្ញុំដឹងបាទ។ អ៊ីចឹងថា អានេះជាសិទ្ធិរបស់គាត់ គាត់បដិសេធ មិនបដិសេធ។ បើ ស្ងួស ធី វិញ គឺគាត់ច្បាស់ណាស់។ បាទ គាត់កាន់បញ្ជីអ្នកទោសសម្លាប់ប៉ុន្មាន នៅប៉ុន្មាន គឺលើគាត់ទាំងអស់ បាទ ដែលទាក់ទងកិច្ចការរដ្ឋបាល ទាក់ទងនឹងរបបខ្មែរក្រហមនៃកម្ពុជាប្រជាធិបតេយ្យ។ បាទ លោកមេធាវី។

[០៩:១៥:១១]

**ស៖** ដូច្នេះនិយាយដោយសង្ខេបទៅ គឺបានន័យថា សាក្សីដទៃទៀតដែលបានលើកឡើង គឺហាក់ដូចជាបង្ហាញថា លោកមានតួនាទីតិចតួចបំផុតនៅក្នុងកងថតរូប <គឺមិនត្រឹមត្រូវទេ>។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ លោកមេធាវី វាទាក់ទងនឹងការងារហ្នឹង ក្រុមជាងថត វាមានអ្នក១៦នាក់។ អ៊ីចឹងភារកិច្ច កាតព្វកិច្ចរបស់អង្គការចាត់តាំង គឺមានពេល មានពេលគេ។ សូម្បីតែថតរូបគុកទួលស្លែង គឺមានការចាត់តាំងខុសគ្នា ជួនកាលថតពេលយប់ ជួនកាលពេលថ្ងៃ ជួនកាលថតរួមមួយគ្នាក៏បាន ជួនកាលអ្នកទោសនៅឆ្នាំ១៩៧៧ អ្នកទោសចូលសម្បើម គឺឆ្នាំហ្នឹងដែលចូលច្រើនជាងគេ។ អ៊ីចឹងថា រឿងគាត់ថាយ៉ាងណាៗ គឺភារកិច្ចខ្ញុំមានពីរផ្នែក។ ទី១ រឿងថតរូប។ ទី២ទៀត គូសផែនទី។ បាទ ផែនទីសម័យនោះ គឺខ្ញុំគូរចាប់តាំងពីមុំបី ចាប់តាំងពីចុងភូមិភាគពាយ័ព្យ មកដល់ភូមិភាគនិរតី នៅតែនិញ, នៅសៃហ្កន នៅឡុកយីង នៅអានយ៉ាង គឺខ្ញុំគូសផែនទីទៀត។ អ៊ីចឹងបានថា ភារកិច្ចចម្បង គឺវាច្រើនបាទ។

**ស៖** សូមអរគុណ។ ដោយសារខ្ញុំមានពេលវេលាកំណត់ ដូច្នេះខ្ញុំសូមឲ្យលោកជួយផ្ដល់ចម្លើយដោយខ្លីៗបានហើយ។ មុននឹងបន្តទៅនីតិវិធីនៃការថតរូបរបស់អ្នកទោស ដែលទើបនឹងចូលមកដល់ថ្មីនោះ ខ្ញុំចង់សួរលោកបន្តិច អំពីព្រៃស។ នៅក្នុងចម្លើយរបស់លោក នៅក្នុងកិច្ចសម្ភាសន៍របស់លោកផងដែរ ជាមួយអ្នកសារព័ត៌មានលោកបាននិយាយថា លោកធ្លាប់ទៅព្រៃស ហើយលោកធ្លាប់ថតរូបនៅទីតាំងព្រៃស។ តើអ៊ីចឹងមែនទេ?

[០៩:១៧:០១]

**ឆ៖** បាទ សូមគោរពលោកប្រធាន ជាការត្រឹមត្រូវ លោកមេធាវី។ ភារកិច្ចកាលនោះ គឺទៅថតនៅព្រៃស បើនិយាយឲ្យចំទៅ គឺទៅថតធ្វើប្រវត្តិរូប។ ដូច្នេះកាតព្វកិច្ចអ្នកនៅព្រៃសនេះ គឺជាមនុស្សប្រភេទទី២។ ទី១ គឺអ្នកត្រូវដាក់នៅទួលស្លែង ទី២ទៀត--

**ប្រធានអង្គជំនុំ៖**

បានៗ ញ៉ែម អែនៗ! លោកស្ដាប់សំណួរឲ្យបាន ហើយឆ្លើយតបនឹងសំណួរដោយខ្លីៗទៅបានហើយ។ គ្រាន់តែថាធ្លាប់ដែលទៅថតរូបនៅព្រៃសដែរឬទេកាលនោះ? ថាធ្លាប់ គឺជាចម្លើយតបចប់ហើយ។ បាទ ហើយមានសំណួរអីផ្សេងទៀត នឹងសួរថាទៅធ្វើការអីទៀត អាហ្នឹងគេនឹងសួរអ៊ីចឹង ទី១ ប្រតិចារឹកផង ទី២ វាតម្រូវការ និងភាពចាំបាច់នៃការគិតរបស់ខាងបច្ចេកទេស និងនៃយុទ្ធសាស្ត្រ ឬក៏វិធីសាស្ត្រក្នុងការសួរដេញដោលតាមផ្លូវតុលាការរបស់ភាគី លោកយល់ដែរទេ?

**លោក ញ៉ែម អែន៖**

**ឆ៖** បាទ ជាការត្រឹមត្រូវលោកមេធាវី រឿងពិតខ្ញុំបាទទៅថតនៅសព្រៃ នៅព្រៃសមែន ជិះកង់ទៅថត ជារៀងរាល់អាទិត្យ ក្នុងមួយអាទិត្យទៅថតម្ដង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អ្នកទោសដែលគេបញ្ជូនទៅព្រៃស តើពួកគាត់នោះត្រូវបានគេថតរូបនៅភ្នំពេញ ឬក៏គេយកគាត់ទៅថតរូបនៅព្រៃសតែម្ដង?

[០៩:១៨:៣៥]

**ឆ៖** បាទលោកមេធាវី រឿងនៅថតនៅព្រៃសនេះ គាត់មិនមែនជាអ្នកទោសទេ ក៏ប៉ុន្តែគាត់ជាប់ហៅថា ពួកគេថា ប្រតិសម្ព័ន្ធៗ បានន័យថា ពីឈ្មោន់ទី២ទេ។ បើសិនណាជាពួកហ្នឹងយកទៅព្រៃស អត់តែ គេចាប់មកទួលស្លែងវិញសម្លាប់ចោលបាទ។ អាហ្នឹងអត់មានជាគុកទេបាទ គឺជាកន្លែងធ្វើស្រែ។

**សៈ** ខ្ញុំសូមអានទូវសម្រង់របស់ <នឹម> គឹម<ស្រ៊ាង> ហើយខ្ញុំនឹងឲ្យលោកឆ្លើយតប តើលោកយល់ស្របជាមួយគាត់ឬក៏អត់។ នៅក្នុងឯកសារ E3/7639 ខ្មែរERN 00162713, អង់គ្លេសមានលេខ<00162736> និងបារាំង 00338079។ ស្រ៊ាង បាននិយាយដូចតទៅនេះ៖ "ភាគច្រើននៃអ្នកទោសដែលត្រូវបានថតរូបនោះ ត្រូវបានគេបញ្ជូនទៅ<ធ្វើ>ស្រែនៅព្រៃស ក្រៅពីនេះខ្ញុំអត់ដឹងទេ។ អ្នកទោសដែលត្រូវបានគេបញ្ជូនទៅ<ធ្វើ>ស្រែ ភាគច្រើនៗតែជាក្មេងៗ។ ខ្ញុំជាអ្នកថតរូបពួកគេដែរ ហើយខ្ញុំឃើញថាពួកគេទៅដាំស្រូវ ធ្វើស្រែ។ <មូលហេតុដែលខ្ញុំដឹង ព្រោះ>ខ្ញុំ<បានធ្វើឲ្យខូច>ថតរូប<មួយចំនួន ហើយត្រូវ>យកឈ្មោះរបស់ពួកគេ<ចេញ> ហើយបន្ទាប់មកទៀត គឺយកទៅថតរូបនៅព្រៃសតែម្តង។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះខ្ញុំចង់សួរថាតើលោកយល់ស្របជាមួយចម្លើយរបស់ នឹម គឹម<ស្រ៊ាង> ដែរឬទេ?

**ឆះ** បាទ នេះគឺជាការត្រឹមត្រូវមួយចំនួនដែរ។ ក៏ប៉ុន្តែលោកមេធាវី ទាក់ទងនៅលោក -- ប៉ុន្តែខ្ញុំហៅកាលនោះ ហៅ គឹមស្រ៊ាង ទេ មិនមែន គឹមស្រេង ទេ, គឹមស្រ៊ាង ឈ្មោះ ស្រ៊ាង ទេគាត់បាទ។ ប៉ុន្តែបញ្ហាទាំងអស់នេះដែលខ្ញុំពិនិត្យមើលទៅវាជាការពិត ប៉ុន្តែនៅនោះគឺមានអង្គភាពមួយ គឺឈ្មោះ តាហ៊ុយ។ ហ៊ុយ ដូចគ្នា មួយហ៊ុយៗសន្តិសុខ មួយហ៊ុយធ្វើស្រែ ហ្នឹងគេហៅហ៊ុយធ្វើស្រែ ប៉ុន្តែ ហ៊ុយនោះក៏គេសម្លាប់ចោលដែរ។ ប៉ុន្តែការថតរូបនោះ គឺជួនកាលអ្នកទោសទាំងអស់ភាគច្រើន គឺយកមកតាមរោងចក្រ កម្មករ អត់មានអ្នកទោសទេ ដូចថាអ្នកជាប់ឧបាយកលខ្លាំងអីអ៊ីចឹង ធ្វើការបាក់បែកសម្ភារៈនៅរោងចក្រអ៊ីចឹងណ៎ា ប៉ុន្តែជាការពិត បាទអាហ្នឹងជាការពិត។ ប៉ុន្តែអ្នកថតទាំងអស់គឺភាគច្រើនថតនៅឯណោះទេ តិចណាស់ដែលបញ្ជូនទៅទួលស្លែង ជាកុមារតូចៗវាតិច។

[០៩:២១:២៣]

**សៈ** តើលោកដឹងទេថា មានប៉ុន្មាននាក់ដែលគេថតនៅភ្នំពេញ? ហើយប៉ុន្មាននាក់ដែលគេមិនបានថតនៅភ្នំពេញ?

**ឆះ** បាទ លោកមេធាវី អានេះបើខ្ញុំនិយាយការពិតនៅសវនាការអន្តរជាតិថ្ងៃនេះ វាជារឿងពិត។ ការថត ជួនកាលអ្នកទោសដែលដឹកមកទួលស្លែង យើងសម័យនោះគឺមានដល់ទៅប្រាំមួយ ប្រាំពីរភូមិភាគ ដូច្នេះភាគច្រើនអត់បានថតទេ បាទថតបានតិចណាស់ គឺយកដឹក យកទៅវៃចោលតែម្តង បាទអាហ្នឹងខ្ញុំនិយាយឲ្យអស់ ប៉ុន្តែការវៃចោលៗនៅឯណាមិនដឹង ប៉ុន្តែដឹកច្រើនណាស់ ដូចជាភូមិបស្ចិមភូមិភាគពាយ័ព្យ និរតី បូព៌ា ព្ញសានអ៊ីចឹងមក ឧត្តរមក។ ដល់អ៊ីចឹងទៅ អ្នកទោសចូលមកច្រើន ក៏ប៉ុន្តែ

ភាគតិចដែលបានថតបាទ បើតាមថតនោះប្រហែលជាដប់ម្ភៃម៉ឺន ទៅមើល។ អានេះជាការពិត ខ្ញុំអត់ព្រោះខ្ញុំបានឡើងស្បថមុខតុលាការហើយ គឺខ្ញុំអត់និយាយកុហកទេ បាទជាការពិត។

**ស៖** ខ្ញុំសូមអាននូវសម្រង់មួយទៀត គឺជាសម្រង់ទី២របស់ គឹមស្រ៊ាង អំពីស្ថានភាព<>អ្នកដែល<>គេបញ្ជូនទៅព្រៃស <ថាតើពួកគេបាន>ថតរូប ឬក៏មិនថតរូបនោះ។ គាត់បាននិយាយថា គឺ E3/7639 ខ្មែរមានលេខ 00162710, អង់គ្លេសមានលេខ 00162733 ដល់34 និងបារាំងមានលេខ 00338076។ គាត់បាននិយាយដូចតទៅនេះ គឺថាគាត់បានរៀបរាប់អំពីហេតុការណ៍មួយ គាត់ថា៖ “ថ្ងៃមួយនៅពេលដែលខ្ញុំកំពុងតែផ្ដិតហ្វីលរូបថត គឺថា<>រូបថត<បាន>ខូច។ នៅពេលដែលខ្ញុំស្នើសុំថតរូបឡើងវិញនោះ ខ្ញុំឃើញតែមនុស្សពីរនាក់ទេនៅសល់ ហើយខ្ញុំសួរ ឌុច ថា បង តើអ្នកទោសដែលគេយកមកពីម្សិលមិញហ្នឹង តើគេយកទៅណាអស់ហើយ? គាត់បានឆ្លើយថា ពួកគេបានបញ្ជូនទៅវាលស្រែអស់ហើយ <>ទៅថតរូប<ពួកគេ>នៅវាលស្រែ<ទៅ>។” សូមបញ្ចប់ការដកស្រង់។ វាហាក់ដូចជាការបញ្ជាក់មួយថា អ្នកទោសត្រូវបានគេយកមក<កន្លែងទទួល ហើយត្រូវបានគេ>ថតរូប ហើយបន្ទាប់មកទៀតត្រូវបានបញ្ជូនទៅព្រៃស។ តើអ៊ីចឹងមែនទេ?

[០៩:២៣:៥១]

**ឆ៖** បាទ លោកមេធាវី អានេះវាជារឿងពិត ព្រោះអ្នកទោសដែលបានថតនៅគុកទួលស្លែងនេះពេលណាថតហើយ ជួនកាលអ្នកទោសអត់សំខាន់។ ដល់ពេលថតហើយ គេយកទៅវៃចោលបណ្ដោយអត់មានយកទៅព្រៃសទេ យកទៅវៃចោលតែម្ដង ដឹងៗវៃចោលឯណា ប៉ុន្តែកន្លងមកវៃចោលនៅជុំវិញទួលស្លែងវាៗអស់កន្លែងកប់។ ដល់អ៊ីចឹងទៅ ឲ្យតែថតហើយ គឺ៩៩កន្លះភាគរយគឺ ១០០ភាគរយគឺស្លាប់ហើយ ឲ្យតែថតហើយ។ អ៊ីចឹងថាការថតរូបខូចមិនខូច ជួនកាលអាចថតខូច ប៉ុន្តែកម្រណាស់បាទរូបថត ៩៩កន្លះភាគរយកម្រខូចណាស់ ប្រយ័ត្នមែនទែនសម័យនោះ។ បាទ ជាការពិត ខ្ញុំឃើញជាក់ស្ដែងអ៊ីចឹងមែនបាទ។

**ស៖** ខ្ញុំនឹងនិយាយអំពីប្រធានបទដែលលោកជាអ្នកថតរូប ដូចដែលលោកបានបញ្ជាក់ពីម្សិល-មិញ<និងថ្ងៃនេះ> គឺថាខ្ញុំទើបតែបានពិនិត្យមើលសៀវភៅរបស់លោកមួយភ្លែតអម្បាញ់មិញនេះ ហើយខ្ញុំបានអានទៅដល់ទំព័រមួយដែលលោករៀបរាប់អំពីដំណើរការ<ពេញលេញ>នៃការថតរូប គឺលោកបាននិយាយយោងអំពីបន្ទប់<>ងងឹតមួយ <ព្រោះថា ជាការពិតណាស់ ក្នុងអំឡុងឆ្នាំទាំងនោះ មិនមានការថតរូបជាឌីជីថលនោះទេ។> រូបថតទាំងអស់ដែលត្រូវបានថតនោះ ត្រូវផ្ដិតនៅក្នុងបន្ទប់ងងឹត

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពិសេសមួយនោះ ហើយប្រើប្រាស់<សាធាតុគីមី>ពិសេសមួយទៀត។ <តើនោះជាករណី?>

[០៩:២៥:៤៣]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<>សូមចាំមួយភ្លែតសិនលោកមេធាវី ព្រោះថាដោយសារតែលោកប្រើប្រាស់សៀវភៅ<នោះ> ដូច្នេះយើងចាំបាច់ត្រូវធ្វើសេចក្តីសម្រេច<ទទួលយក>សិន។ ខ្ញុំបានអានសៀវភៅនេះមួយភ្លែត ហើយជាបឋមខ្ញុំគិតថា សៀវភៅនេះមានភាពពាក់ព័ន្ធ។ ដូច្នេះតើភាគីទាំងនាមានមតិយោបល់អ្វីទាក់ទងនឹងការទទួលយកឯកសារ<នេះទេ>?

**លោក ឌេល លីសាក់៖**

បាទ លោកស្រីចៅក្រម ហ្វេនស៍ យើងខ្ញុំខាងព្រះរាជអាជ្ញាមិនមានការជំទាស់នោះទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ចុះសហមេធាវីនាំមុខ យ៉ាងម៉េចដែរ?

**លោកស្រី ម៉ារីហ្គីរ៉ូដ៍៖**

យើងមិនទាន់បានពិនិត្យមើលសៀវភៅនេះនៅឡើយទេ លោកស្រីចៅក្រម។

**កញ្ញា អង់តា ហ្គីសសេ៖**

យើងពិនិត្យមើលទៅដូចជាចម្លើយពីមុនរបស់សាក្សីអ៊ីចឹង។ អ៊ីចឹងយើងអត់មានជំទាស់អីទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៧:១៦]

**ប្រធានអង្គជំនុំ៖**

បាទ ដោយសារភាពចាំបាច់នៃការពិភាក្សាដេញដោល ហើយមានភាពបន្ទាន់ ដោយសារការប្រើពេលវេលាដែលភាគីស្នើសុំ ដល់ពេលត្រូវសួរដេញដល់ចំពោះសាក្សីរូបនេះ ដោយផ្អែកលើមូលដ្ឋាននៃឯកសារភ័ស្តុតាងដែលខ្លួនបានស្នើសុំ ហើយដោយសារឯកសារនេះបន្ទាប់ពីមើលបឋមពីភាគីពាក់ព័ន្ធឃើញថាមិនមានភាគីណាជំទាស់ទេ។ ដូច្នេះ អង្គជំនុំជម្រះសម្រេចទទួលឯកសារសៀវភៅនិពន្ធឡើងដោយ ញ៉ែម អេន ដែលជាសាក្សីរូបនេះ ជាឯកសារភ័ស្តុតាងដាក់បញ្ចូលទៅក្នុងសំណុំរឿងតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ ឯសំអាងហេតុ អង្គជំនុំជម្រះនឹងចេញនៅពេលក្រោយ។ អ៊ីចឹងលោកមេធាវីនិងភាគី – មេធាវី វ៉ិចទ័រ កូប៉េ និងភាគីដទៃទៀតអាចប្រើប្រាស់ឯកសារនេះក្នុងការតាំងសំណួរដេញ

ដោលចំពោះសាក្សី ញ៉ែម អេន បានហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអរគុណលោកប្រធាន។ ខ្ញុំបានរៀបរាប់ឱ្យលោកស្តាប់អំពីការលាងផ្តិតរូបថតនៅក្នុងពេលនោះ។ លោកបានរៀនវគ្គផ្តិតរូបថតផងដែរ លោកបានពន្យល់រួចមកហើយ។ ដូច្នេះខ្ញុំចង់សួរថា តើហ្វីលរូបថតដែលលោកយកចេញពីក្នុងកាមេរ៉ាមកហ្នឹង រួមទាំងគ្រឿងលាងនៅក្នុងបន្ទប់ងងឹតហ្នឹង តើកន្លែងលាងហ្វីលនៅក្នុងបន្ទប់ងងឹតហ្នឹងនៅកន្លែងណាដែរ?

[០៩:២៨:៥៧]

**លោក ញ៉ែម អេន៖**

**ឆ៖** បាទ សូមគោរពលោកប្រធាន លោកមេធាវី។ ផ្ទះខ្ញុំសព្វថ្ងៃ ខ្ញុំចាំច្បាស់ណាស់អត់មានភ្លេចបានទេបាទ។ នៅៗទៅពីទួលស្លែងទៅប្រហែលជា២០០ម៉ែត្រ។ ខ្ញុំទៅសួរអ្នកនៅផ្ទះរាល់ថ្ងៃនេះ ថាលោកស្រីកាលចូលផ្ទះដំបូងមានឃើញអីទេ? ផ្ទះហ្នឹងគេថា ហ្វីលត្រឹមជង្គង់។ ថាយកទៅណាអស់ហើយ? ថា ដុតចោលអស់ហើយ។ អ៊ីចឹងថា ទាក់ទងនឹងការលាងបន្ទប់ងងឹតនេះ ខ្ញុំមានភ័ស្តុតាងទាំងអស់ ទាំងកន្លែងខ្ញុំធ្វើការ ទាំងកន្លែងខ្ញុំរក្សាទុក។ កាលហ្នឹងម៉ាស៊ីនថតប្រហែលជាប់ជា៥០០គ្រឿង ទាំងម៉ាស៊ីនថតកុន១៨មិល្លីម៉ែត្រ ១៦មិល្លីម៉ែត្រ ៣៥មិល្លីម៉ែត្រ និងម៉ាស៊ីនថតទាក់ទង សូមលោក ចៅក្រមសុំម៉ាស៊ីនថតតិចបាននៅ រូបថតម៉ាស៊ីនថតនោះ។ អ៊ីចឹងថា នៅៗអូន នៅៗលោករដ្ឋបាល សុំបង្ហាញម៉ាស៊ីនថត ដែលខ្ញុំម៉ាស៊ីនថតខ្ញុំថតសម័យនោះបន្តិច។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ បាទ សូមអញ្ជើញ!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ក្នុងពេលដែលលោកពិនិត្យមើលទៅលើឯកសាររបស់លោក ខ្ញុំសូមបន្តបន្តិច។ លោកបានរៀបរាប់<ពីផ្ទះមួយចម្ងាយ២០០ម៉ែត្រពី>ទួលស្លែង។ ថាតើផ្ទះហ្នឹងនៅផ្លូវលេខប៉ុន្មានដែរ? ហើយចុះផ្ទះហ្នឹងលេខប៉ុន្មានដែរ គឺផ្ទះដែលលោកនិយាយហ្នឹងលេខប៉ុន្មានដែរ នៅផ្លូវលេខអីដែរ?

[០៩:៣០:៤២]

**លោក ញ៉ែម អេន៖**

**ឆ៖** បាទ លោកមេធាវី ចង់ទៅមើលឥឡូវក៏បានដែរ ប៉ុន្តែនៅសវនាការ។ ខ្ញុំឱ្យច្បាស់ ឱ្យស្គាល់

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទាំងផ្ទះខ្ញុំធ្វើការហ្នឹងទៀត ហើយស្គាល់ទាំងកន្លែងខ្ញុំ ទៅពីលូទឹកស្អុយទៅប្រហែលជា៥០ម៉ែត្រទេបាទ។ អីចឹងខ្ញុំជិះកង់តែ២នាទីទេ ពីផ្ទះហ្នឹងមកបាទ។ នេះទាក់ទងនឹងកាមេរ៉ា រ៉ូឡិច, យ៉ាហ្សីកា របស់អាល្លឺម៉ង់ របស់ជប៉ុន។ បាទ នេះទាក់ទងនឹងៗម៉ាស៊ីនថត។ ឥឡូវម៉ាស៊ីនថតសព្វថ្ងៃហ្នឹងនៅខ្ញុំ បាទនៅខ្ញុំ ខ្ញុំរក្សាទុក ខ្ញុំកប់ទុកច្រើនណាស់ ម៉ាស៊ីនថតប្រហែលជា៥០០គ្រឿងអ៊ំ ប៉ុន្តែម៉ាស៊ីនថតមួយចំនួនខ្ញុំបាទបានបញ្ជូនទៅអូស្ត្រាលីអស់ហើយបាទ។ នេះជាការពិត លោកមេធាវី រឿងអីជាសក្ខីកម្មសម្រាប់ខ្មែរក្រហម គឺខ្ញុំមានច្បាស់។ នេះរូបថតខ្ញុំ បាទអំមិញនេះ។ អានេះថតដោយម៉ាស៊ីនយ៉ាហ្សីកា បាទខ្ញុំមាន--

**ប្រធានអង្គជំនុំ៖**

លោកសាក្សី ចាំស្តាប់សំណួរ ហើយលោកឆ្លើយមិនទាន់ចំ វាអត់ត្រូវសំណួរសោះនេះ។ លោកនិយាយច្រើន ប៉ុន្តែអត់ត្រូវសំណួរ។ វាអត់មានហុចៗប្រយោជន៍ឲ្យដល់ការស្វែងរកការពិតទេ។ គេសួរថា តើលោកស្គាល់ទីតាំងកន្លែងថតរូប ផ្តិតរូបហ្នឹងច្បាស់លាស់ទេ លេខ ផ្លូវលេខប៉ុន្មាន ផ្ទះលេខប៉ុន្មាន? តើលោកអាចឆ្លើយបានទេ ផ្ទះលេខប៉ុន្មាន ផ្លូវលេខប៉ុន្មាន? បើលោកដឹង លោកឆ្លើយថាដឹង លេខប៉ុន្មានពីមុនហ្នឹងប៉ុន្មាន ហើយឥឡូវហ្នឹងលេខប៉ុន្មាន បើសិនជាលោកដឹង។ ហើយបើលោកមិនដឹងទេ លោកត្រូវឆ្លើយថា មិនដឹង។ អាហ្នឹងជាចម្លើយរបស់លោក ព្រោះជំនាន់មុនហ្នឹង វាមិនដឹងមានលេខយ៉ាងម៉េចផង ទី១។ ទី២ វាដូរ វិវត្តន៍ សង្គមវិវត្តន៍ខ្លាំងណាស់ ឥឡូវវាយើងមិនអាចជាកំណត់លេខៗសព្វថ្ងៃ មិនដឹងជាលេខពីមុន ឬក៏សព្វថ្ងៃវាមិនៗដូចគ្នាឯណា។ អាហ្នឹងអាជ្ញាធររដ្ឋបាលថ្នាក់ជាតិរាល់ថ្ងៃហ្នឹង ក៏ៗគ្រប់គ្រងអាសយដ្ឋានលំនៅឋានរបស់ពលរដ្ឋមិនបានផង។ លោកធ្វើអ្នកជាអភិបាលរងស្រុក លោកអាចយល់បានហើយពីបញ្ហាស្ថានភាពនោះ។ សូម្បីតែជនបទហ្នឹង ក៏គ្រប់គ្រងអត់បានផងហ្នឹង។ ប៉ុន្តែលោកសូមឆ្លើយតបនឹងសំណួរ ដើម្បីឲ្យត្រូវនឹងសំណួរ។ ស្តាប់សំណួរ ថាគេសួររឿងអី ឲ្យឆ្លើយរឿងហ្នឹង។ និយាយរួម ភាសាតុលាការ គេហៅថា សួរអីឆ្លើយហ្នឹង។ បាទ កាលណាយើងនិយាយទៅវាៗបែកសាចមែនទែន វាអត់ភាពចាំបាច់ ព្រោះគេអត់ចង់ដឹងទេ អាអស់ហ្នឹង ណា៎។ ហើយបើគេខាងភាគីចង់ដឹង គេនឹងសួរបន្តទៅទៀតហើយណា៎។

លោក វ៉ិចទ័រ កូប៉េ តាំង លោកចាំទេ លោកៗចាំសំណួរទេ គេសួរពីអាសយដ្ឋាននោះ ផ្ទះលេខប៉ុន្មាន ផ្លូវលេខប៉ុន្មានណា៎?

[០៩:៣៣:០៥]

**លោក ញ៉ែម អេន៖**

**ឆ៖** បាទ សូមជម្រាបលោកមេធាវី។ ទាក់ទងនឹងកន្លែងខ្ញុំធ្វើការ សព្វថ្ងៃក៏មិនដឹងផ្ទះលេខប៉ុន្មានដែរ ហើយក៏មិនដឹងផ្លូវប៉ុន្មានដែរ ប៉ុន្តែខ្ញុំអត់បានៗមើលលេខ ប៉ុន្តែខ្ញុំដឹងកន្លែងខ្ញុំ។ បាទស្គាល់ច្បាស់តែម្តង។ ខ្ញុំស្គាល់ច្បាស់ មិនអាចកាឡៃបានទេ កន្លែងខ្ញុំផ្តិតរូបថតនោះហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើផ្លូវ៣៦០ ឬក៏ផ្លូវ៣៥០?

**ឆ៖** បាទ សុំទោសលោកមេធាវី វាមិនដឹងផ្លូវលេខប៉ុន្មាន ប៉ុន្តែផ្ទះខ្ញុំស្គាល់ បាទគឺៗខ្ញុំមិនៗភ្លេចទេ បាទខ្ញុំមិនភ្លេច ស្គាល់មកទល់សព្វថ្ងៃហ្នឹង។

**ស៖** នៅក្នុងផ្ទះដែលលោកនិយាយថា លោកហើយនិងអ្នកដទៃទៀតលាងហ្វីលនៅក្នុងបន្ទប់ងងឹតហ្នឹង ថាតើហ្វីលទាំងអស់ហ្នឹង ត្រូវបានគេរក្សាទុកនៅក្នុងផ្ទះនុ៎ងដែរឬទេ? ខ្ញុំមិននិយាយតែហ្វីលដែលលោកថតទេ គឺចង់និយាយថាហ្វីលទាំងអស់ គឺហ្វីលដែលគេថតទាំងអស់នៅស-២១ តើគេទុកហ្វីលទាំងអស់ហ្នឹងនៅក្នុងផ្ទះនុ៎ងតែមួយ ឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** បាទ លោកមេធាវី ទាក់ទងបញ្ហាហ្វីល ជាងថតមានដល់ប្រាំមួយនាក់។ ជាកាតព្វកិច្ចរបស់បុគ្គលម្នាក់ៗ គឺអ្នកណាថត អ្នកណា អ្នកហ្នឹងលាង អ្នកហ្នឹងផ្តិត។ អត់មានពាក់ព័ន្ធទេ គឺរក្សាទុកមួយប្លុកៗ អត់មានពាក់ព័ន្ធអ្នកណាទាំងអស់។ អ៊ីចឹងថាប្រាំមួយនាក់ គឺមានប្រាំមួយបន្ទប់។ ហើយហ្វីលគឺអ្នកណាថត អ្នកហ្នឹងអ្នកទុក។ អត់មានច្របូកច្របល់ទាំងអស់។

**ស៖** អ៊ីចឹងលោកចង់និយាយថា ហ្វីលហ្នឹងគេអត់ទុកនៅក្នុងផ្ទះជាមួយ<គ្នា> ក្នុងកន្លែងតែមួយ<>ជាមួយកន្លែងដែលគេផ្តិតរូបថតទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។

[០៩:៣៥:១៣]

**លោក វ៉ិចទ័រ កូប៉េ៖**

ដើម្បីឲ្យច្បាស់បន្តិច គឺលោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញនូវឯកសារមួយមកពីអាល្លឺម៉ង់ខាងកើត ដែលមានឈ្មោះថា "ឌី អង្គការ" គឺE3/3085R គឺ<>យើងបានបញ្ជូនឯកសារហ្នឹងទៅមន្ត្រីច្បាប់ជាន់ខ្ពស់កាលពីម្សិលមិញរួចហើយ។ គឺជារូបមួយដែលបង្ហាញពីហ្វីល ហើយខ្ញុំចង់បង្ហាញឲ្យសាក្សីមើល ថាតើសាក្សីស្គាល់ថា ហ្វីលរូបថតហ្នឹងគឺជាអ្វី? គឺខ្ញុំមិនចង់សួរអំពីមនុស្សទេ ប៉ុន្តែគ្រាន់ចង់

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឲ្យគាត់មើលទៅលើហ្វីលនោះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការយកឯកសារពីមេធាវីជូនសាក្សីពិនិត្យ។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើហ្វីលនេះ វាដូចគ្នាទៅនឹងហ្វីលដែលលោកប្រើប្រាស់នៅពេលលោកធ្វើការនៅឯស-២១ នោះដែរឬទេ?

**លោក ញ៉ែម អេន៖**

**ឆ៖** បាទ លោកប្រធាន និងលោកមេធាវី ជាការពិត។ អានេះគេហៅថា ហ្វីល១២ប៉ុស្តិ៍។ បាទ សម័យនុ៎ងម៉ាស៊ីនហ្នឹងថតបានតែ១២ប៉ុស្តិ៍ទេ ប៉ុន្តែភាគច្រើនប្រើ៣៥ -- ៦ប៉ុស្តិ៍ទេ ប៉ុន្តែអត់សូវប្រើ ភាគច្រើនប្រើអានេះ វាថតស្អាត។ ជាការត្រឹមត្រូវបាទ ហ្វីលប្រើប្រាប់នៅទួលស្លែងបាទ។

[០៩:៣៧:៣១]

**ស៖** ឥឡូវខ្ញុំសូមពន្លឿនទៅមុខបន្តិចលោកសាក្សី តើត្រឹមត្រូវដែរទេដែលថា លោកហើយនិង ឌុច គឺជាមនុស្សចុងក្រោយហើយ ដែលមានឱកាសរត់ចេញពីគុកស-២១ នៅថ្ងៃ០៧ មករា ៧៩ នៅពេលដែលកងទ័ពវៀតណាមចូលមកដល់។ តើត្រឹមត្រូវដែរទេ?

**ឆ៖** លោកមេធាវី ជាការត្រឹមត្រូវ។ វៀតណាមចូលដល់ភ្នំពេញ កងរំដោះចូលដល់ភ្នំពេញថ្ងៃទី០៧ មករា គឺម៉ោងដប់ពីរដល់ភ្នំពេញនៅថ្ងៃត្រង់។ ហើយម៉ោងបីរសៀល ខ្ញុំបាទចេញពីទួលស្លែងកាត់តាមស្ថានទូតចិន បានធ្លាក់ទៅចំការដូង ទៅដល់បែកចាន ជាការពិត។ នេះតាមផ្លូវយើងមកបែកចាននេះ។

**ស៖** ហើយជាការពិតនោះ ថាតើលោកបានឃើញថា ឌុច នេះបានចាកចេញទៅជាមួយនឹងលោកដែរ រួមទាំងបុគ្គលិក ស-២១ ទៀតនោះ បានៗចាកចេញដំណើររួមគ្នាដែរឬអត់ទេ?

**ឆ៖** បាទ លោកមេធាវីជាការពិត។ ថ្ងៃចេញ ថ្ងៃ០៧ មករា ហ្នឹង គឺខ្ញុំបាទកាត់តាមស្ថានទូតចិនទៅតាមទួលទំពូង ស្ថានទូតចិនមកបានរួមដំណើរជាមួយកងកម្លាំងទាំងអស់ និងសន្តិសុខស-២១។ ក៏ប៉ុន្តែថៃដន្យធ្វើដំណើរមកដល់បែកចានក៏បែកគ្នា បែកពាក់កណ្ដាល។

**ស៖** លោកបានឆ្លើយថា ខ្លួនលោកផ្ទាល់នេះបានចាកចេញ បានរត់ចេញបាតដៃទទេ គ្មានបាន

យកអ្វីទៅជាមួយទេ ត្រឹមត្រូវដែរទេ?

[០៩:៣៩:២០]

**ឆ៖** បាទ លោកមេធាវី បាទមុននឹងចេញពីភ្នំពេញទៅ ខ្ញុំបាទបានលាក់សម្ភារៈបានជាច្រើន ក៏ប៉ុន្តែចេញទៅតែខ្លួនទទេសោះ និងកាំភ្លើងអាកាអ៊ែកែងបត់មួយដើម និងស្លាប៉ាកកាផ្កាទីនមួយ និងនាឡិកាមួយ ខោអាវមួយចង្កេះប៉ុណ្ណឹង ចេញពី ស-២១ ថ្ងៃ០៧ មករា ហ្នឹង។ ទៅជាមួយ តាឌុច ទៅបែកគាត់នៅអមលាំង ត្រពាំងជោរ។

**ស៖** មុននឹងខ្ញុំចូលទៅដល់សំណួរពាក់ព័ន្ធទៅនឹងចំណុចនេះ តើធ្វើយ៉ាងម៉េច <>បានជាលោកមានម៉ាស៊ីនថត<ដែលទើបតែ>បង្ហាញជូនតុលាការ<នេះ>បាន <បើលោកមិនបានយកអ្វីតាមទៅខ្លួនលោកផងនោះ តើនៅពេលក្រោយមកទៀតលោកធ្វើម៉េចដើម្បីអាចយកកាម៉េរ៉ាទាំងនោះមកវិញបាន> ដែលលោក<ថា>បានប្រើប្រាស់នៅ ស-២១<នោះ?>

**ឆ៖** បាទ លោកមេធាវី លោកប្រធាន។ មុនខ្ញុំបាទចេញពីក្រុងភ្នំពេញ ខ្ញុំបានកប់ដីលាក់ បាទកប់ដីលាក់ហ្នឹង គឺខ្ញុំបានលាក់ជាច្រើន ម៉ាស៊ីនបាទ។ ប៉ុន្តែឃើញមួយកន្លែងទេ ពីរកន្លែងទៀត គាស់យកបាត់។ អ៊ីចឹងថាខ្ញុំបានរក្សាទុកជាច្រើន ឯកសារហ្នឹងនៅមកទាល់សព្វថ្ងៃហ្នឹងតែម្តង នៅសល់។ ដូច្នេះដែលខ្ញុំបាទយកទៅតាមខ្លួន តែសៀវភៅមួយក្បាល សៀវភៅដែលខ្ញុំទៅរៀនស្រុកចិនហ្នឹង បានមួយក្បាលគត់ ទៅតាមខ្លួន។ សម្ភារៈមួយចំនួនយកទៅអត់រួច វាធ្ងន់ពេក។

**ស៖** សូមបញ្ជាក់ឲ្យបានច្បាស់បន្តិច លោកមិនបានឃើញ ឌុច និងបុគ្គលិក ស-២១ មានយកឯកសារពីស-២១ រូបថតពីស-២១ ឬក៏ហ្វីលពីស-២១ ទេ លោកមិនបានឃើញអ្នកទាំងនោះ យករបស់ទាំងនេះ ទៅជាមួយទេ ត្រឹមត្រូវដែរទេ?

[០៩:៤១:២០]

**ឆ៖** បាទ លោកមេធាវី ពេលនោះគ្មានអ្នកណាយកអីបានទាំងអស់ មានតែឃើញយកទៅតាមខ្លួនមួយចំនួន មានតែកាំភ្លើងប្រហែលជាដប់ ម្ភៃដើមតែប៉ុណ្ណឹង នៅជុំវិញសន្តិសុខហ្នឹង។ ប៉ុន្តែស្អី គឺអត់ទាំងអស់។ បាទ ទៅតែខ្លួនទទេទាំងអស់គ្នា ដូចតែខ្ញុំដែរ តែខោអាវមួយចង្កេះ ថ្ងៃ០៧ មករា ហ្នឹង។

**ស៖** ឥឡូវនេះខ្ញុំចូលទៅដល់សំណួរសំខាន់ គឺសំណួរដូចតទៅនេះ តើលោកអាចពន្យល់ជូនតុលាការបានឬទេ ថាហេតុអ្វីបានជានៅឆ្នាំ១៩៧៩នោះ ជាពិសេស គិតមកដល់ពេលឥឡូវនេះ គឺថា<> មាន<>តែចំនួន៥.០០០<>ទេ<ដែលគេបានរកឃើញ មានតែរូបថត៥០០០សន្លឹកនៅជាហ្វីលប៉ុណ្ណោះ

ដែលគេបានរកឃើញ>។ ឥឡូវនេះមានច្រើនជាងនោះ។ តើលោក<មានគំនិតយោបល់អីទេ តើ>ត្រឹមត្រូវទេ<ចំពោះអ្វីដែលព្រះរាជអាជ្ញាបានជំទាស់នឹងការសម្រេចរបស់>អង្គជំនុំជម្រះ<សាលាដំបូងដែល>បានសម្រេចថា <>មានអ្នកទោស<> ជាង១២.០០០នាក់ <ទៅ១៥.០០០នាក់ តើ>ហ្វីល<៧.០០០ ទៅ១០.០០០ទៀតនោះ នៅឯណា?>។ អ៊ីចឹងលោកអាចពន្យល់អំពីភាពខុសគ្នានេះបានទេ?

**ឆ៖** បាទ លោកមេធាវី ហ្នឹងវាជាការពិត។ ក៏ប៉ុន្តែចំពោះហ្វីលថត ដែលសម័យដែលថតនៅក្នុងគុកទួលស្លែងហ្នឹង បើខ្ញុំគិតទៅ ជួនកាលរក្សារៀងខ្លួន បាទរក្សារៀងខ្លួន។ ដល់ពេលរូបថតវាឡើងកើនដល់១០.០០០ជាង ក៏ប៉ុន្តែជួនកាល តាឌុច គាត់យកទៅ តាឌុច គាត់សុំ។ អ៊ីចឹងថា ជាការពិតហើយ ជាការត្រឹមត្រូវហើយ ប៉ុន្តែហ្វីលបាត់ច្រើនមែន ប៉ុន្តែចំពោះខ្ញុំដែលរក្សាទុក គឺរក្សាទុកទៅ។ ជួនកាលហ្វីលសំខាន់ៗ ដូចជាគណៈភូមិភាគ គណៈតំបន់ អ្នកដឹកនាំផ្សេងៗ តាឌុច គាត់សុំយកទៅទុក គាត់ខ្លាចបាត់ ខ្លាចខូច។ ដល់អ៊ីចឹងទៅ ខ្ញុំវាពណ៌នាហ្នឹងវាច្រើនណាស់ ពណ៌នាទៅមិនអស់។

[០៩:៤៣:៤៥]

**ស៖** តើត្រឹមត្រូវដែរឬទេ ដែលឥឡូវនេះលោកស្មាន <ដោយ>លោក<ពិតជា>មិនដឹងថាហ្វីលទាំងអស់នេះ នៅទីណានោះទេ នៅពេលនោះ ហើយក៏មិនដឹងថា ពិតជាមានហ្វីលនេះ ឬក៏អត់នោះទេ អ៊ីចឹង ឬក៏យ៉ាងណា?

**ឆ៖** ហ្វីលនេះ ខ្ញុំធានាថាមាន។ ប៉ុន្តែការរក្សាទុកសម័យនោះ ដូចខ្ញុំជម្រាបខាងដើមអ៊ីចឹង សូម្បីតែបន្ទប់ដែលធ្វើការ ពេលដែលថ្ងៃ០៧ មករា ដែលប្រជាពលរដ្ឋគេចូលទៅនៅវិញ គាត់ថា ហ្វីលគរគោក ប៉ុន្តែខ្ញុំសួរគាត់ គាត់ថា យកដុតចោលអស់។ មានភ័ស្តុតាងម្ចាស់ផ្ទះនៅរាល់ថ្ងៃតែម្តង។ ដឹងជាសល់ នៅសល់កន្លែងណា ខ្ញុំមិនដឹងទេ ប៉ុន្តែហ្វីលច្រើនណាស់ មានតែ៥.០០០, ១០.០០០ច្រើន នៅថតតាមភូមិភាគ តំបន់ផ្សេងៗ ច្រើនណាស់ហ្វីល។ បាទ ខ្ញុំពណ៌នាមិនអស់។

**ប្រធានអង្គជំនុំ៖**

អស់ពេលហើយលោកមេធាវី។ ចាំពេលក្រោយ ពេលវេលាដែលអង្គជំនុំជម្រះនឹងផ្តល់ឲ្យទៅមេធាវីនៅពេលចុងក្រោយ វគ្គចុងក្រោយចុះ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន សូមមេត្តាអនុញ្ញាតឲ្យខ្ញុំបញ្ចប់ត្រឹមប្រធានបទនេះសិនចុះ ខ្ញុំសល់តែពីរបីសំណួរទេ សម្រាប់ប្រធានបទនេះ។

[០៩:៤៥:០៣]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកយល់ស្របជាមួយជាមួយចម្លើយរបស់ គឹមស្រ៊ាង ដែលគាត់ឆ្លើយថា "ខ្ញុំបានប៉ាន់ប្រមាណថា អ្នកទោសជាងពីរ<ទៅ>បីពាន់នាក់ទេ ដែលត្រូវបានគេថតរូបនៅស-២១"។ អ៊ីចឹងថាតើលោកយល់ស្របជាមួយនឹង គឹមស្រ៊ាង ទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! ហើយរំឭកថាសាក្សីសុំឆ្លើយយឺតៗ ឆ្លើយចំសំណួរ ហើយយឺតៗបានហើយ ព្រោះមានការបកប្រែណា។ អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឲ្យភាគីបង្ហាញនូវលេខ ERN ផង ពីព្រោះ<តាមការចាំរបស់ខ្ញុំនូវអ្វីដែលសាក្សីនិយាយគឺខុសពីនោះឆ្ងាយណាស់ ដែលគាត់និយាយអំពីចំនួន>រូបថតដែលគាត់ថត<>។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺឯកសារ E3/7639, ERN ជាភាសាអង់គ្លេស 00162740 ហើយ ERN ជាភាសាខ្មែរ និង <ERN>ភាសាបារាំង <និងភាសាខ្មែរ --> បារាំងគឺ 00162740 *(ស៊ីក)*, ខ្មែរ ខ្ញុំនឹងផ្ដល់ជូននៅពេលក្រោយបន្តិចទៀតនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឥឡូវខ្ញុំសួរសំណួររបៀបផ្សេង ដើម្បីចៀសវាងកុំឲ្យមានការជំទាស់។ តើត្រឹមត្រូវដែរទេលោកសាក្សីដែលថា ស្រ៊ាង នេះ ឬក៏ថាអង្គភាពថតរូបថតនេះ ថតបានតែពីពីរ ទៅ បីពាន់នាក់ទេ តើលោកយល់យ៉ាងម៉េចដែរចំពោះចម្លើយរបស់ ស្រ៊ាង នេះ?

[០៩:៤៧:១៧]

**លោក ញ៉ែម អេន៖**

**ឆ៖** បាទ ចង់ជម្រាបលោកប្រធាន លោកមេធាវី ដូចជាអត់ពិតទេបាទ។ បានថាអត់ពិត បើខ្ញុំសរុបតែឆ្នាំ១៩៧៧ អ្នកទោសថតច្រើនណាស់ ច្រើនមែនទែន។ ហើយលេខដូចខ្ញុំប្រាប់លោកប្រធានថាលោកមេធាវីថា លេខដាក់ពីលេខ១រហូត លេខខ្លះដល់មាន៥០០ លេខខ្លះដល់មួយ៦០០។ ដូច្នេះលេខ

ហ្នឹងដាក់ថាក្នុងមួយថ្ងៃ អ្នកទោសចូលប៉ុន្មាន។ អ៊ីចឹងលោក ស្រ៊ាង គាត់ថានេះអត់ពិតទេ អត់ពិតទេច្រើនណាស់។ រូបថតគ្នាប្រាំមួយនាក់ រកពេលសម្រាកញ៉ាំបាយអត់បាន ហូបបានអត់បាន ច្រើន។ ប៉ុន្តែការបាត់បង់ ខ្ញុំមិនដឹងទេ ប៉ុន្តែការថតហ្នឹង វាលើសលប់នឹងការពលកម្ម ដែលធ្វើៗម្នាក់ៗធ្វើស្ទើរតែ២៤ម៉ោង។ ឆ្នាំ១៩៧៧នេះ អ្នកទោសចូលរាប់ម៉ឺននាក់ ប៉ុន្តែអាការថតវាតិចដែរ ប៉ុន្តែយកទៅសម្លាប់ចោលវាច្រើន។ បីបួនពាន់នាក់ មិនទេ វាច្រើនណាស់។ ហ្វីលគរឡើងត្រឹមជង្គង់ហើយ មិនបួនប្រាំពាន់នាក់ឯណា។

**ស៖** ដោយសារខ្ញុំអត់ពេល ខ្ញុំសួរសំណួរចុងក្រោយ។ ហ្វីលចំនួន៥.០០០<> រូបថត៥.០០០ <កំណត់ហេតុប្រវត្តិរូប៥.០០០> ចម្លើយសារភាពប្រហែលជា៤.០០០ <នៅក្នុង>បញ្ជី<ថ្មី>របស់សហថៅក្រមស៊ើបអង្កេត គឺមានមនុស្ស៥.០០០នាក់ត្រូវបានសម្លាប់ចោល។ នៅក្នុង<ឯកសារដ៏សំខាន់របស់ចិនបាន>យោង<ថា មានជនរងគ្រោះ៥.០០០នាក់។>។ <តើអាចទៅរួចទេ> តាមបទពិសោធន៍ និងការចងចាំរបស់លោក <>ដែលថាមានអ្នកទោសប្រហែលជាប្រាំ<>ពាន់នាក់ប៉ុណ្ណោះ ដែលត្រូវបានគេឃុំឃាំងនៅស-២១ ក្រោយមកគេយកទៅសម្លាប់ចោល?

[០៩:៤៩:២៥]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមានអ្វីជំទាស់ទេ ដោយសារគាត់មានពេលវេលាសល់តែពីរបីនាទី ប៉ុន្តែ<បើ>គាត់<ព្យាយាម>បង្ហាញព័ត៌មាន បញ្ចូកព័ត៌មាននេះទៅសាក្សី<ដោយយោងទៅលើភស្តុតាងរបស់អ្នកដទៃ ដែលគាត់ជឿថាមាននោះ គាត់គួរតែដកស្រង់មក ដូច្នេះយើងទាំងអស់គ្នានឹងអាចពិនិត្យមើលបាន>។ <>ខ្ញុំមិនដឹងថាតើគាត់បានតួលេខ ឯកសារចម្លើយសារភាពទាំងអស់<ដែលរកឃើញ>ពីស-២១ ក៏ដូចជា<ឯកសារយោងទាំងអស់នោះពីណាមកនោះទេ។ ដូច្នេះហើយខ្ញុំគិតថាគាត់កំពុងតែព្យាយាមសួរនាំមុខសាក្សីនៅទីនោះ។ លុះណាតែគាត់ធ្វើឲ្យបានល្អ ដោយសួរផ្ទុញសាក្សីជាមួយនឹងភស្តុតាង។> អ៊ីចឹងខ្ញុំសូមជំទាស់។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំ<មិនជឿទេលោកប្រធាន ដែលថា>សហព្រះរាជអាជ្ញា<នៅតែមិនដឹងនូវអ្វីដែលលោក ផេនដ៍ល័រ និយាយអំពីចំនួនចម្លើយសារភាពដែលគេបានរកឃើញ ៤.១៦៦-->

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<លោកមេធាវី លោកដឹងវាយ៉ាងម៉េច? សូមឯកសារយោង។>

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំដឹង ប៉ុន្តែដោយសារតែ<បន្ថយពេលវេលារបស់>ខ្ញុំ <ទើបខ្ញុំសង្ខេបភស្តុតាងនោះ។ ពេលនេះលោកចៅក្រមចង់ឲ្យ>ខ្ញុំ<>ផ្តល់ERN<របស់ភស្តុតាងដែល>យើងធ្លាប់<បានដោះស្រាយអស់រយៈពេល៨>ឆ្នាំ<ចុងក្រោយនេះឬ?>

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើត្រឹមត្រូវទេលោកសាក្សី សំណួរខ្ញុំសួរអម្បាញ់មិញនេះ?

[០៩:៥០:៤៤]

**ប្រធានអង្គជំនុំ៖**

លោកផ្តល់លេខERN លេខឯកសារសិនទៅ មានទាំងឯកសារមកពីចិនមកពីអ៊ីអ៊ីចឹង។ លោកបញ្ជាក់ឯកសារពាក់ព័ន្ធនឹងទាំងអស់មក លោក វ៉ិចទ័រ កូប៉េ ទាំងអត្តសញ្ញាណឯកសារ ទាំងលេខទំព័រ ERN បើអាចធ្វើបានបីភាសា បើធ្វើមិនបានទេ ភាសាដែលចាំបាច់ចំពោះមុខ ហើយលោកនឹងផ្តល់ពេលក្រោយ ដូចលោកបានធ្វើអំមិញអ៊ីចឹងណា៎។

**លោក វ៉ិចទ័រ កូប៉េ៖**

ដូចខ្ញុំបាន<>និយាយ<ហើយ>ថា <ការដកស្រង់ថាមាន>ចម្លើយសារភាព<៤.១៦៦>នេះ គឺចេញពីសៀវភៅរបស់ ដេវីដ ឆេនដ៍ល័រ ហើយដែលយើងតែងតែដកស្រង់យកមកយោងយ៉ាងច្រើន។ តួលេខចំនួន៥.០០០នេះ គឺគេហៅរបាយការណ៍ <ហ្គេង បៀវ>មកពីប្រទេសចិន <ដែលត្រូវបានពិភាក្សាយ៉ាងទូលំទូលាយជាមួយអ្នកជំនាញ បេកយ័រ>។ ហ្វីលចំនួន៥.០០០ ចំនួននេះគឺលោកអាចរកឃើញនៅគ្រប់កន្លែងទាំងអស់នៅក្នុងសំណុំរឿង។ <ខ្ញុំអត់មានលេខយោងជាERNទេ-->

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<លោកមេធាវី ជាមួយនឹងការគោរពទាំងអស់-->

**លោក វ៉ិចទ័រ កូប៉េ៖**

<--ឥឡូវនេះ-->

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ខ្ញុំចង់និយាយថា> លោកដឹង<លេខ> ERN <និងរបៀបដកស្រង់វាយ៉ាងម៉េចហើយអីតើ។>

[០៩:៥១:៥១]

**លោក វ៉ិចទ័រ កូប៉េ៖**

អ៊ីចឹងខ្ញុំសូមឈប់សួរសំណួរនេះតែម្តង។

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហ តំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី។

មន្ត្រីរដ្ឋបាលតុលាការបង្វែរក្បាលមីក្រូហ្វូនមកខាងកើតបន្តិច!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ ឌេល លីសាក់។ ខ្ញុំនឹងសួរសំណួរខ្លះៗទៅកាន់លោកនៅព្រឹកនេះ ហើយប្រហែលជានឹងបន្តខ្លះៗទៅទៀតនៅរសៀល។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ឥឡូវខ្ញុំសួរអំពីប្រវត្តិសាវតារផ្ទាល់ខ្លួនរបស់លោកតែម្តង។ លោកបានឆ្លើយថា លោកបានចូលរួមបដិវត្តន៍នៅពេលដែលលោកមានអាយុប្រហែលជា១១ឆ្នាំ។ <>តើលោកមានអាយុប៉ុន្មាននៅពេលដែលខ្មែរក្រហមឲ្យអារុធមកលោកស្លាយ<ជាលើកដំបូងនោះ>?

[០៩:៥៣:០៨]

**លោក ញ៉ែម អេន៖**

**ឆ៖** បាទអរគុណលោកព្រះរាជអាជ្ញាអន្តរជាតិ។ សូមគោរពលោកប្រធាន។ ជាការពិតក្រោយពីនរោត្តម លន់ នល់ ទម្លាក់ព្រះអង្គម្ចាស់នរោត្តម សីហនុ ចេញរាជបល្ល័ង្ក ខ្ញុំបាទបានចូលធ្វើបដិវត្តន៍នៅឆ្នាំ១៩៧១ បាទថ្ងៃ២៤ ខែ៧ បាទខ្ញុំចាំច្បាស់ណាស់ ថ្ងៃ២៤ ខែ៧ ឆ្នាំ១៩៧១។ ក្នុងនោះ គឺមានបងប្អូនខ្ញុំប្រាំនាក់ចូលធ្វើបដិវត្តន៍ គឺខ្ញុំបាទ ស្ពាយកាំភ្លើងបាទ។ ស្ពាយកាំភ្លើងមែនបាទ ស្ពាយកាំភ្លើងម៉ាទ្រីយ៉ែត។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កាំភ្លើងម៉ាទ្រីយ៉ែតហ្នឹងវាមាន៣២--

**ប្រធានអង្គជំនុំ៖**

សាក្សីចាំស្ដាប់សំណួរសិន យើងប្រាប់ហើយ ស្ដាប់សំណួរឲ្យបានឆ្លើយតបភាពចាំបាច់ទៅនឹងសំណួរបានហើយណ៎ា។ កាលណាលោកឆ្លើយហៀរទៅ វាអត់ភាពចាំបាច់ ហើយខាតពេលផង ហើយសម្ពាធបន្ទុកនៃសំណួរវាអាចពាក់ព័ន្ធ និង ដាក់បន្ទុកលើលោកបន្ថែម។ នេះយើងគ្រប់គ្រងពេលវេលា បើសិនជាគ្រប់គ្រងពេលវេលាមិនបានទេ គឺលោកនឹងមានសម្ពាធតឹងតែងណាស់ក្នុងការឆ្លើយនឹងសំណួរដ៏មានបច្ចេកទេសនៃនីតិវិធីតាមផ្លូវតុលាការនេះ ហើយអ្នកដែលប្រឈមនឹងការលំបាកនោះគឺលោកទេ។ យើងសង្ឃឹមថា លោកស្ដាប់សំណួរឲ្យបាន ហើយឆ្លើយតបកម្រិតត្រឹមតែពេញលេញ សមស្រប ឆ្លើយតបនឹងសំណួរហ្នឹងបានហើយ។

[០៩:៥៤:៣៦]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកបានឆ្លើយថា គេបានប្រគល់អាវុធឲ្យលោក< ហើយអាវុធនោះគេហៅថា ម៉ាទ្រី-យ៉ែត។> តើអាវុធនោះជាប្រភេទណាដែរ? ហើយនៅពេលដែលលោកចូលរួមជាមួយបដិវត្តន៍ តើលោកនៅក្នុងកងកុមារ ឬក៏អត់ទេ? <> តើកុមារដទៃទៀតនៅក្នុងកងរបស់លោកនោះ មានអាវុធដូចលោកដែរទេ?

**លោក ញ៉ែម អេន៖**

**ឆ៖** បាទ លោកមេធាវី ទាក់ទងបញ្ហានេះខ្ញុំបាទបានចូលរួមនៅការតស៊ូនេះ កាំភ្លើងគឺម៉ាកម៉ាទ្រីយ៉ែត។ ម៉ាទ្រីយ៉ែត គឺខ្ញុំមិនចាំប្រទេសប្រហែលជាអាច មិនអាល្លឺម៉ង់ទេ រ៉ូម៉ានី និងគុយបា តែបីប្រទេសហ្នឹងទេបាទ។ ប៉ុន្តែដែលការចូលរួមនេះគឺ ខ្ញុំបាទចូលរួមជាមួយបងៗខ្ញុំ។ ដូច្នេះកាំភ្លើងនេះគឺ បើនិយាយឲ្យចំទៅដែលខ្ញុំបានមកនេះ គឺខាង សម័យនោះគឺថាយៀកកុង គឺថាខ្មែរខាងជើងនៃវៀតណាមគាត់បានចូលមកតាមរយៈ តាមអ៊ំហ្វូ យន់ និង អ៊ំហ្វូ នឹម មកដល់ផ្ទះខ្ញុំតែម្ដងបាទ។

**ស៖** សំណួរខ្ញុំមួយផ្សេងទៀត។ ឥឡូវនេះយើងនិយាយតែអំឡុងពេលក្រោយពេលលោកចូលបដិវត្តន៍សិន គឺនិយាយមុនថ្ងៃ១៧ មេសា ៧៥។ តើមានពេលណាមួយនោះ លោកនៅក្នុងកងកុមារទេ? ហើយបើលោកនៅកងកុមារ តើកុមារដទៃទៀតមានកាំភ្លើងកាន់ដែរទេ?

**ឆ៖** បាទ លោកៗព្រះរាជអាជ្ញា មានបាទ។ ក្នុងកុមារហ្នឹងគេហៅថា "កុមាររណសិស្សរួបរួម

ជាតិកម្ពុជា"។ កាំភ្លើងមានការ៉ាប៊ីន មានម៉ាទ្រីយ៉ែត មានតាំសុន មានអ្នកកាន់កាំភ្លើងប្រហែលជាសាមសែសិបនាក់ដែរ ក្នុងរួមជាមួយកងទ័ពឈ្លបទាំងអស់។ កាំភ្លើងនេះគឺបានមកពីអង្គការបញ្ជូនមកពីខេត្តកំពង់ធំ មកពីហៅថា ក្រយា-ដងក្ដារ។ បាទ នេះជាការពិតបាទ។

[០៩:៥៦:៤២]

**ស៖** ហើយសំណួរចុងក្រោយទៅលើប្រធានបទនេះ ចុះតើកុមារដទៃៗទៀតនោះនៅក្នុងកងជាមួយនឹងលោកមានអាយុប៉ុន្មានដែរ?

**ឆ៖** បាទ អាយុមិនជាលើសខ្ញុំប៉ុន្មាន ហើយក៏មិនជាក្រោមប៉ុន្មានដែរ ភាគច្រើនគឺស្រករៗគ្នានឹងបាទ។ ក្នុងកងកុមារហ្នឹងគឺភាគច្រើនគឺប្រចាំនៅសមរភូមិស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ហើយអាចជៀសទៅដល់ខេត្តកំពង់ធំ ស្រុកសន្ទុកមួយទៀត។ សមរភូមិគឺតឹងតែងណាស់ គឺមានការមានទាំងស្ពាយកាំភ្លើងហ្នឹង មានការដឹកស្បៀងអាហារទៅសមរភូមិទៀត។

**ស៖** បាទ សូមអរគុណ។ មេធាវី នួន ជា បានសួរសំណួរខ្លះៗមកហើយ អំពីដំណើររបស់លោកទៅរៀននៅស្រុកចិន។ ខ្ញុំសូមសួរបញ្ជាក់ថា តើលោកបានចាប់ផ្ដើមធ្វើអ្វី នៅក្នុងខែមិថុនា ឆ្នាំ៧៦ ក្រោយពីត្រឡប់មកពីប្រទេសចិនវិញ? ហើយនៅក្នុងចម្លើយថ្មីៗ<របស់លោកឆ្លើយ>ជូនសហចៅក្រមស៊ើបអង្កេតគឺឯកសារ E3/9532 ត្រង់សំណួរចម្លើយលេខ៦ លោកបានឆ្លើយថា សូមដកស្រង់៖ "ក្រោយពីខ្ញុំត្រឡប់មកពីប្រទេសចិនវិញ ខ្ញុំបានត្រឡប់ទៅធ្វើការនៅមន្ទីរ៨៧០ ហើយក្រោយមកគេចាត់តាំងឲ្យខ្ញុំទៅធ្វើជាអ្នកថតរូបនៅគុកទួលស្លែង និងនៅទូទាំងប្រទេសផងដែរ។" បញ្ចប់ការដកស្រង់។

ហើយខ្ញុំសូមអានសម្រង់មួយ ដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេតនៅឆ្នាំ២០០៧ គឺឯកសារ E3/68 ERNជាអង់គ្លេស 00401819, ខ្មែរ 00162837 ដល់ 838, បារាំង 00195658។ ហើយនៅត្រង់នេះ គឺថាលោកនិយាយយោងទៅលើពេលវេលា ដែលក្រោយពីលោកត្រឡប់មកពីប្រទេសចិនវិញ។ លោកបានឆ្លើយថា សូមដកស្រង់៖ "ក្រោយពីខ្ញុំបានមកដល់ភ្នំពេញ ខ្ញុំមិនទាន់បានទៅធ្វើការនៅស-២១ ទេ គឺខ្ញុំធ្វើការនៅមន្ទីររបស់នាយអគ្គសេនាធិការ ដើរថតរូប<>។ សួរ៖ តើលោកធ្វើអ្វីក្រោយពេលមកដល់ប្រទេសកម្ពុជា? ឆ្លើយ៖ ខ្ញុំនៅឯសេនាធិការដ្ឋាននៅភ្នំពេញជិតមន្ទីរពេទ្យមុនីវង្ស។ (លោកថា)ជាមន្ទីរ<ព>-៩៨។ <នៅពេលនោះ ខ្ញុំបានចាប់ផ្ដើមធ្វើរោងពុម្ពដើម្បីបោះពុម្ពកាសែត និងទស្សនាវដ្ដី។> សួរ៖ <>នៅពេលនោះ អ្នកណាជាមេរបស់លោក? ឆ្លើយ៖ ខ្ញុំមានមេពីរនាក់ មួយឈ្មោះថា <តាប៉ង់> ដែលជាភ្នាក់ងារពិសេសរបស់ ប៉ុល ពត។ ម្នាក់ទៀតឈ្មោះ នឿន ដែលជិតដិត

ជាមួយនឹង សុន សេន។ សួរ៖ <នឿន> មានតួនាទីធ្វើអ្វី? ឆ្លើយ៖ យោងតាមអង្គការ គេហៅថាជានីរសារនៅទីក្រុង"។ ហើយ<នៅពីរទំព័រ>ក្រោយមកទៀត<គេ>សួរថា លោកធ្វើការនៅជិតមន្ទីរពេទ្យមុនីវង្សរយៈពេលប៉ុន្មានដែរក្រោយពីមកពីចិនវិញ? ឆ្លើយ៖ ថាប្រហែលជាបីទៅបួនខែទេ គឺនៅពេលនោះគឺជារដូវ<រំហើយ> អ៊ីចឹងប្រហែលជានៅក្នុងខែវិច្ឆិកា និងខែធ្នូ តែប៉ុណ្ណោះឯង។"

តើចំណុចទាំងអស់នេះវាជួយរំឭកដល់ការចងចាំរបស់លោកទេ ថាក្រោយពេលលោកត្រឡប់មកពីប្រទេសចិនវិញ លោកធ្វើការនៅមន្ទីរមួយជិតមន្ទីរពេទ្យមុនីវង្ស មុនពេលគេបញ្ជូនលោកទៅឲ្យធ្វើការនៅស-២១ តើត្រឹមត្រូវដែរទេ?

[១០:០០:៤៩]

**ឆ៖** លោកព្រះរាជអាជ្ញា ជាការត្រឹមត្រូវ បាទព្រោះកាលខ្ញុំមកពីប្រទេសចិននេះ មុននឹងចូលស-២១ ហើយឆ្លៀតពេលថតជាច្រើនណាស់ គឺខ្ញុំពណ៌នាមិនអស់វាច្រើនពេក បាទវាច្រើនណាស់។ ចម្លើយដែលការនិយាយ គឺជាការត្រឹមត្រូវបាទ ត្រឹមត្រូវ។

**ស៖** ហើយក្នុងអំឡុងពេលនោះ នៅពេលដែលលោកធ្វើការនៅមន្ទីរមួយនៅជិត<មន្ទីរពេទ្យមុនីវង្ស ព>-៩៨ តើគេឲ្យលោកធ្វើការពិសេសធ្វើអ្វី? ហើយតើលោកត្រូវមានភារកិច្ចរាយការណ៍ជូនអ្នកណា?

**ឆ៖** បាទ លោកព្រះរាជអាជ្ញាអន្តរជាតិ នេះជារឿងសំខាន់ដែរ មិនមែនសំខាន់ដែរ សំខាន់មែនទែន។ ភារកិច្ចខ្ញុំ គឺការងារដូចជាការងារច្រើនដែរ ជាពិសេសនាំសារបាទ។ នាំសារគឺនាំសារពីពេទ្យមុនីវង្ស ពេទ្យមុនីវង្សមិនមែនជាពេទ្យទេបាទ កាលនោះគឺព-៩៨ ពេទ្យកងទ័ព ក៏ប៉ុន្តែជាគុកមួយទៀត។ ហើយនាំសារនេះ គឺការងារដែលពិសេសគឺយកឯកសារទៅតាខ្មៅ បាទទៅខាងពេទ្យឆ្កួតតាខ្មៅហ្នឹង។ ហើយការងារជុំវិញហ្នឹង គឺជាពិសេស គឺសារសំខាន់ៗគឺខ្ញុំអ្នកកាន់ទៅតែម្តងបាទ មានចុះហត្ថលេខាពីប៉ុល ពត ចុះហត្ថលេខាពីអ្នកដឹកនាំមួយចំនួន គឺអ្នកទោសនៅ គេហៅថានៅតាខ្មៅគេវៃចោលជាច្រើនដែលខ្ញុំយកទៅបាទ។ ជាការពិត គឺជាការងារច្រើនណាស់ ខ្ញុំពិពណ៌នាទៅវាវែងឆ្ងាយ វាខុសពីចាកប្រធានសំណួរបាទ។

[១០:០២:២៥]

**ស៖** ហើយក្នុងអំឡុងពេលដែលលោកត្រឡប់មកពីប្រទេសចិនវិញ<ជាលើកដំបូង> តើលោកមានបន្តធ្វើដំណើរទៅតាមបណ្តាខេត្តផ្សេងៗជាមួយមេដឹកនាំខ្មែរក្រហមដើម្បីថតរូបដែរទេ? ឬក៏ថា

ពេលវេលាដែលលោកចុះទៅថតរូបជាមួយមេដឹកនាំហ្នឹង គឺក្រោយពេលដែលលោកទៅធ្វើការនៅឯស-២១រួចមកហើយទេ?

**ឆ៖** បាទ លោកព្រះរាជអាជ្ញា រឿងនេះវាដូចត្រឡប់ក្រោយ ទៅមុខទៅក្រោយ ដូចគ្នាៗអ៊ីចឹងថា ពេលដែលធ្វើការនៅក្នុងទួលស្លែងហើយ ក៏ឆ្លៀតពេលទៅថតដូចជានៅអង្គរវត្ត អ៊ំប៉ុល ពត គណៈប្រតិភូចិន អគ្គរដ្ឋទូតអីផ្សេងៗដែលប្រទេសកុម្មុយនីស្ត នៅប្លុកកុម្មុយនីស្តគេមកហ្នឹង គឺទៅថត មិនថាអ្នកដឹកនាំ ប៉ុន្តែភាគច្រើនគឺទៅៗតាមអ៊ំប៉ុល ពត និងអ៊ំសុន សេន ប៉ុន្តែអ៊ំខៀវ សំផន មិនដែលបានទៅជាប់ជាមួយគាត់ទេ គឺភាគតិចណាស់ ព្រោះមិនដែលឃើញគាត់ ឃើញតិច។ ក៏ប៉ុន្តែអ្នកដឹកនាំផ្សេងៗគឺការងារវាច្រើន ដូចខ្ញុំប្រាប់លោកព្រះរាជអាជ្ញាអ៊ីចឹង ដែលខ្ញុំពណ៌នាទៅ បើសិនណាខ្ញុំនិយាយ ខ្ញុំនិយាយមួយខែមិនអស់នៅកន្លែងហ្នឹង វាច្រើនបាទ ប៉ុន្តែកុំឱ្យពេលវេលាវាកន្លងផុត ដូច្នេះខ្ញុំនិយាយតែចំណុចពិសេស។ ជាការពិត អ្នកដឹកនាំខ្ញុំថតជាច្រើន ពីព្រោះឯកសារខ្ញុំមានរូបថតរក្សាទុកដល់រាល់ថ្ងៃប្រហែលជា៥.០០០សន្លឹកទៀតដឹកនាំខ្មែរក្រហមបាទ។ ហើយទាក់ទងនឹងបញ្ហាផ្សេងៗគឺខ្ញុំមានបាទ នេះដូចជាកន្លែងក្នុងបាទរោងពុម្ព។ នេះសម័យហ្នឹងគឺប្រាប់លោកប្រធាន ព្រះរាជអាជ្ញាថាមានតែកាសែតមួយគត់គឺការសែតបដិវត្តន៍ ទស្សនាវដ្ដីបក្ស តែប៉ុណ្ណឹង វាច្រើនណាស់ព្រះរាជអាជ្ញា ខ្ញុំសូមទោស ខ្ញុំពណ៌នាទាំងអស់ វាច្រើន។

[១០:០៥:០០]

**ស៖** តើលោកចុះទៅតាមបណ្ដាខេត្ត ទៅតាមភូមិភាគ<ដើម្បីទៅថតរូបភាព>ញឹកញាប់ប៉ុនណាដែរ? មួយខែម្ដង ឬក៏ញឹកញាប់ជាងមួយខែម្ដង ឬក៏តិចជាងមួយខែម្ដង? អ៊ីចឹងតើលោកអាចជម្រាបជូនតុលាការបានទេថាលោកចុះទៅតាមបណ្ដាខេត្ត និងបណ្ដាភូមិភាគជាមួយមេដឹកនាំខ្មែរក្រហមហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** បាទ ជាការត្រឹមត្រូវ លោកព្រះរាជអាជ្ញា។ ការចុះជាប់ ខ្ញុំសូមជម្រាបទៅលោកប្រធាន និងព្រះរាជអាជ្ញាថា ពេលវេលាទី១ ការងារស្នូលគឺទួលស្លែង។ បន្ទាប់ពីការងារស្នូល គឺពេលដែលចាកទំនេរ គឺជួនកាលទៅតាមភូមិភាគទៅតាមតំបន់នានា គឺមិនញឹកញាប់ ជួនកាលពីរខែម្ដង បីខែម្ដង វាអត់ទៀង។ ដូច្នេះតាមតែគណៈប្រតិភូអន្តរជាតិ ប្រទេសផ្នែកសង្គមនិយម ប្លុកកុម្មុយនីស្តនៅអឺរ៉ុប ដូចជាប្រទេសកូរ៉េខាងជើង ដូចជាចិន យូហ្គោស្លាវី រ៉ូម៉ានីអ៊ីចឹងទៅ។ ខ្ញុំពណ៌នាអស់មែនជាការពិត វាប៉ុន្តែពេលវេលាយើងប្រើអត់បាន ជួនកាលចន្លោះ ការចាំបាច់ទៅ ព្រោះខ្ញុំមានឯកសារជាច្រើនទៀតសម្រាប់

បង្ហាញនៅតុលាការអន្តរជាតិនៅពេលនេះ។

**ស៖** អ្នកណាចាត់តាំងឱ្យលោកទៅថតរូបនៅតាមដំណើរទស្សនកិច្ចទាំងអស់នេះ? <> តើរូបថតទាំងអស់នេះគេយកមកប្រើប្រាស់ក្នុងគោលបំណងអ្វីដែរ?

**ឆ៖** *អូ.ខេ* បាទ លោកព្រះរាជអាជ្ញា ជាត្រឹមត្រូវ ការមកប្រើប្រាស់នេះ សម័យហ្នឹងមានដូចជាខ្ញុំជម្រាបណ៎ា មានកាសែតបដិវត្ត មានទស្សនាវដ្ដីបដិវត្ត ទង់១, ទង់២, ទង់៣, ទង់៥ ហើយយកមកប្រើការងាររដ្ឋបាល ទាក់ទងនឹងមុខងារសាធារណៈរបស់ខ្មែរក្រហមតែម្តងណាស់ គឺច្រើនណាស់លោកព្រះរាជអាជ្ញា ការប្រើប្រាស់គឺជាប្រធានបទមួយសម្រាប់របបកម្ពុជាប្រជាធិបតេយ្យ និងអាចបញ្ជូនតាមស្ថានទូតដែលប្រចាំនៅកម្ពុជាតែម្តងបាទ។

[១០:០៥:៥៩]

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសុំការអនុញ្ញាតបង្ហាញជូនឯកសារ គឺឯកសារ E3/9295 – E3/9295 ដែលយើងខ្ញុំយល់ថាជាទស្សនាវដ្ដីកម្ពុជាប្រជាធិបតេយ្យចេញប្រចាំខែ ក្រែងថាសាក្សីអាចនឹងនៅស្គាល់ឯកសារនេះបាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី ឯកសារដែលខ្ញុំឱ្យទៅលោកនេះគឺជាទំព័រខ្លះៗនៃទស្សនាវដ្ដីបោះពុម្ពផ្សាយប្រចាំខែ ឯកសារ E3/9295 សុំលោកពិនិត្យមើលឯកសារនេះមើល ហើយតើលោកនៅចាំទស្សនាវដ្ដីនេះទេ? ហើយនៅក្នុងទស្សនាវដ្ដីនេះ តើរូបថតនៅក្នុងទស្សនាវដ្ដីនេះ ជារូបថតដែលលោកបានថតដោយផ្ទាល់ដៃឬក៏អត់ទេ?

**លោក ញ៉ែម អេន៖**

**ឆ៖** បាទ លោកព្រះរាជអាជ្ញា រូបថតនេះ ខ្ញុំថត៨០ភាគរយ បាទ៨០ភាគរយនេះ បាទខ្ញុំថត។ ដូចជាការជញ្ជូនជ័រកៅស៊ូ ជញ្ជូនកប្បាសទៅប្រទេសចិន ដាក់នៅយើងកំពង់ផែភ្នំពេញ យកទៅកំពង់សោមអី បាទនេះការពិត។ នេះទស្សនាវដ្ដីនេះ នៅកន្លែងធ្វើនៅផ្សារថ្មី បាទនៅផ្សារថ្មីយើងហ្នឹង កន្លែងខ្ញុំស្គាល់កន្លែងធ្វើទៀត។ អ៊ីចឹងថា ជាការពិត លោកព្រះរាជអាជ្ញា នេះវាទាក់ទងនឹងបញ្ហានេះ ដូចជា

ឯកសារត្រូវនេះជា លោកចៅក្រមនេះ តាណាត ៗនេះ, នេះចិន, តាសោម កងពល (ឮមិនច្បាស់) អា នេះជាការពិត។ ឯកសារហ្នឹងវាជាការត្រឹមត្រូវបាទ អត់មានក្លែងបន្លំបាទ ជាការពិតមែន។

[១០:០៨:០៥]

**ស៖** អ្នកណាជាអ្នកទទួលបន្ទុកបោះពុម្ពផ្សាយទស្សនាវដ្ដីហ្នឹង? តើមានអង្គភាពណា មានឈ្មោះអង្គភាពអី ឬក៏មន្ទីរអីដែលទទួលខុសត្រូវក្នុងការបោះពុម្ពផ្សាយទស្សនាវដ្ដីនេះ? លោកដឹងដែរទេ?

**ឆ៖** បាទ លោកព្រះរាជអាជ្ញា សម័យនុ៎ងគឺ ខ្ញុំចាំមិនភ្លេចទេ គឺឯកឧត្ដម ហ៊ូ នឹម បាទ គាត់ទទួលបន្ទុកខាងព័ត៌មានឃោសនាការ។ ហើយមានប្អូកមួយទៀតលោកស្រី អៀង ធីរិទ្ធ គាត់ទទួលបន្ទុកខាងក្រសួងអប់រំ គឺមានកន្លែងប្អូកមួយធ្វើទស្សនាវដ្ដី ប៉ុន្ដែធ្វើហ្នឹង មិនជាច្រើនប៉ុន្មានទេ ប៉ុន្ដែគ្រាន់តែចែកតាមតំបន់ ភូមិភាគនានាទូទាំងប្រទេសកម្ពុជាហ្នឹងគឺ អ្នកដែលគ្រប់គ្រងគឺគ្មានពីណាក្រៅពី សុន សេន ក្រៅពី តាណាត និង ហ៊ូ នឹម។ ខ្ញុំនៅជាមួយអាំហ៊ូ នឹម មួយចំនួនដែរ ដែលខ្ញុំទាក់ទងនឹងបញ្ហាព័ត៌មាន។ បាទ គឺខ្ញុំមិនចាំមិនភ្លេចទេបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ៗសហព្រះរាជអាជ្ញារង។ បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ដ្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:០៩ នាទី ដល់ម៉ោង ១០:៣០ នាទី)*

[១០:៣០:៤៨]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅខាងតំណាងសហព្រះរាជអាជ្ញាអន្តរជាតិសួរដេញដោលសាក្សី ហើយមន្ត្រីរដ្ឋបាលតុលាការដកហូតនូវដុំរូបថតពីសាក្សីវិញ ហើយបានន័យថា ទុកសិនទៅ។ ហើយអង្គជំនុំជម្រះសូមជម្រាបសាក្សីថា ប្រសិនបើសាក្សីត្រូវការគាំទ្រនូវចម្លើយតបរបស់លោកករណីណាមួយចាំបាច់ គឺបំផុត គឺលោកអាចនឹងស្នើសុំដើម្បីយកទៅធ្វើជាសំអាងមូលដ្ឋានក្នុងការចង្អុលបង្ហាញ។ ហើយយើងនឹងបំពេញកិច្ចនីតិវិធីបន្តទៅមុខទៀត លើបញ្ហាចំពោះឯកសារណាដែលពាក់ព័ន្ធនឹងការគាំទ្រនឹងចម្លើយតបរបស់លោកចំពោះសំណួរ។

បាទ តទៅនេះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ហើយសហព្រះរាជអាជ្ញាអន្តរជាតិ តាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមថ្លែងអំណរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី លោកបាននិយាយអម្បាញ់មិញ ពាក់ព័ន្ធទៅនឹងរូបថត ពាក់ព័ន្ធទៅនឹងដំណើររបស់លោកទៅកាន់ភូមិភាគនៅក្នុងសម័យ<>នោះ។ តើលោកអាចប្រាប់បានទេ<> លោកបាននិយាយអំពីលោក ប៉ុល ពត និង សុន សេន ថាតើលោកមានបានទៅជាមួយនឹងថ្នាក់ដឹកនាំណាផ្សេងទៀតទេ ទៅកាន់ភូមិភាគនោះ?

[១០:៣២:៥៧]

**លោក ញ៉ែម អេន៖**

**ឆ៖** បាទ លោកព្រះរាជអាជ្ញា ការទៅហ្នឹង គឺទី១ អ៊ំប៉ុល ពត, ទី២ តាម៉ុក, ទី៣ អៀង សារី, ទី៤ សុន សេន, ទី៥ នួន ជា។ ដូចខ្ញុំបាទទៅទស្សនកិច្ច ឬក៏ថតគណៈប្រតិភូមក លើកទំនប់ ជីកប្រឡាយ បាទ ដូចជានៅទំនប់៦មករា ទំនប់៣០កញ្ញា អាងទឹកកំពីងពួយ អាងទឹកត្រពាំងថ្ម មានតំបន់ជាច្រើនទៀត ដែលខ្ញុំពណ៌នាមិនអស់ លោកព្រះរាជអាជ្ញា។

**ស៖** តើលោកចាំបានទេ ថាតើមានទីតាំងណាខ្លះដែលលោកបានធ្វើដំណើរជាមួយនឹងលោក នួន ជា នោះ?

**ឆ៖** លោកព្រះរាជអាជ្ញា ខ្ញុំបាទធ្វើដំណើរទៅតាមគាត់ពីរដង បានទៅខាងយើងភូមិភាគបស្ចិម និងភូមិភាគពាយ័ព្យ ទៅមើលសកម្មភាពលើកទំនប់ ជីកប្រឡាយនៅតំបន់នោះ។

**ស៖** តើលោកចាំថាតើមានទំនប់អ្វីខ្លះ ឈ្មោះអ្វីខ្លះ នៅការដ្ឋានណាខ្លះ នៅពេលដែលលោកធ្វើដំណើរជាមួយនឹងលោក នួន ជា ទៅ<ពាយ័ព្យ>នោះ?

**ឆ៖** បាទ ការធ្វើដំណើរទៅអាងកំពីងពួយ អាងកំពីងពួយៗ នៅខេត្តបាត់ដំបង។ មានទំនប់មួយទៀតនៅយើង ម្ដុំជើង ហៅៗថា តំបន់៣១ ម្ដុំយើងភ្នំគុក បាទភ្នំគុកខេត្តកំពង់ឆ្នាំង។

**ស៖** លោក កូប៉េ <>បានសួរលោកកាលពីម្សិលមិញ<ថាតើលោកមានរូបថត>លោក រស់ ញឹម <ទេ។ តើ>លោកបានថតរូបលោក នួន ជា <ទេ ពេលធ្វើដំណើរ>ទៅកាន់ភូមិភាគនោះ<>?

[១០:៣៥:១៤]

**ឆ៖** បាទ រូបថតខ្ញុំបាទនៅ អត់បានយកមកនៅឯសៀមរាបទាំងអស់បាទ។

**ស៖** តើលោកអាចធ្វើការស្មានថាតើមានរូបថតដែលលោកថត នួន ជា ហ្នឹងមានចំនួនប៉ុន្មាន អាចស្មានមើលមានប្រហែលជាប៉ុន្មាន?

**ឆ៖** លោកព្រះរាជអាជ្ញា ខ្ញុំពណ៌នាមិនបាន វាច្រើនដែរ ច្រើន ទៅជាការប្រជុំ តូចធំ គណៈប្រតិភូ ដូចប្រជុំគណៈភូមិភាគ គណៈតំបន់ គេអញ្ជើញតាមតំបន់នានាមកប្រជុំភ្នំពេញគឺមាន មានជាច្រើន ប្រហែលជាខ្ទង់មិនក្រោមបីបួនរយសន្លឹកទេ។ ប៉ុន្តែឥឡូវវា យើងខ្ញុំបាត់បង់ជាច្រើន យើងបានឃើញតិចណាស់ បាទឃើញតិច។

**ស៖** ថាតើមានពេលណាដែលលោក ខៀវ សំផន ហ្នឹងធ្វើដំណើរជាមួយក្រុមថ្នាក់ដឹកនាំហ្នឹង ហើយលោកទៅជាមួយគាត់ដែរឬទេ?

**ឆ៖** បាទ លោកព្រះរាជអាជ្ញា បើទាក់ទងនឹង អ៊ំខៀវ សំផន ខ្ញុំនិយាយចំពោះលោកប្រធានតុលាការណេះ ខ្ញុំឃើញកម្រគាត់ទៅណាស់ ទៅក្រៅកម្រ កម្រឃើញ។ សម័យនោះប្រជុំតូចធំអី ខ្ញុំកម្រឃើញគាត់ កម្រឃើញគាត់ និយាយឲ្យត្រង់តែម្ដង គឺកម្រឃើញតែម្ដង ព្រោះត្បិតតែគាត់នៅជាដឹកនាំគណៈប្រធានរដ្ឋមែន ក៏ប៉ុន្តែកាតព្វកិច្ចមួយចំនួនខ្ញុំដែលដឹងផ្ទាល់ និយាយមុខតុលាការថា អង្គការមិនសូវឲ្យគាត់ដឹងដែរ។ ជាពិសេសដឹងខ្លាំង គឺមានតែមួយ ទី១ អ៊ំទី១ ប៉ុលពត, អ៊ំទី២ នួន ជា, អ៊ំទី៣ សុន សេន, អៀង សារី អីចឹងមក។ ប៉ុន្តែអ៊ំ ខៀវ សំផន ខ្ញុំនិយាយថ្ងៃនេះ មុខតុលាការអន្តរជាតិ ខ្ញុំកម្រឃើញគាត់ណាស់ ជាការងារភាគច្រើន គាត់មិនសូវទៅក្រៅ ដូចជាគេមិនសូវទុកចិត្តគាត់ម៉េចមិនដឹងអីដឹង

សម័យនោះ ខ្ញុំមិនសូវយល់ដែរ។

[១០:៣៧:១៥]

**ស៖** អ៊ីចឹងខ្ញុំសូមធ្វើការរំឭកការចងចាំរបស់លោកបន្តិចនៅក្នុងបទសម្ភាសន៍<លើកដំបូងរបស់លោកជាមួយ អូ.ស៊ី.អាយ.ជេ> E3/68 លេខភាសា ជាភាសាអង់គ្លេស 00401820 រហូតទៅដល់ 821 ហើយERNជាភាសាខ្មែរ 00162839 ហើយERN ជាភាសាបារាំង 00195659 ទៅដល់60។ លោកបានផ្តល់សក្ខីកម្មដូចតទៅ៖ “សំណួរ៖ តើលោកមានជួបលោក ខៀវ សំផន នៅតាមខេត្ត ហើយថតរូបថតគាត់ដែរឬទេ? លោកឆ្លើយថា៖ ខ្ញុំបានថត ហើយខ្ញុំថតរូបថ្នាក់ដឹកនាំទូទាំងប្រទេសកម្ពុជាហ្នឹង ហើយថតរូបច្រើន។” ហើយខ្ញុំយល់ថា លោកបាននិយាយថា លោកឃើញថា គាត់ធ្លាប់ទៅម្តងម្កាលដែរ ប៉ុន្តែលោកចាំទេ ថាតើមានពេលណា ឬក៏នៅកន្លែងណាដែលលោកបានទៅហើយឃើញលោក ខៀវ សំផន ទៅដែរនោះ តើទៅកន្លែងណាដែរ?

**ឆ៖** បាទ លោកមេធាវី -- លោកព្រះរាជាអាជ្ញា ខ្ញុំឃើញ ដូចជាឃើញតែម្តងពេលគាត់ជិះរទេះភ្លើងទៅកំពង់សោម ដូចជាម្តងហ្នឹងគត់។ ដូចជាការទៅប្រជុំតាមតំបន់ផ្សេងៗអី ដូចជាឃើញកម្រគាត់ចុះទៅ។ ប៉ុន្តែតែម្តង ដែលគាត់តែម្តងទេ សម័យ៣ឆ្នាំ២០ថ្ងៃ ប៉ុន្តែកិច្ចការអន្តរជាតិ អាហ្នឹងខ្ញុំអត់ដឹងដែរ ទាក់ទងនៅលើពិភពលោក។ ប៉ុន្តែទាក់ទងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អ៊ំខៀវ សំផន លោកក៏មិនដែលជាទៅ ទៅជាញឹកញាប់ដែរ។ ដូចជា -- បើនិយាយឲ្យចំខ្ញុំមិនដែលឃើញ ឃើញតិចណាស់ ឃើញតែម្តង និយាយឲ្យចំ។ គេប្រជុំសភា ប្រជុំកងទ័ពឃើញម្តង ប្រជុំផ្សេងៗសំខាន់ៗ ខ្ញុំដូចជាកម្រឃើញគាត់បាទ។ អានេះជាការពិត។

[១០:៣៩:១៥]

**ស៖** តើលោកបានឃើញគាត់នៅ<កន្លែង>ណា? ហើយឃើញគាត់<>ជួប<>ប្រជុំ<>ជាមួយកងទ័ពហ្នឹងនៅពេលណា ឬនៅកន្លែងណា?

**ឆ៖** ទី១ នៅបុរីកីឡា។ ទី២ ដូចជាប្រជុំនៅតំបន់២៥ នៅស្អាងកោះធំ ដូចជាប្រជុំ មិនមែនប្រជុំ ដូចថាចូលរួមជាមួយសហករណ៍ និងប្រជាពលរដ្ឋ ប្រជាជនដែលគាត់មកចូលរួម។ តែពីរដង បីដង ខ្ញុំឃើញនៅរទេះភ្លើងម្តងបាទ តែប៉ុណ្ណឹង។ ប៉ុន្តែការងារអន្តរជាតិផ្សេងៗទៀត បើនិយាយឲ្យចំ ខ្ញុំបកទៅក្រោយបន្តិច ខ្ញុំមិនដែលឃើញគាត់ ឃើញតិចណាស់ ដូចខ្ញុំជម្រាបជូនលោកព្រះរាជអាជ្ញាអ៊ីចឹងបាទ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** នៅក្នុងសម្រង់ដូចគ្នាហ្នឹងដែរ គឺលោកបានសំដៅទៅលើដំណើរមួយ ដែលលោក ខៀវ សំផន និង អៀង សារី បានទៅជាមួយនឹងលោកនៅពេលដែលពួកគេចូលរួមកិច្ចប្រជុំ<ពិសេសមួយ> នៅ<>កោះធំ។ <តើអ្វីដែលលោកនិយាយនោះ គឺជាកិច្ចប្រជុំ>នៅក្នុងតំបន់២៥<ឬ? បើសិនជាពិតមែន តើលោកអាចប្រាប់យើងបានទេ> ថាតើគេប្រជុំហ្នឹងគឺគេ<>និយាយអំពីអ្វី នៅពេលដែលលោក<បានទៅជាមួយ>លោក ខៀវ សំផន<>នោះ?

**ឆ៖** បាទ ការចូលរួមប្រជុំហ្នឹងអត់មាននិយាយអីផង និយាយពីរឿងសហករណ៍ និយាយពីការជឿនលឿន ឲ្យប្រជាជនទាំងអស់ខំប្រឹង ហើយនិយាយពីការភាពណ្ដានពានរបស់បរទេសជិតខាង។ ដូចជាអត់មាននិយាយអី គឺនិយាយសម្រាប់តែកសាងប្រទេស ឈានពីកសិកម្មសម័យពី១០ឆ្នាំ ទៅ១៥ឆ្នាំ ឧស្សាហកម្មសម័យពី១៥ឆ្នាំ ទៅ២០ឆ្នាំ។ នេះជា១ទិសដៅ១ និងជាច្បាប់របស់អង្គការសម័យនោះ គឺណែនាំទៅដល់ប្រជាជន ដូចជាតំណាងផ្សេង។ ប៉ុន្តែឲ្យនិយាយទាក់ទងពីបញ្ហាផ្សេងៗ គឺអត់ផង។

[១០:៤១:២២]

**ស៖** តើអ្នកណាជាអ្នកឡើងនិយាយអំពីប្រធានបទ ដូចដែលលោកលើកឡើងទាំងនេះនៅក្នុងអង្គប្រជុំនោះ?

**ឆ៖** បាទ ការឡើងនិយាយគឺ អ៊ំខៀវ សំផន គាត់ឡើងនិយាយតែម្ដង ប៉ុន្តែហ្នឹងគឺមានអ្នកដឹកនាំជាច្រើននៅពីក្រោយគាត់ដូចជាមាន អ៊ំអៀង សារី, ថ្នាក់ដឹកនាំដូចជា ជួន ប្រាសិទ្ធ, ជួន មុំ អ្នកច្រើនដូចជាខ្ញុំចាំមិនអស់ រូបថតខ្ញុំមាន។ រូបថតអ៊ំ ខៀវ សំផន ឡើងនៅវេទិកាខ្ញុំមាន។ ហើយទាក់ទងនឹងការប្រជុំតិចតួច ខ្ញុំមាន ប៉ុន្តែដូចខ្ញុំបាទជម្រាបលោកព្រះរាជអាជ្ញាអន្តរជាតិអ៊ីចឹងថា អ្វីដែលខ្ញុំមានគឺអត់បានយកមក មិនពិបាកនិយាយ បង្ហាញអត់កើត វាច្រើនណាស់ដែរ មិនច្រើនណាស់ដែរ ប៉ុន្តែតិចតួចបាទតិចតួច។

**ស៖** <វានៅក្នុងសំណួរ>សួរបន្តទៀត<របស់>ខ្ញុំ។ ថាតើខ្ញុំ<យល់ត្រឹមត្រូវទេថា នៅផ្ទះ ឬក៏នៅសៀមរាប>លោក<ក៏>មាន<បណ្ដុំឯកសារ>រូបថតលោក ខៀវ សំផន ដែរ មិនអ៊ីចឹងណ៎ា?

**ឆ៖** បាទ លោកមេធាវី ខ្ញុំមានរូបថតអ៊ំ ខៀវ សំផន រហូតមកទល់ឆ្នាំ៧៩ដល់៩៥ ក៏ខ្ញុំមានច្រើនៗ ប៉ុន្តែសម័យយើង៣ឆ្នាំមានតិច។

**ស៖** លោកបានបញ្ជាក់ថា នៅក្នុងទីតាំងមួយដែលលោកបានទៅនោះ គឺនៅត្រពាំងថ្ម នៅឯពាយ័ព្យហ្នឹង ថាតើលោកទៅទំនប់ត្រពាំងថ្មហ្នឹង<>ប៉ុន្មាន<ដង>ដែរ?

[១០:៤៣:០២]

**ឆ៖** បាទ លោកព្រះរាជអាជ្ញា ខ្ញុំបាទទៅអាងត្រពាំងថ្មទៅកាលពីរៀបចំលើកទំនប់ម្ដង គេចាប់ផ្ដើមលើកហ្នឹង។ ហើយខ្ញុំទៅបានតែបីដងទេ គឺខ្ញុំទៅលើកទី៣ ខ្ញុំទៅថតកុន។ ទៅថតកុនហ្នឹងមានខាងសាធារណរដ្ឋប្រជាមានិតចិន ពីខាងស៊ីនហួរ គាត់រួមថតកុនជាមួយខ្ញុំ ហើយគាត់បានមកបង្ហាត់បង្ហាញខ្ញុំហ្នឹង គឺការថតកុនអា៣៥មិល្លីម៉ែត្រ អា១៨មិល្លីម៉ែត្រ អា១៤មិល្លី។ ការថតកុនលំបាកណាស់សម័យនុ៎ង លោកព្រះរាជអាជ្ញាដឹងហើយ គឺការធ្វើដៃទាំងអស់ នាំមើលរឿងមួយរឿង១ប្រហែលជាមួយខែពីរខែបាន១មើលបាទ។

**ស៖** តើអ្នកណាជាថ្នាក់ដឹកនាំខ្មែរក្រហម ដែលមានវត្តមាននៅក្នុងទំនប់អាងត្រពាំងថ្មនៅពេលនោះ?

**ឆ៖** បាទ ថ្នាក់ដឹកនាំពេលនោះ គឺបើនិយាយទៅមានខាង រស់ ញឹម និងគណៈភូមិភាគពាយ័ព្យ ប៉ុន្ដែគណៈតំបន់ខ្ញុំអត់ស្គាល់ឈ្មោះ។ ប៉ុន្ដែបើគណៈស្រុកខ្ញុំស្គាល់ យាយថែម១ ខ្ញុំស្គាល់គាត់។ ប៉ុន្ដែគាត់១នៅក្មេង១ ខ្ញុំមិនបាន គាត់ចាំខ្ញុំ ក៏ខ្ញុំចាំគាត់ រហូតមកទល់សព្វថ្ងៃ គាត់នៅមេឃុំត្រពាំងតៅ អន្លង់វែងហ្នឹង។ ប៉ុន្ដែមេខ្មែរក្រហមដែលទៅអមដំណើរទៅជាមួយខ្ញុំហ្នឹងមានដូចជា អ៊ំណាត, ដូចជា អ៊ំសុនសេន និយាយរួមមានជំនាញការមួយចំនួនទៀត ហើយអង្គាល់ហ្នឹងមានស្ថានទូតចិន គឺមានឯកឧត្ដមស៊ុន ហាវ អគ្គរដ្ឋទូតប្រចាំប្រទេសកម្ពុជាសម័យនោះបាទ។

[១០:៤៤:៣៧]

**ស៖** ខ្ញុំមិនច្បាស់ទេ ប្រហែលជាមានបញ្ហា<>បកប្រែភាសាអង់គ្លេស គឺគេបានបញ្ជាក់ហើយថា <ហ៊ូ នឹម> គឺជាថ្នាក់ដឹកនាំ<ម្នាក់>នៅពេលនោះ។ ថាតើលោកសំដៅលើ <ហ៊ូ នឹម ឬក៏> រស់ ញឹម ដែលជាប្រធានតំបន់ពាយ័ព្យហ្នឹង ឬមួយយ៉ាងណា?

**ឆ៖** បាទ លោកព្រះរាជអាជ្ញា រស់ ញឹម នេះបើនិយាយឲ្យចំទៅ គាត់ជាគណៈភូមិភាគពាយ័ព្យតែម្ដង គ្រប់គ្រងប្រាំ ប្រាំមួយតំបន់ តំបន់១, តំបន់២, តំបន់៥ និយាយរួមគាត់គ្រប់គ្រងមួយភូមិភាគពាយ័ព្យតែម្ដង រស់ ញឹម ហ្នឹងបាទ។ ប៉ុន្ដែខ្ញុំជាមួយគាត់ កាលឃើញ ខ្ញុំឃើញគាត់តែម្ដង ពីរដងគត់ ប៉ុន្ដែខ្ញុំមិនបានជាស្និទ្ធស្នាលជាមួយគាត់ទេបាទ។

**ស៖** លោកបានបញ្ជាក់អម្បាញ់មិញថា <អ៊ឹម> ថែម <ដែលជាមេដឹកនាំម្នាក់ដែរ>នោះ<>ក៏មានវត្តមាននៅពេលដែលលោកទៅអាងត្រពាំងថ្មនោះ។ អ៊ីចឹងខ្ញុំចង់ឲ្យលោកប្រតិកម្មពាក់ព័ន្ធទៅនឹង

ចម្លើយរបស់គាត់<ទាក់ទងនឹងអាងត្រពាំងថ្ម> ដែលក្នុងបទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាគឺ E3/5657 ហើយខ្មែរERNគឺ <00061333> , ភាសាអង់គ្លេសគឺ <00089778>, ហើយនិង <បារាំងគឺ 00347361>។ នេះគឺជាអ្វីដែលលោក អ៊ឹម ចែម បាននិយាយ៖ “សំណួរ៖ នៅក្នុងរបបនោះ នៅពេលដែលធ្វើការនៅអាងត្រពាំងថ្មនោះ តើ<អ្នកស្រីធ្លាប់ទទួលគណៈប្រតិភូណាទេ ឬក៏អ្នកនៅថ្នាក់ភូមិភាគដែលមកធ្វើទស្សនកិច្ចនៅទីនេះ>ដែរឬទេ? អ៊ីចឹងគាត់ឆ្លើយថា៖ ពួកគេបានមក ហើយខ្ញុំបានហែហមជាមួយពួកគេ។ ហើយសួរថា អ្នកណាជាថ្នាក់ដឹកនាំ? <ឆ្លើយ៖> ជនជាតិចិន ហើយនិង<ពូ> ខៀវ សំផន <ក៏>បានមកទីនេះ។ សំណួរសួរថា៖ តើលោក នួន ជា និង ប៉ុល ពត មកដែរឬទេ? ឆ្លើយ ៖ ប៉ុល ពត បានមកម្តងម្កាល ប៉ុន្តែលោក ខៀវ សំផន បានមកញឹកញាប់។ អ៊ីចឹងសំណួរ៖ ថាតើ លោក ខៀវ សំផន ហ្នឹងមកពិនិត្យទៅលើទំនប់អាងត្រពាំងថ្មហ្នឹងទេ? ឆ្លើយ៖ មែន គាត់បានមក។ ហើយសួរទៀត៖ ថាតើគាត់មានបាននិយាយអ្វីខ្លះ? <>ឆ្លើយ៖ នៅពេលដែលគាត់<ឃើញកម្លាំងមនុស្សធ្វើការ> នៅ<ទំនប់ និងនៅវាលស្រែ> គឺគាត់ជំរុញឲ្យបន្តខិតខំធ្វើការងារ<ឲ្យកាន់តែខ្លាំង>។”

តើអ្វីដែលខ្ញុំរំឭកនេះ ធ្វើឲ្យលោកចងចាំពាក់ព័ន្ធជាមួយនឹងថ្នាក់ដឹកនាំដែលចុះទៅអាងត្រពាំងថ្មហ្នឹងដែរទេ? ថាតើលោកចាំទេថា<>លោក ខៀវ សំផន ហ្នឹង<មានវត្តមាន ក្នុងដំណើររបស់លោកណាមួយ>ទៅកាន់ទំនប់ត្រពាំងថ្ម<>?

[១០:៤៧:៤៨]

**ឆ៖** បាទ លោកព្រះរាជអាជ្ញា រឿងនេះខ្ញុំបាទសូមជម្រាបថា ដូចខ្ញុំជម្រាបអ៊ីចឹងក្នុងជាងថតយើងប្រាំមួយនាក់ ជួនកាលខ្ញុំបាទមានភារកិច្ចរវល់នៅគុកទួលស្លែង ជួនកាលមានដូចជា បងនិត ដូចជាសុង គាត់ទៅម្តងម្កាលដែរ ប៉ុន្តែចំពោះខ្ញុំដើរទៅអាងត្រពាំងថ្មហ្នឹង គឺខ្ញុំទៅជាមួយ សុន សេន ទៅជាមួយ តាណាត ទៅថតកុនតែម្តង ទៅថតកុនម្តង។ បីដង ទៅបីដងអាងត្រពាំងថ្ម ប៉ុន្តែទៅចំពោះថ្នាក់ដឹកនាំដូចជា អ៊ំប៉ុល ពត, ដូចអ៊ំ ខៀវ សំផន អី ខ្ញុំអត់បានទៅជាមួយទេបាទ។

**ស៖** ឥឡូវខ្ញុំសូមសួរលោកតទៀត <លោកក៏បានបញ្ចាក់ពី>ទំនប់១មករា<ដែរ> ថាតើ<លោកចង់សំដៅទៅលើ>ទំនប់<នៅ>តាមស្ទឹងជីនិត <>នៅកំពង់ធំហ្នឹង<>ឬ<>? <តើនោះជាទំនប់ដែលលោកបានទៅមើលឬ?>

**ឆ៖** បាទ ទំនប់ហ្នឹងដូចជាមិនមែន១ ដូចជាដូច៦មករាទេ ដូចជាមិន១ ព្រោះដូច៦មករា។ ទំនប់ធំៗណាស់ម្តុំហ្នឹង ដូចជា៦មករាមួយ ទំនប់៣០កញ្ញាមួយ នៅស្រុកស្ទោង នៅក្រយា នៅស្រុក

ក្រយា-សង្គ្រាម អាហ្នឹងទំនប់ធំដែរបាទ។ នៅខេត្តកំពង់ធំ ដូចខ្ញុំដឹងគឺមានទំនប់តែពីរទេបាទ ដែលធំជាងគេ ប៉ុន្តែទំនប់ណាផ្សេងទៀត ខ្ញុំវាច្រើនពេក សម័យនោះវាលើកគ្រប់តែកន្លែង។ ប៉ុន្តែអាងធំ គម្រោងអង្គការដែលទប់ស្ទឹងជីនិតហ្នឹង គឺដូចទំនប់៦មករា ប៉ុន្តែជួនកាលគេកែលេខពីក្រោយ អាហ្នឹងខ្ញុំមិនសូវយល់ដែរបាទ។

[១០:៤៩:៣២]

**ស៖** ឥឡូវខ្ញុំសំដៅទៅលើឯកសារដែលពាក់ព័ន្ធទៅនឹងទំនប់នៅតាមស្ទឹងជីនិត <តើលោកទៅទីនោះប៉ុន្មានដង?> តើលោកចាំទេថាតើមានថ្នាក់ដឹកនាំខ្មែរក្រហមណាដែលបាន<ធ្វើដំណើរ>ជាមួយលោក<>ទៅកាន់<ទំនប់នៅ>ស្ទឹងជីនិត<>?

**ឆ៖** បាទ កាលនុំងខ្ញុំទៅជាមួយ អ៊ំប៉ុល ពត ម្តង ទៅជាមួយចិន។ ចិនគេទៅហ្នឹង គេមានខាងបច្ចេកទេស ខាងៗបច្ចេកទេសធ្វើទំនប់វារីអគ្គិសនី ទាក់ទងនឹងប្រព័ន្ធធារាសាស្ត្រហ្នឹង គឺគេទៅ បាទគឺខ្ញុំទៅជាមួយថតនៅទំនប់ស្ទឹងជីនិតហ្នឹង។ ប៉ុន្តែទៅៗមិនយូរទេ អ៊ំប៉ុល ពត គាត់ទៅប្រហែលជាៗអត់ដល់កន្លះម៉ោងផង គាត់ត្រឡប់ឡានមកវិញ ហើយបានពួកខ្ញុំនៅថតកុននុំងបាទ។

**លោក ឌេល លីសាក់៖**

លោកប្រធាន សូមការអនុញ្ញាត ខ្ញុំចង់បង្ហាញលោកសាក្សី គឺរូបថតដែលជាឯកសារ E3/3282 និងឯកសារ E3/3283 គឺដើម្បីចង់ដឹងថា តើលោកសាក្សីហ្នឹងគាត់ស្គាល់រូបថតហ្នឹងដែរឬទេ? សូមការអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ប្រសិនបើលោកមើលទៅលើរូបថតទាំងពីរនេះ លោកសាក្សី <ដំបូងបង្អស់សូមលោកប្រាប់យើងមើល៍> តើលោកស្គាល់ពីទីតាំង<នោះទេ>? ហើយទី២នោះ ថាតើ<នេះជា>រូបថតដែលលោក<>ថតដោយផ្ទាល់ដៃ ឬមួយក៏<ថតដោយ>នរណាម្នាក់ផ្សេងទេ?

**លោក ញ៉ែម អេន៖**

**ឆ៖** បាទ រូបថតនេះ ខ្ញុំថតបាទ។ រូបថតនេះ គឺនៅទំនប់៦មករា ប៉ុន្តែនៅទំនប់៣០កញ្ញាក៏ថតទំនប់យើងអាងកំពឹងពួយក៏ថត។ ប៉ុន្តែកាលនុំងដូចលោកព្រះរាជអាជ្ញាដឹងហើយ ការសម្លៀកបំពាក់

01247180



សម័យនោះ វាខ្មៅទាំងអស់ ការប្រើប្រាស់ គឺដូចគ្នាទាំងអស់។ អ៊ីចឹងថា ជួនកាលអាចភ័ន្តច្រឡំខ្លះដែរ។ ប៉ុន្តែរូបថតនេះ ពិតជាខ្ញុំថតបាទ នៅទំនប់៦មករា ស្ទឹងជីនិត។ មានច្រើនណាស់ មានរូបថតអ៊ីចឹងទៀត រូបថតប្រហែលជារាប់ពាន់សន្លឹកដែរបាទ។

**ស៖** ដើម្បី<>ប្រតិចារឹក <រូបថតដែលសាក្សីកំពុងកាន់នេះ គឺគាត់>បានបញ្ជាក់<ថា គាត់ថតដោយផ្ទាល់> គឺ<>ឯកសារ E3/3282<។> តើលោកចាំបានទេ ថា<បានអមដំណើរ>គណៈប្រតិភូស្រី<>មកពីឡាវ <និង អៀង ធីរិទ្ធ ទៅពិនិត្យមើលការដ្ឋានមួយចំនួន រួមទាំង>នៅទំនប់១មករានោះ?

[១០:៥២:៥២]

**ឆ៖** សូមជម្រាបជូនលោកព្រះរាជអាជ្ញា ខ្ញុំបាទសូមបកទៅក្រោយបន្តិច ការទំនាក់ទំនង ការថតរូបនៅសម័យនោះ គឺដូចខ្ញុំប្រាប់ជម្រាបជូនអ៊ីចឹង ដំណាក់កាលវាមានបួន មានប្រាំមួយនាក់ មានប្រាំមួយនាក់។ ជួនកាលពេលខ្លះខ្ញុំអត់បានមកដែរ ប៉ុន្តែរូបខ្លះគឺខ្ញុំស្គាល់ គឺដូចក្នុងសារព័ត៌មាន ដូចជាទាក់ទងសៀវភៅពិភពលោករាល់ថ្ងៃ គេនិពន្ធតុបតែងពីរបបខ្មែរក្រហមនេះ គឺឃើញនិយាយចាកប្រធានច្រើនណាស់លោកប្រធាន លោកព្រះរាជអាជ្ញា ប៉ុន្តែអានេះជាសិទ្ធិរបស់គេ ប៉ុន្តែរូបថតដែលការប្រើប្រាស់ គឺចាកប្រធានច្រើន ការចុះឈ្មោះ ខុស អីខុសអ៊ីចឹង ប៉ុន្តែគឺខ្ញុំថត គឺខ្ញុំថាខ្ញុំថត។ ដូច្នេះការលើកទំនប់ ជីកប្រឡាយនៅតំបន់នោះ គឺជាការពិតណាស់លោកប្រធាន អត់មាន លោកព្រះរាជអាជ្ញាអត់មានប្រែក្លាយបានទេ គឺសកម្មភាពជាក់ស្តែង ដែលប្រើពលកម្ម។ ដូចជា ឡាវមកក៏ខ្ញុំដឹង គណៈប្រតិភូថៃមកក៏ដឹង ភូមាមកក៏ដឹង ប៉ុន្តែអាចឆ្លោះខ្លះ ខ្ញុំអត់បានទៅថត ប៉ុន្តែក្រុមខ្ញុំទៅថត។

**ស៖** លោកសាក្សី គឺលោកបានបញ្ជាក់ថា គឺលោកបានអមដំណើរជាមួយគណៈប្រតិភូចិន តាមរយៈឯកសារ <E3/1339>, <E3/1339> គឺ<ជាកំណត់ហេតុដែលមានផ្ទុកនូវ>ការផ្សព្វផ្សាយតាមវិទ្យុ<របស់កម្ពុជាប្រជាធិបតេយ្យ>នៅខែធ្នូ ឆ្នាំ១៩៧៧ <នៅពេលដែល>គណៈប្រតិភូចិនដែលដឹកនាំដោយ ឆឹង យឹងគួយ បានធ្វើដំណើរទៅតាមទីតាំងការដ្ឋាន<មួយចំនួន> ជាពិសេសដូចជា ទំនប់១មករា ត្រពាំងថ្ម។ តើលោកចាំទេ ថានៅពេលនោះ លោកមានវត្តមានជាមួយនឹងថ្នាក់ដឹកនាំចិន ដែលឈ្មោះ ឆឹង យឹងគួយ <>មកទស្សនកិច្ចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ<>នេះ?

[១០:៥៤:៥៣]

**ឆ៖** បាទ លោកព្រះរាជអាជ្ញា ជាការពិត ខ្ញុំបាទបានធ្វើដំណើរទៅជាមួយឯកឧត្តម ឆឹង យឹង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គួយ។ ឆឹង យឹងគួយ នេះបើគិតទៅគាត់ជារដ្ឋមន្ត្រីកសិកម្មនៅប្រទេសចិន ជារដ្ឋមន្ត្រីមួយដែលពូកែដាំស្រូវលើភ្នំបានរាប់តោនក្នុងមួយហិកតា។ អ៊ីចឹងថាខ្ញុំបានទៅធ្វើដំណើរជាមួយ តាម៉ុក, ជាមួយអ៊ំអៀង សារី, ជាមួយ ប៉ុល ពត – អ៊ំប៉ុល ពត បីនាក់ ដែលធ្វើដំណើរទៅមានបញ្ចាកងទ័ពមួយចំនួន ហើយក៏មានស្ថានទូតចិន និងអ្នកអមដំណើរហ្នឹង គឺខ្ញុំរូបថតខ្ញុំមាន ប៉ុន្តែថ្ងៃនេះដូចជាខ្ញុំអត់បានយកមកបាទរូបថត។ ខ្ញុំមានរូបថតមួយសន្លឹកដែលថតអនុស្សាវរីយ៍នៅរាល់ថ្ងៃនេះគឺ ប្រៀបធៀបទៅថ្ងៃនេះដើមត្នោតបាត់អស់ប្អូនដប់ដើមហើយ សល់តែពីរដើមទេ ប៉ុន្តែខ្ញុំមានរូបថត ប៉ុន្តែខ្ញុំអត់បានយកមក។ ហើយសូមជម្រាបលោកព្រះរាជអាជ្ញាផងដែរថា ការធ្វើដំណើរនេះគឺអត់ៗចូលឃ្ញុំរទេបាទ ចូលតែមួយភ្លែតៗទេ ប៉ុន្តែនៅអង្គរវត្តបានយូរ នៅអង្គរវត្តបានយូរតិច។ កាលហ្នឹងឯកឧត្តមគាត់ ឆឹង យឹងគួយ ហ្នឹង គាត់ចង់មកទស្សនៈនៅប្រទេសកម្ពុជា ដើម្បីមើលតំបន់កសិកម្មប្រទេសកម្ពុជាដែលទើបក្រោកពីសង្គ្រាមចក្រពត្តិអាមេរិកាំងហើយគឺៗ មានបាទ។

**ស៖** អរគុណលោកសាក្សី។ តើលោកមានបន្តធ្វើដំណើរទៅភូមិភាគ<បូព៌ា>ជាមួយនឹង ប៉ុល ពត <ឬ> នួន ជា ដែរឬទេ? <បើធ្លាប់ តើលោកបានទៅកន្លែងណា>?

**ឆ៖** បាទ លោកព្រះរាជអាជ្ញា។ ភូមិភាគបូព៌ា ខ្ញុំអត់បានដែលបានទៅជាមួយគាត់ទេ ប៉ុន្តែបើទៅភូមិភាគពាយ័ព្យខ្ញុំទៅជាមួយគាត់ ទៅជាមួយអ៊ំប៉ុល ពត ទៅដល់ភ្នំវាយចាប ទៅបេះកប្បាស ជាមួយគាត់ហ្នឹង។ បើទៅភូមិភាគបូព៌ា ខ្ញុំអត់ដែលបានទៅជាមួយផង។

[១០:៥៦:៥១]

**ស៖** លោកបានឆ្លើយនៅក្នុងកិច្ចសម្ភាសន៍របស់លោក ថាលោកក៏បានថតរូបមេដឹកនាំខ្មែរក្រហមនៅក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំ <ប្រជុំសភា> កិច្ចប្រជុំជាមួយនឹងកងទ័ព <>ដែល<>មានការថ្លែងសុន្ទរកថា<>។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ការជួបប្រជុំដែលលោកបានថតរូបមេដឹកនាំខ្មែរក្រហមជាមួយកងទ័ពហ្នឹង ប្រជុំនៅកន្លែងណាដែរ?

**ឆ៖** បាទ ការថតរូបមេៗខ្មែរក្រហមដឹកនាំហ្នឹង ដូចជាមានអ៊ំ នួន ជា រដ្ឋសភា, អ៊ំ ប៉ុល ពត រដ្ឋមន្ត្រីទី១ និងគណៈប្រតិភូរដ្ឋមន្ត្រីជាច្រើនរូបទៀត ដែលនៅក្នុងការប្រជុំនៅមហោស្រពយើងនៅជិតមាត់ទន្លេរាល់ថ្ងៃ។ ហើយទី២ទៀត នៅបុរី នៅកីឡាដ្ឋានកន្លែងបញ្ចាំងកុននៅយើងផ្សារដើមគ។ បាទប្រជុំគឺមានពីរកន្លែងហ្នឹងដែលឃើញប្រជុំ។ បើទាក់ទងប្រជុំកងទ័ព បើបញ្ហាព្រំដែនដែលវៀតណាមវាយសម្រុកចូលឆ្នាំ១០៧៦, ៧៧, ៧៨ នេះគឺគេប្រជុំតែ ជាសំខាន់គេប្រជុំនៅកន្លែង។ ជាពិសេសនេះ

ទៀតគឺថ្ងៃ៣០ កញ្ញា ឆ្នាំ១៩៧៧ ដែលបក្សកុម្មុយនីស្តកម្ពុជាប្រកាសចេញជាជំហរ គឺថតជាច្រើនសន្លឹក ក្រៅពី ប៉ុល ពត ប្រកាសបក្សកុម្មុយនីស្តកម្ពុជាចេញជាជំហរហើយ គឺខ្ញុំបានចូលរួមថតជាច្រើន។ គាត់ទៅចិន គាត់ទៅកូរ៉េខាងជើង គាត់ទៅយូហ្គោស្លាវី រ៉ូម៉ានី គឺច្រើនបាទ។ ដូច្នេះខ្ញុំសូមប្រាប់លោកព្រះរាជអាជ្ញាអន្តរជាតិថា អ្វីដែលជាកាតព្វកិច្ចរបស់ខ្ញុំ គឺមានច្រើន ទុកអ្នកណា ថាខ្ញុំមិនបានដឹងឮ ព្រោះខ្ញុំវ័យ ១៧, ១៨ ខ្ញុំដឹងច្បាស់ណាស់បាទ។

**ប្រធានអង្គជំនុំ៖**

សាក្សី ទី១ សូមរំឭកឡើងវិញ សុំឲ្យនិយាយឲ្យយឺត ពីព្រោះនិយាយយឺតបាទ។ ហើយបញ្ហាទី២ សុំឲ្យឆ្លើយនូវភាពចាំបាច់តបទៅនឹងសំណួរបានហើយណ៎ា។ លោកនិយាយច្រើនទៅ ជួនកាលវាអត់មានចំសម្រេចគោលបំណង គោលដៅនៃការសួរដេញដោលតាមផ្លូវតុលាការ។

[១០:៥៩:00]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សីតើលោកនៅចាំទេថា មានកិច្ចប្រជុំមួយលោកបានថតរូប<នោះ> តើវាជា<កិច្ច>ប្រជុំ<ប្រចាំឆ្នាំ ឬក៏ជា>សន្និបាត<ខួបកំណើត>កងទ័ពបដិវត្តន៍កម្ពុជាដែលគេប្រជុំរៀងរាល់<ឆ្នាំក្នុង>ខែមករា<>?

**លោក ញ៉ែម អេន៖**

**ឆ៖** បាទ ខ្ញុំបានថតជាច្រើនសន្លឹកដែរបាទថត ដូចជាឲ្យ សំខាន់ ឲ្យប្រជុំសំខាន់ ខ្ញុំបាទទៅថតជាច្រើនកន្លែង សំខាន់ប្រជុំសភា ប៉ុន្តែសភាសម័យនោះគឺ សូមជម្រាបលោកព្រះរាជអាជ្ញាថាវាតិចណាស់ ពេលវេលា ប៉ុន្តែដូចថាមានតែក្រដាស។ មានតែក្រដាសអ៊ីចឹងទៅ ការប្រជុំវាតិច សំខាន់គឺផ្តោតទៅលើបញ្ហាព្រំដែនវៀតណាមតែម្តង។

**ស៖** មានកំណត់ត្រា និងភស្តុតាងស្តីអំពីការផ្សាយតាមវិទ្យុផ្សាយសំឡេងកម្ពុជាប្រជាធិបតេយ្យនូវសុន្ទរកថាដែលថ្លែងដោយ នួន ជា អំពីខួបកងទ័ពបដិវត្តន៍កម្ពុជាលើកទី៩ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ៧៧។ នេះគឺឯកសារ E3/147 ERN ជាភាសាខ្មែរ 00679792 ដល់802, អង់គ្លេស 00168465 ដល់<470> ហើយបារាំង <00698444> ដល់50។ សំណួររបស់ខ្ញុំសួរថាតើលោកនៅចាំថា នួន ជា មានបានថ្លែងសុន្ទរកថានៅឯខួបកងទ័ពបដិវត្តន៍កម្ពុជានោះដែរឬទេ? ហើយលោកនៅចាំថាលោកមានបានថតរូបនៅក្នុងអង្គប្រជុំមួយនេះដែរទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១១:០១:២០]

**ឆ៖** បាទ ព្រះរាជអាជ្ញា ខ្ញុំបាទកាលហ្នឹងប្រជុំនៅបុរីកីឡាបាទ។ បុរីកីឡាហ្នឹងគឺកងទ័ពចូលរួមច្រើនណាស់បាទចូលរួម និយាយរួមកងទ័ព ដូចជាខ្ញុំចាំមិនច្បាស់ ដូចជា១០កងពលជាង បាទមកប្រជុំនៅស្តាតអូឡាំពិកទាំងអស់។ មានការថ្លែងសុន្ទរកថារបស់អ៊ំនួន ជា, របស់អ៊ំប៉ុល ពត នៅទីនោះ ហើយក៏មានអ៊ំសុន សេន ដែរបាទ។ ហើយការច្រៀងភ្លេងជាតិ ឈាមក្រហមឆ្អៅហ្នឹងគឺឲ្យច្រៀងទាំងអស់គ្នាតែម្តងនៅក្នុង ខ្ញុំបាទខ្ញុំចាំអត់ភ្លេចទេបាទ គឺមែនបាទមានការប្រជុំចូលរួមមែន។

**ស៖** មុននឹងខ្ញុំចូលទៅដល់ប្រធានបទបន្ទាប់មកទៀត គឺប្រធានបទដែលលោកធ្វើការនៅឯ ស-២១ នៅពេលដែលលោកមានវត្តមាននៅក្នុងកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំខ្មែរក្រហម ហើយដែលលោកថតរូបនុ៎ង តើលោកធ្លាប់ដែលបានស្តាប់ឮអំពីការបោសសម្អាតខ្មាំងដែរទេ? តើលោក<>បានឮ<អ្វីដែល>ថ្នាក់ដឹកនាំខ្មែរក្រហមនិយាយអំពីការបោសសម្អាត<>នៅក្នុងកិច្ចប្រជុំទាំងនុ៎ង?

**ឆ៖** បាទ អរគុណណាស់។ សំណួរនេះជាសំខាន់បំផុតសម្រាប់ជីវិតខ្ញុំបាទ ក៏ដូចជាសម្រាប់ជីវិតជនរួមជាតិ ក្រោយពីគាត់រលត់ជីវិតអស់ទៅ ការពិត ទី១ គ្រោងការអង្គការគឺទី១ កម្ចាត់ភ្នាក់ងារសេ.អ៊ី.អា។ បាទ សេ.អ៊ី.អា ហ្នឹងអស់លោកដឹងហើយថាជាភ្នាក់ងាររបស់អាមេរិកាំង។ ទី២ កម្ចាត់ភ្នាក់ងារ កា.ហ្សេ.បេ ភ្នាក់ងាររបស់សូវៀត។ ទី៣ទៀត គឺភ្នាក់ងារយួនលេបទឹកដី។ បាទគឺបីហ្នឹងគឺផ្តោតសំខាន់ទៀតគឺកម្ចាត់ខ្មាំងបង្កប់។ ខ្មាំងបង្កប់ហ្នឹង លោកព្រះរាជអាជ្ញាដឹងហើយថាសម័យនោះគឺជាសម័យមួយអាណាធិបតេយ្យ ដូចថាគ្មានតុលាការ គ្មានមេធាវី គ្មានអ្នកកាសែតអីចឹងទៅ ការចាប់ និងសម្លាប់ យើងថាការពិត បាទអានេះខ្ញុំនិយាយការពិតមែន គឺផែនការអង្គការគឺកម្ចាត់ជាមូលដ្ឋាន។ ដូច្នេះក្រោយពីប្រទេសជាតិរំដោះហើយ ១៧ មេសានេះ គឺមែនជាការពិតមែន ខ្ញុំបានស្តាប់គោលការណ៍របស់អង្គការ គឺច្បាស់ណាស់ ប៉ុល ពត និយាយច្បាស់តែម្តង គឺកម្ចាត់ខ្មាំងសត្រូវ ភ្នាក់ងារទាំងបីហ្នឹងបាទ។

[១១:០៣:៣៥]

**ស៖** តើលោកបានស្តាប់ឮ ប៉ុល ពត និយាយអំពីរឿងនេះមែនឬ? ហើយបើសិនណាជាស្តាប់បានឮមែនហ្នឹង តើ<ក្នុងឱកាសណាដែល>លោកស្តាប់<>ឮ <ប៉ុល ពត> និយាយ<>អំពីការបោសសម្អាតនេះ<>?

**ឆ៖** បាទ នៅឆ្នាំ១៩៧៧ ក៏និយាយ នៅឆ្នាំ១០៧៨*(ស៊ីក)* និយាយនៅទីប្រជុំជន គឺកន្លែងស្តាតអូឡាំពិកហ្នឹងតែម្តង ហើយសំខាន់បំផុតគឺតាមវិទ្យុបាទ។ គាត់ចាក់មួយថ្ងៃៗគឺៗនិយាយតែអារឿងហ្នឹង

តែម្តងបាទ។

**ស៖** នៅពេលដែលមានការបោសសម្អាតតាមបណ្តាភូមិភាគផ្សេងៗ តើ<>លោកដឹង<ទេ ថា >គេបញ្ជូន<អ្នកណាឲ្យទៅជំនួស>កម្មាភិបាល<>ដែលគេបោសសម្អាតនោះ?

**ឆ៖** បាទ លោកព្រះរាជអាជ្ញា ខ្ញុំយល់ច្បាស់ណាស់សំណួរនេះ។ ក្រោយពីការបោសសម្អាត ដែលថាភ្នាក់ងារខ្មាំងនៅតាមតំបន់ទូទាំងប្រទេសកម្ពុជា ភាគច្រើនគឺយកពីតំបន់ភូមិភាគនិរតី។ ភូមិភាគនិរតីនេះ គឺទៅគ្របដណ្តប់នៅប្រទេសកម្ពុជាទាំងមូល គឺភាគច្រើនគឺយកមកពីភូមិភាគនិរតីទាំងអស់ ទៅធ្វើជាគណៈស្រុក ធ្វើជាគណៈតំបន់ កងទ័ព។ ហើយសំខាន់បំផុត គេបំបែកជាកងពលមួយទៀត កងពល៧០៣ នេះគឺគេយកទៅគ្រប់ដណ្តប់ទូទាំងប្រទេសតែម្តង។ ហើយគេចាប់មកគឺគេបញ្ជូនអ្នកថ្មីចូលទៅទាំងអស់ ភាគច្រើនគឺអ្នកថ្មីបាទ។ សំខាន់គេយកពីភូមិភាគនិរតីតែម្តង គឺក្រោមបទបញ្ជារបស់ តាម៉ុក បាទ តាម៉ុក និង ប៉ុល ពត, អៀង សារី ហ្នឹងគឺគាត់រួមគ្នាបីនាក់ បួននឹង អ៊ំនួន ជា ហ្នឹងបាទ។ តែបីបួននាក់ហ្នឹងឯងបាទ។ ដកតែ អ៊ំខៀវ សំផន មួយទេ ខ្ញុំមិនកាន់ជើងគាត់ទេ ប៉ុន្តែនិយាយមុខសវនាការ បីបួននាក់ គឺគាត់សហការគ្នា គឺច្បាស់ណាស់ បាទច្បាស់តែម្តង។ ជាពិសេស សុន សេន តែម្តង គាត់កាន់ផ្នែកសន្តិសុខជាតិ ផ្នែកយោធា។

[១១:០៥:៤៨]

**ស៖** ខ្ញុំសុំសួរលោកអំពីសេចក្តីថ្លែងការណ៍នៅក្នុងកិច្ចសម្ភាសន៍មួយដែល<>លោក<បានធ្វើនៅក្នុងឆ្នាំ១៩៩៧> គឺឯកសារ E3/7495 – E3/7495, ERNជាភាសាខ្មែរ 00826562, អង់គ្លេស 00078259, បារាំង 00795353។ នេះគឺអ្វីដែលលោកបានឆ្លើយពាក់ព័ន្ធទៅនឹងការបោសសម្អាត សុំដកស្រង់៖ “ក្រោយពីរយៈពេលប្រហែលជាពីរឆ្នាំ ឬប្រហាក់ប្រហែលហ្នឹងមក ខ្ញុំបានកត់សម្គាល់ថា អ្វីៗដែលខ្មែរក្រហមបានធ្វើ គឺធ្វើតាមរយៈអំពើហិង្សា ភាពឃោរឃៅ និងភាពផ្តាច់ការ។ ខ្ញុំមានអារម្មណ៍ខុសពីនោះ ដោយសារថា ខ្ញុំឃើញ<អ្វីដែល>ពួកគេ<>ធ្វើ<គឺ>ផ្តាច់ការ ឃោរឃៅ <យុត្តិធម៌ដោយសង្ខេប ពួកគេមិនបានធ្វើការស៊ើបអង្កេតមុនពេលសម្លាប់មនុស្ស>។ ទោះបីកំហុសធំ កំហុសតូចក៏ដោយ គឺថាគ្រប់គ្រាន់សម្រាប់ចាប់ខ្លួនហើយ។ ទោះបីជាគេមិនបានក្បត់ប្រទេសជាតិក៏ដោយ ក៏ត្រូវបានគេចោទប្រកាន់ ហើយនិងត្រូវបានគេចាប់ខ្លួនដែរ។” បញ្ចប់ការដកស្រង់។ លោក<បាននិយាយ>ថា <ឮបញ្ហាទាំងអស់នេះ បានធ្វើដោយ “យុត្តិធម៌ដោយសង្ខេប”។ តើ>លោក<អាច >ពន្យល់<បានទេ តើលោកចង់និយាយថាម៉េច > “យុត្តិធម៌<ដោយសង្ខេប” នោះ>?

**ឆ៖** បាទ លោកព្រះរាជអាជ្ញា លោកប្រធាន សំណួរនេះ បើខ្ញុំអត្ថាធិប្បាយ ចង់មួយម៉ោងក៏មិនអស់ផង។ ប៉ុន្តែដូចទាក់ទងការបោសសម្អាត ខ្ញុំសូមជម្រាបលោកប្រធានថា -- លោកព្រះរាជអាជ្ញាថា សម័យនោះ ខ្ញុំដូចជាបកទៅក្រោយវិញបន្តិច ការបទបញ្ហា មានតែបីប្អូននាក់ទេ។ ទី១ អ៊ំប៉ុល ពត បន្ទាប់មក អ៊ំនួន ជា និង សុន សេន។ អ៊ីចឹងថា ខ្ញុំសូមជម្រាបថា ការបោសសម្អាតសម័យនោះគឺវាអយុត្តិធម៌ណាស់សម្រាប់អ្នករងគ្រោះបាទ។ ខ្ញុំនិយាយបកទៅក្រោយ ដូចជាទួលស្លែងអ៊ីចឹងបាទ។ ទួលស្លែងសម្លាប់រាប់ម៉ឺននាក់នេះ អ្នកខុសប្រហែលជា១០០នាក់ចុះ ដែលចាប់ៗ។ ក្រៅពីហ្នឹងគឺដោយសារតែការវាយដំ ច្រំធាក់ ឆក់ខ្សែភ្លើង វាយឃើពេក អ៊ីចឹងឆ្លើយទៅ ឲ្យតែរួចខ្លួន ឲ្យបានតែរស់ មិនណាំយកទៅវ៉ៃចោលទៀត។ អ៊ីចឹងថា នេះវាជាភាពមួយអយុត្តិធម៌ណាស់ សម្រាប់ប្រជាជនកម្ពុជាសម័យនោះ គឺខ្ញុំ សូម្បីតែបងខ្ញុំបង្កើត ក៏គេសម្លាប់ចោលមួយដែរ។ ហើយបងប្អូនខ្ញុំ២៥នាក់ សម័យនោះស្លាប់ដូចគ្នាហៅថាប្រជាជន១៧ថ្មីហ្នឹង។ បងខ្ញុំបង្កើតម្នាក់ទៀត ស្លាប់នៅកោះកុង។ គេបាញ់ចោលនៅនាវាសមុទ្រ គឺបងខ្ញុំបង្កើតតែម្តង។ គាត់ជាបញ្ជាការកងទ័ព ក៏ដូចគ្នា។ អ៊ីចឹងបងខ្ញុំនេះ រូបថត ខ្ញុំយកមក ខ្ញុំសុំលោកចៅក្រមបង្ហាញតិចបានទេ ខ្ញុំមានរូបថតមួយសន្លឹកបងខ្ញុំបង្កើតគេបាញ់ចោលនៅកោះកុងបាទ? អ៊ីចឹងច្រើនណាស់ លោកព្រះរាជអាជ្ញា ខ្ញុំពណ៌នាមិនអស់ទេរឿងនេះ វាអយុត្តិធម៌ណាស់សម្រាប់ប្រជាជនកម្ពុជាសម្រាប់ថ្នាក់ដឹកនាំសម័យនោះបាទ។

[១១:០៨:៤៣]

**ស៖** ឥឡូវនេះខ្ញុំចូលសួរពេលវេលារបស់លោក ដែលលោកធ្វើ<ជាអ្នកថតរូប>នៅមន្ទីរសន្តិសុខ ស-២១។ បញ្ហាដំបូងដែលខ្ញុំត្រូវសួរលោកនោះ តើលោកហើយនិងអ្នកថតរូបទាំងអស់ហ្នឹង ថតរូបអ្នកទោសនៅឯណា នៅពេលអ្នកមកដល់ហ្នឹង? តើថតនៅ<ក្នុង>បរិវេណ<ស-២១> ឬនៅ<ក្រៅបរិវេណ>មុនពេលគេចូលមកដល់ <តើលោកអាចរៀបរាប់>ជូនតុលាការ<ឲ្យច្បាស់បានទេ តើ>លោកថតរូប<នៅកន្លែងណា>?

**ឆ៖** សូមជម្រាបលោកព្រះរាជអាជ្ញា លោកប្រធានចៅក្រម និងតុលាការទាំងអស់ សូមជម្រាបថា ការថតរូបហ្នឹងមានពីរផ្នែក។ ទី១ កាលនុ៎ងឡានគេច្រើនដាក់ ជួនកាលឡានដឹកអ្នកទោសមកភាគច្រើន គេដាក់សញ្ញាពេទ្យ សញ្ញាពេទ្យមក យកអ្នកចុះពីឡានអឹម.ហ្សេ.អឹម.សេ មកសុទ្ធតែអ្នកទោសទាំងអស់ ហើយគេចង គេចងដៃ គេចងមុខទៀត ដៃដាក់ខ្នោះ។ ដល់អ៊ីចឹងទៅ បរិវេណថត មានកន្លែងនៅនឹងក្រៅបរិវេណហ្នឹង នៅមុខទួលស្លែងហ្នឹងពីរកន្លែងថត។ ដល់ថតហើយ ពេលដែលអ្នក

ទោសចុះពីលើឡានថត។ ថតហើយ ស្រាយៗមុខហើយថត ថតខាងក្រៅ។ ដល់ថតហើយ បានបញ្ជូនអ្នកទោសចូលក្នុង។ ជួនកាលអ្នកទោសមកច្រើនពេក យកអ្នកទោសហ្នឹងទៅដាក់តាមអគារ“អា”, អគារ “បេ”, អគារ “សេ” ហ្នឹងទៅ ក៏ចាប់ផ្ដើមពួកខ្ញុំទៅថត ដូចក្នុងរូបថតមួយចំនួន លោកព្រះរាជអាជ្ញាឃើញហើយ មានជាប់គ្នាទាំងរនងៗៗហ្នឹង បានន័យថា អ្នកទោសវាចូលច្រើនពេក ថតអត់ទាន់។ អ៊ីចឹងថា ការថតហ្នឹងមានពីរគន្លាក់ ថតនៅទូលស្លែង ថតនៅក្រៅបរិវេណទួលស្លែងផង ថតនៅទួលស្លែងផង ហើយថតនៅក្នុងគុកទួលស្លែង នៅក្នុងអគារដែលគាត់សម្រាកហ្នឹង ដែលអ្នកទោសធ្ងន់បាទ។

[១១:១០:៤០]

**ស៖** ខ្ញុំសូមបង្ហាញរូបថតពីរបីសន្លឹកឲ្យលោកមើល ចង់ដឹងថាតើលោក<ស្គាល់>ទីតាំង<ឬអាចប្រាប់ទីតាំងនោះបានទេ>។ លោកប្រធាន ឯកសារទី១ដែលខ្ញុំស្នើសុំនេះ<> គឺឯកសារ E394.1 ត្រង់ទំព័រ P01223690 ដល់ 92 <ដែលជាផ្នែកនៃបណ្ដុំរូបថត១.០០០ ដែលទើបតែបន្ថែមថ្មីៗនេះដោយ>មជ្ឈមណ្ឌលឯកសារកម្ពុជា។ បើអង្គជំនុំជម្រះអនុញ្ញាត សូមបង្ហាញឯកសារនេះជូនទៅសាក្សីមើល។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំយោងទៅរូបថត<មួយចំនួន។> រូបថតនៅក្នុងបណ្ដុំរូបថតដែលបានផ្ដល់ជូនតុលាការដោយមជ្ឈមណ្ឌលឯកសារកម្ពុជា<>មានលេខបង់<នៅលើនោះ>រួចស្រេចមកហើយ <គឺខុសពីលេខ>ដែល<បានប្រើនៅលើរូបថត>ដែលលោកថតនុ៎ង។ អ៊ីចឹង<ជាបឋម>ខ្ញុំសូមបង្ហាញលោក<មើលលេខដែល>មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង់<លើឯកសារ>នោះ។ <សូមលោកមើលទៅ>រូបថតលេខ៣, លេខ១០, លេខ១៣, លេខ១៤, លេខ១៨ និងរូបថតលេខ<២៤> នៅលើឯកសារពីរទំព័រនេះ។ <អ្វីដែលរូបថតទាំងអស់នេះមានដូចគ្នានោះ គឺផ្ទៃខាងក្រោយនៃរូបថតនេះ>គឺយើងឃើញថា រូបថតនេះ ហាក់បីដូចជាមានៗវាឃើញថតទៅ ឃើញមានជញ្ជាំង បាំងជាប់នឹងជញ្ជាំង។ សំណួររបស់ខ្ញុំ តើលោកស្គាល់ ឬក៏នៅចាំបានទេថា រូបថតនេះ ថតនៅទីតាំងកន្លែងណាដែរ បើធៀបទៅនឹងបរិវេណនៃមន្ទីរសន្តិសុខស-២១?

**លោក ញ៉ែម អេន៖**

**ឆ៖** បាទ លោកព្រះរាជអាជ្ញា ខ្ញុំសូមភារៈជូនលោកប្រធាន ព្រះរាជអាជ្ញា។ វាទាក់ទងករណីរូបនេះ រូបថតនេះ ជួនកាលសម័យនោះ មិនពិបាកធ្វើអីស្អាតទេ ថតតែជញ្ជាំង អាកន្លែង ថតនឹងជញ្ជាំងគេយកជញ្ជាំងយើងផ្ទះថ្មហ្នឹងក៏បានដែរ ទី១។ ទី២ទៀត ដែលមានថតដូចជាមានទ្វារនេះ គឺអ្នកទោសដែលគាត់បញ្ជូនដល់គុកទួលស្លែង ហើយក្នុងគុក អត់បានថតខាងក្រៅ គឺមកថតនៅនឹងក្នុងគុកតែម្តង។ ជួនកាលនៅក្នុងបរិវេណដែលខ្ញុំថតហ្នឹង គឺមាន ១ប៉ាណូមួយ មានផ្ទាំងមួយ មានផ្ទាំងមួយថតហ្នឹង។ អ៊ីចឹងថាជាការត្រឹមត្រូវ ជួនកាលអ្នកទោសមកច្រើនពេក ហៅអ្នកទោសមកថតខាងក្នុងក៏មានបាទ។ ជាការត្រឹមត្រូវ រូបថត។ ហើយការដាក់លេខ ការដាក់លេខ ខ្ញុំសូមជូនជម្រាបជូនព្រះរាជអាជ្ញាអន្តរជាតិ ជាតិថា កុំច្រឡំថា រូបថតដែលដាក់លេខហ្នឹង គឺកំណត់ថ្ងៃបាទ។

[១១:១៣:៤៨]

**ស៖** ខ្ញុំនឹងសួរអំពីរបៀបដែលលោកបង់លេខរៀងរូបថតអ្នកទោសនៅពេលក្រោយនេះ។ នៅខាងក្រោយរូបថតនេះ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ជូនមកតុលាការ។ ជាពិសេសសំដៅទៅលើរូបថតដែលនៅក្នុងឆ្នាំ៧៦ និង៧៧ មានអក្សរសរសេរដោយដៃនៅខាងក្រោយរូបថតទាំងនេះ។ តើលោក<>ស្គាល់អក្សរនេះទេ អ្នកណាជាអ្នកសរសេរអក្សរនេះ? <តើលោកអាចប្រាប់បានទេ ថាតើ>អក្សរសរសេរដោយដៃនេះ <ដែលមាន>សរសេរឈ្មោះអ្នកទោស និងថ្ងៃខែ<ថតរូបនោះ គឺសរសេរដោយក្រុមរបស់លោក ឬក៏ព័ត៌មានទាំងអស់នេះសរសេរបញ្ចូលបន្ថែមនៅពេលក្រោយ គឺក្រោយពេលលោកប្រគល់រូបថតថតចម្លងរួចហើយ>?

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនព្រះរាជអាជ្ញាថា អក្សរនេះគឺអក្សរ តាស្រ៊ាង។ នៅនុ៎ងគឺអក្សរស្អាតមានតែបីនាក់ទេ មានតាស្រ៊ាង, តាសុង, តានិត។ ហើយខ្ញុំកាលនុ៎ង អក្សរអត់សូវស្អាត សឹងរាល់ថ្ងៃអក្សរមិនសូវស្អាតទេបាទ គឺមាន តាស្រ៊ាង គាត់ប៉ិនសរសេរកាលនោះបាទ។

**ស៖** សូមលោកជម្រាបជូនតុលាការមើល ស្រ៊ាង នេះជាអ្នកណា?

**ឆ៖** ក្នុងហ្នឹងគឺគាត់ឈ្មោះ ក្នុងសៀវភៅឈ្មោះដើមគាត់មាន ប៉ុន្តែឈ្មោះក្រោយ ឈ្មោះបដិវត្តន៍ឈ្មោះ ស្រ៊ាង ខ្ញុំហៅតែ ស្រ៊ាង ទេ។ គាត់អត់មានអីប្រែប្រួលទេបាទ។ ឈ្មោះបដិវត្តន៍ឈ្មោះ ស្រ៊ាង គាត់ជាប្រធានក្រុមជាងថតជាមួយខ្ញុំដែរ ការគ្រប់គ្រងនៅកន្លែងជាងថត។

[១១:១៥:៣៨]

01247188



**ស៖** សូមអរគុណ។ ក្រោយលោកផ្តិតរូបថតហើយ ហើយសរសេរព័ត៌មាននៅខាងក្រោយនេះ <តើបន្ទាប់មកគេធ្វើយ៉ាងម៉េចទៀត?> តើលោកបញ្ជូនរូបថតនេះ ទៅឱ្យអ្នកណា?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោក ញ៉ែម អែន៖**

**ឆ៖** បាទ លោកព្រះរាជអាជ្ញា ទាក់ទងនឹងបញ្ហានេះ ការសរសេរនេះ ជួនកាលគេសរសេរដាក់ក្រដាសសៀវភៅទេ ជួនកាលក្នុងរូបថតហ្នឹងសរសេរតិចណាស់ ក៏ប៉ុន្តែការបញ្ជូនរូបថតនេះ គឺអ្នកណាថត អ្នកហ្នឹងបញ្ជូនទៅឱ្យ សួស ធី។ បាទ សួស ធីៗ ហ្នឹងគេគាត់ទទួលផ្នែករដ្ឋបាល ផ្នែកអ្នកទោសចេញ អ្នកទោសចូល អ្នកទោសប៉ុន្មានៗ គឺលើគាត់ទាំងអស់។ គឺពួកខ្ញុំអ្នកបញ្ជូនរូបថតទៅឱ្យគាត់តែម្តងបាទ។ ប៉ុន្តែរូបថតសំខាន់ៗមួយចំនួនទៀត ដូចជាថ្នាក់ដឹកនាំធំៗ គឺបញ្ជូនទៅឱ្យ តាឌុច ខុសគ្នា ផ្នែកពីរនេះខុសគ្នាបាទ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ហើយអ្នកណាៗ ជាអ្នកយករូបថតហ្នឹងទៅឱ្យ សួស ធី ក្តី ទៅឱ្យ ឌុច ក្តី អ៊ីចឹងអ្នកណាដែលជាអ្នកកាន់រូបថតនោះទៅឱ្យ?

[១១:១៦:៥៤]

**ឆ៖** លោកព្រះរាជអាជ្ញា ជួនកាលខ្ញុំ ជួនកាលខាងលោក ស្រ៊ាង ព្រោះការថតរូបដូចខ្ញុំជម្រាបលោកព្រះរាជអាជ្ញាអ៊ីចឹង ការថតរូបមានគ្នាប្រាំមួយនាក់។ ដូច្នេះកាតព្វកិច្ចម្នាក់ៗគឺរៀងខ្លួន។ បាទ អត់មានអ្នកណា ការងារគេ គេដឹង ការងារយើង យើងដឹង អ្នកណាធ្វើមិនល្អ ទទួលខុសត្រូវខ្លួនឯង។

**ស៖** តើលោកអាចជម្រាបជូនតុលាការអំពីការមកដល់នៃអ្នកទោសនេះបានទេ? តើធ្វើម៉េចបានលោកដឹងថា អ្នកទោសមកដល់ ហើយត្រូវទៅថតរូប? ហើយនៅពេលដែលអ្នកទោសមកដល់ហ្នឹង តើអ្នកទោសត្រូវបានគេចងដៃ ឬក៏គេបិទមុខអីដែរទេ? <តើស្ថានភាពអ្នកទោសយ៉ាងម៉េចដែរ នៅពេលគេយកអ្នកទាំងនោះទៅឱ្យលោកថតរូបនោះ?>

**ឆ៖** បាទ លោកព្រះរាជអាជ្ញា។ ការអ្នកទោសចូលដល់នេះ ខ្ញុំបាទ សម័យនោះគឺដូចជាទំនើបដែរ លោកព្រះរាជអាជ្ញា លោកប្រធានតុលាការ ខ្ញុំមានទូរស័ព្ទគ្រប់បន្ទប់បាទ ហើយកន្លែងខ្ញុំមានទូរស័ព្ទគឺមួយទូលស្តែងហ្នឹង មានទូរស័ព្ទទាំងអស់គ្រប់កន្លែងធ្វើការ ព្រោះពេលមានអ្នកទោសចូលមក គេ*តេ*

រ៉ឺង ទូរស័ព្ទរបស់សូវៀតហ្នឹង ខ្ញុំមកដល់ភ្លាម។ ជួនកាលអ្នកទោសដែលធ្វើដំណើរមកដល់ហ្នឹង ដូចព្រះរាជអាជ្ញាសួរខ្ញុំអ៊ីចឹង មួយរយភាគរយគឺចង ចងដៃត្រូវដាក់ខ្នោះ និងចងមុខ។ ទុកតែស្រីៗ ក៏ដាក់ខ្នោះចងដៃ និងចងមុខដូចគ្នា គឺអត់មានអ្នកណាក៏អត់ចង។ ពេលចូលមកដល់ចងមុខហើយ ស្រាយមុខហើយថត ថតហើយ ចងមុខបញ្ជូនទៅក្នុងគុកទួលស្លែងតែម្តង។

**ស៖** អ្នកណាជាអ្នកដោះខ្នោះដៃ និងដោះរបាំងមុខហ្នឹងចេញ? <តើ>អ្នកថតរូប ជាអ្នកដោះខ្នោះដៃ <និង>ជាអ្នកស្រាយមុខហ្នឹង ឬក៏ឆ្មាំគុកទេ ដែលជាអ្នកធ្វើការនេះ?

[១១:១៨:៥១]

**ឆ៖** បាទ សូមជម្រាបជូនលោកព្រះរាជអាជ្ញាថា ការដោះមុខនេះ គឺមិនមែនខ្ញុំបាទអ្នកដោះទេ គឺឆ្មាំគុក ឬក៏អ្នកយាមតែម្តង។ គេស្រាយមុខហើយ ចំពោះខ្នោះវិញអត់មានស្រាយទេ អត់ដោះទេ ដាច់ខាត អត់មានដោះសោះ ប៉ុន្តែមុខស្រាយ។ ពេលដែលថតហើយ គេចងមុខ បញ្ជូនទៅគុកតែម្តង។ ខាងខ្ញុំ ភារកិច្ចថត សូម្បីតែនិយាយជាមួយអ្នកទោស ក៏អត់បានដែរ អត់បានដាច់ខាត ព្រោះការងារគេ គេដឹង ការងារយើង យើងដឹង ក្បាលអ្នកណា សក់អ្នកហ្នឹង។ ដូចសម័យនោះ ក៏បានខ្ញុំជាអ្នកថត មានភារកិច្ចត្រឹមតែថតរូបតែប៉ុណ្ណោះ។

**ស៖** តើមានពេលណាមួយនេះ <>ដែល<>អ្នកទោស<និយាយអ្វីមួយជាមួយលោក ឬក៏សួរសំណួរអីទេ? ហើយបើមាន តើគេនិយាយអំពីអ្វី? តើមាននិយាយ មានសួរទេ? តើអ្នកទោសមាននិយាយអីទេនៅពេលគេដោះរបាំងមុខចេញ> ហើយ<លោក>នៅ<ទីនោះចាំ>ថតរូប<ពួកគេ? តើលោកចាំទេ ថាតើ>អ្នកទោសមានធ្លាប់ដែលប៉ាននិយាយអីមកកាន់លោកទេ?

**ឆ៖** បាទ ខ្ញុំបានជួបគណៈស្រុកមួយមកពីកំពង់លែង ពេលនោះខ្ញុំបានលួចមើលប្រវត្តិរូប ដូចឈ្មោះ តាយឹម។ តាយឹម ហ្នឹងគឺគណៈស្រុកកំពង់លែង គាត់មានខូចសីលធម៌ជាមួយយាយ គឺថា យាយម៉ែនៗ ហ្នឹងគណៈកងទ័ព បញ្ជាការកងទ័ពស្រីដែរ។ ដល់អ៊ីចឹងទៅ ពេលដែលខ្ញុំឃើញប្រវត្តិរូប កាលនុ៎ងគេហៅស្រុកកំពង់១៦។ ដល់ពេលខ្ញុំឃើញៗប្រវត្តិរូប ខ្ញុំលួចមើល គឺថា ខ្ញុំហៅអ៊ំៗ អ៊ំឯងមកពីណាថា ខ្ញុំមកពីកំពង់លែង។ ដល់ពេលដល់មកពីកំពង់លែង ខ្ញុំដូចជាៗងាក់ដែរ ព្រោះបងខ្ញុំធ្វើគណៈស្រុកដែរ បាទធ្វើគណៈស្រុកកំពង់លែងហ្នឹងជាមួយគាត់ហ្នឹង សម័យនុ៎ង គាត់ធ្វើគណៈស្រុកមួយដែរ។ ដល់អ៊ីចឹងទៅ ខ្ញុំថាចុះអ៊ំឯងស្គាល់ៗ បងមន ទេ? ខ្ញុំថីមិនស្គាល់ មិត្តមន គណៈឃុំឈានមុខ។ ដល់ខ្ញុំគឺចាប់ផ្តើមដូចជា *អ៊ែរ៉ឺ* ខួរក្បាលបណ្តោយទៅ។ ចាំមើលតែគេចាប់គណៈស្រុកមក គាត់អនុប្រធានត្រូវតែមក

ហើយ។ អ៊ីចឹងថា ខ្ញុំបាននិយាយតែម្នាក់គត់គឺឈ្មោះ តាយឹម ហ្នឹងគឺគណៈស្រុកកំពង់លែង ហៅថាតំបន់សម័យនោះ គេហៅស្រុក១៦ តែប៉ុណ្ណឹង។ ខ្ញុំហ៊ាននិយាយជាមួយអ្នកទោសតែមួយគត់ ហ្នឹងគឺខ្ញុំបានឃើញប្រវត្តិរូបគាត់ ខ្ញុំលួចមើល ដែលពាក់ព័ន្ធនឹងបងខ្ញុំបង្កើតផង។

**ស៖** ខ្ញុំសូមសួរបញ្ជាក់ចំណុចមួយនៅក្នុងសៀវភៅរបស់លោក ដែលលោកបានផ្ដល់មកឲ្យយើងនេះ <មានរូបថតមួយនៅ> ត្រង់ទំព័រ៤៤ នៃសៀវភៅរបស់លោក។ តើ<នេះជារូបថតរបស់មនុស្សម្នាក់ ក្នុងចំណោមមនុស្សបីនាក់ ដែលលោកកំពុងនិយាយនោះឬ គឺ>រូបថត<>ត្រង់ទំព័រ៤៤ហ្នឹង? <តើលោកអាចប្រាប់បានទេ ថាតើគាត់ជាអ្នកណា?> លោកមានសៀវភៅនេះនៅនឹងៗខ្លួនលោកទេ?

[១១:២១:៤៥]

<>សំណួររបស់ខ្ញុំ<គឺ> នៅ<ក្នុង>រូបថតលើទំព័រ៤៤ តើមានរូបថតមួយណាក្នុងចំណោមរូបថតទាំងនេះជាលេខាស្រុកកំពង់លែង<ដែលលោកនិយាយ>នោះ? <ឬក៏នេះជា>រូបថតនារី<>ដែលថាខុសសីលធម៌ជាមួយនឹងចៅហ្វាយស្រុកហ្នឹង<>? <តើ>លោក<អាចបញ្ជាក់ចំណុចនេះឲ្យយើងបានទេ?>

**ឆ៖** លោកព្រះរាជអាជ្ញារូបថតនេះ បាទរូបថតនេះ ៗឈ្មោះ យាយម៉ែន នេះយាយម៉ែន។ យាយម៉ែន ហ្នឹងគាត់ជាបញ្ជាការកងទ័ពស្រីនៅតំបន់៣១ ខ្លាំងណាស់ គឺគាត់នេះបាញ់បេម្ពង១០គ្រាប់ជាមួយទាហាន លន់ នល់ គឺខ្លាំងណាស់ គាត់ដោះតែម្ខាងទេ គាត់របួសដាច់ដោះម្ខាង។ ប៉ុន្តែក្រោយមកទៀត គាត់បានខូចសីលធម៌ជាមួយ តាយឹម ហ្នឹង គេចាប់មកទួលស្លែងទាំងពីរហ្នឹងឯង។ នេះៗបាទ រូបថតខ្ញុំចង្អុលនេះ ហ្នឹងឈ្មោះ យាយម៉ែនៗ។ គាត់បញ្ជាការកងទ័ពនៅតំបន់៣១ កងទ័ពស្រី។

**ស៖** <ហើយ>បុរសដែល<គាត់>ខូចសីលធម៌ជាមួយ<នោះ តើ>ជាលេខាស្រុកកំពង់លែង<>ដែលលោក<ទើបតែនិយាយពីរបីនាទីមុននេះឬ គឺអ្នកដែលលោកបាននិយាយជាមួយ> ពេលមកដល់ស-២១ <>នោះ?

**ឆ៖** បាទ មិនមែនជាលេខាទេ គាត់គណៈស្រុកតែប៉ុណ្ណោះ។ គណៈស្រុក ថាបើឥឡូវគេហៅចៅហ្វាយស្រុក កាលនុ៎ងគេហៅគណៈស្រុកកំពង់លែង អ៎គណៈស្រុកកំពង់លែង សម័យនោះគេហៅស្រុក១៦ តំបន់៣១ ខេត្តកំពង់ឆ្នាំង។ មិនមែនលេខាទេ គណៈស្រុក។

[១១:២៣:៥៣]

**ស៖** យើងឃើញរូបថតអ្នកទោសស-២១ គឺមានបង់លេខផ្សេងៗគ្នា មានបង់លេខនៅលើរូបថតនុ៎ង។ តើលោកអាចពន្យល់ជូនតុលាការអំពីរបៀបរបបដែល<គេប្រើនៅ>ពេលថតរូប<ដើម្បី>បង់លេខ<លើអ្នកទោសនោះ>?<>

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់ឆ្លើយសាក្សី!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំ<ដឹង>ថា <សហព្រះរាជអាជ្ញាបានស្នើ>សុំ<ដាក់រូបថតទាំងនេះទៅក្នុងសំណុំរឿង ប៉ុន្តែខ្ញុំអាចខុសក៏មិនដឹង យ៉ាងណាក៏ដោយ ខ្ញុំ>មិនទាន់ដឹងថា អង្គជំនុំជម្រះសម្រេចទទួលយករូបថតនេះហើយ ឬក៏នៅទេ? ទោះបីជា<>ខ្ញុំ<យល់ពីភាពពាក់ព័ន្ធនៃ>រូបថតទាំងនោះ<ក្ដី ក៏ប៉ុន្តែខ្ញុំជឿលើសេចក្ដីសម្រេច។> បើសិនណាមិនទាន់មានសេចក្ដីសម្រេច<>ទេ <ត្រូវតែធ្វើសេចក្ដីសម្រេចជាមុនសិន>។

**លោក ឌេល លីសាក់៖**

បញ្ជីរូបថតទាំងនេះត្រូវបានទទួលយក<រួច>ហើយ គឺឯកសារE3 សូមចាំមួយភ្លែត បញ្ជីរូបថតទាំងនេះ <>ត្រូវបាន<បញ្ចូលទៅក្នុងបញ្ជីឯកសារដើមរបស់>អង្គជំនុំជម្រះ <គឺអង្គជំនុំជម្រះសាលាដំបូងបាន>ទទួលយកហើយ គឺឯកសារ E3/9214។ <ដូចលោកដឹងហើយតាមរយៈការស្នើសុំរបស់យើងនោះ គឺថាមិនអាចរករូបថតបានទេ>នៅពេលយើង<ធ្វើ>បញ្ជី<ឯកសារជំនុំជម្រះ>ដើមដំបូងនោះ <ដូច្នេះហើយយើងបានស្នើសុំឱ្យ>ដាក់<បញ្ចូលបន្ថែមទៅក្នុង>ឯកសារ E3/9214។ ខ្ញុំយល់ស្របជាមួយនឹងការលើកឡើងរបស់មេធាវីការពារក្ដី <វាជាការល្អ ដែលត្រូវមានការសម្រេចទៅលើរឿងនេះ ហើយជាពិសេសនោះ នេះគឺជា>សាក្សី<> ដែល<យើងអាចប្រើប្រាស់រូបថតទាំងនេះជាមួយគាត់>។

[១១:២៦:១៣]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើមានភាគីដទៃទៀតណាជំទាស់ទៅនឹង<ការទទួលយក>រូបថតទាំងអស់នេះទេ? ខ្ញុំមើលទៅ

ឃើញថាមិនមានភាគីណាជំទាស់ទេ។

**លោក ខេល លីសាក់៖**

បាទសូមអរគុណលោកស្រីចៅក្រម។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** <សំណួររបស់ខ្ញុំនៅពេលនេះ គឺមិនចាំបាច់>ឲ្យលោកពិនិត្យមើលរូបថត<នោះទេ។ ប៉ុន្តែមុនពេលយើងឈប់សម្រាកនេះ តើ>លោក<អាច>ពន្យល់ជូនតុលាការ <ពី>របៀបរបបនីតិវិធី<>បង់លេខ<ដែលមាននៅលើរូបថតអ្នកទោស ស-២១ បានទេ?>

**លោក ញ៉ែម អែន៖**

**ឆ៖** នេះវាជាកាតព្វកិច្ចខ្ញុំជាអ្នកថត ខ្ញុំដឹងច្បាស់តែម្តងលោកព្រះរាជអាជ្ញា សូមជម្រាបជូនអង្គតុលាការទាំងអស់ថា ពេលអ្នកទោសដឹកយកមកដល់ អានេះខ្ញុំនិយាយឲ្យចំមិនបាច់ឧទាហរណ៍ទេ។ ពេលដឹកមកដល់ ពេលដឹកមកដល់ហើយចុះពីលើឡាន។ ចុះពីលើឡានហើយ ខាងខ្ញុំអ្នកថតនេះ អត់មានធ្វើអីទេ ចាំរង់ចាំកន្លែងថត។ ពេលថតហើយគឺចាប់ផ្តើម ឧទាហរណ៍ថា អត់មានឧទាហរណ៍ទេ ជារឿងពិត ចាប់ឧទាហរណ៍ថាថ្ងៃចន្ទ ថ្ងៃចន្ទទៅថ្ងៃទី១ ដាក់ពីលេខ១រហូត២៤ម៉ោង។ ២៤ម៉ោងហ្នឹងឧទាហរណ៍ថាដាក់ពីម៉ោងប្រាំពីរ រហូតទៅដល់ម៉ោងដប់ពីរ ឬក៏២៤ម៉ោង គឺចាប់ផ្តើមពីមួយថ្ងៃហ្នឹងតើអ្នកទោសចូលប៉ុន្មាននាក់អ៊ីចឹង ដូចៗលោកព្រះរាជអាជ្ញាអន្តរជាតិលោកបានឃើញហើយថា ពីលេខ១ខ្លះ រហូតដល់លេខ៥០០ អាហ្នឹងអ្នកទោសចូលមួយថ្ងៃ។ ជួនកាលលេខខ្លះមួយថ្ងៃ១០នាក់ ដល់លេខ២០។ ជួនកាលរហូតប្រាំពីរប្រាំបីរយក្នុងមួយថ្ងៃនេះ មិនមែនជារឿងឧទាហរណ៍ទេ ជាការពិត ព្រោះការដាក់លេខរៀងនេះ មិនមែនដាក់លេខរៀងអី សម្គាល់ថាតើអ្នកទោសក្នុងមួយថ្ងៃហ្នឹងចូលប៉ុន្មាននាក់បាទ។

[១១:២៨:០៥]

**ស៖** ដូច្នេះបើខ្ញុំយល់មិនច្រឡំទេ ក្នុងមួយថ្ងៃៗគឺលោកចាប់ផ្តើមបង់លេខអ្នកទោសហ្នឹងពីលេខ១ ហើយបង់ជាលំដាប់លំដោយតាមលេខស្ទីតអ៊ីចឹងទៅ<គ្រប់អ្នកទោសទាំងអស់ដែលលោកថតនៅថ្ងៃនោះ>។ អ៊ីចឹងត្រឹមត្រូវទេ បើខ្ញុំយល់យ៉ាងហ្នឹង?

**ឆ៖** បាទ លោកព្រះរាជអាជ្ញា វាជាការពិត ក្នុងមួយថ្ងៃចូលប៉ុន្មាន គឺពីលេខ១ដល់លេខ១០០ គឺ១០០ក្នុងមួយថ្ងៃ អត់មានលើស២៤ម៉ោង គិតទៅមួយថ្ងៃ២៤ម៉ោងតែម្តង។ ខុស២៤ម៉ោង គេដាក់លេខ

១ទៀត លេខ២ទៀត។ អ៊ីចឹងឃើញ លោកព្រះរាជអាជ្ញាឃើញហើយ លេខវាជាន់គ្នាច្រើនណាស់ អ៊ីចឹងអានេះមានគេសួរច្រើនដែរ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយកន្លះរសៀល។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:២៩ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:៤២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ មុនផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី អង្គជំនុំជម្រះសម្រេច ចេញសេចក្តីសម្រេចផ្ទាត់មាត់លើសំណើសុំ លើបញ្ហាចំនួនពីរ។ ទី១ គឺសេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការដែលធ្វើជាមេធាវីប្រឹក្សាសាក្សីពីមុនរបស់លោក គង់ សំអុន ដែលជាមេធាវីការពារក្តីលោក ខៀវ សំផន។ នៅពេលនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា ដែលបានដាក់កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ពាក់ព័ន្ធនឹងថា លោក គង់ សំអុន ជាមេធាវីជាតិការពារក្តីឲ្យលោក ខៀវ

សំផន ដែលធ្លាប់ធ្វើជាមេធាវីប្រឹក្សាសាក្សីកាលពីសំណុំរឿងមុនរបស់សាក្សី 2-TCW-898, 2-TCW-931, 2-TCW-906 និង 2-TCW-816។

បន្ទាប់ពីបានស្តាប់សារណាផ្ទាល់មាត់របស់ភាគីកាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ អង្គជំនុំជម្រះសម្រេចៈ ១) ច្រានចោលសំណើរបស់សហព្រះរាជអាជ្ញា ដែលបានស្នើសុំការលះបង់សិទ្ធិជាលាយលក្ខណ៍ អក្សរពីសំណាក់លោក ខៀវ សំផន។ ២) ស្នើថា ឲ្យក្រុមមេធាវីការពារក្តី ខៀវ សំផន លោក ខៀវ សំផន គឺលោកស្រី -- ឲ្យសហមេធាវីការពារអន្តរជាតិការពារក្តីលោក ខៀវ សំផន លោកស្រី អង់តា ហ្គីសសេ ជាអ្នកតាំងសំណួរទៅកាន់សាក្សី 2-TCW-898, 2-TCW-931, 2-TCW-906 និង 2-TCW-816។ ៣) បញ្ជាក់សាជាថ្មីថា មេធាវី គង់ សំអុន ត្រូវគោរពកាតព្វកិច្ចរបស់ខ្លួនក្នុងការរក្សាការសម្ងាត់សំអាងហេតុសេចក្តីសម្រេចនេះ នឹងចេញនៅពេលសមស្របខាងមុខ។

[១៣:៣៦:០២]

សេចក្តីសម្រេចផ្ទាល់មាត់ទី២ លើវិធានការការពារតាមវិធាន២៩ នៃវិធានផ្ទៃក្នុងសម្រាប់សាក្សី 2-TCW-865។ អង្គជំនុំជម្រះកត់សម្គាល់ថា សាក្សីដែលមានរហស្សនាម 2-TCW-865 ត្រូវបានផ្តល់នូវវិធានការការពារនៅក្នុងសំណុំរឿង០០១ អនុលោមតាមវិធាន២៩ នៃវិធានផ្ទៃក្នុង ឯកសារ E135។ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០១៦ អង្គភាពការពារសាក្សី និងអ្នកជំនាញបានផ្តល់ជូនមកអង្គជំនុំជម្រះនូវរបាយការណ៍វាយតម្លៃពីហានិភ័យដែលបានធ្វើបច្ចុប្បន្នភាពទាក់ទិននឹងសាក្សី 2-TCW-865 និងបានផ្តល់ជាអនុសាសន៍ថា គួរតែមានវិធានការការពារមួយចំនួន នៅក្នុងអំឡុងពេលសាក្សីរូបនេះផ្តល់សក្ខីកម្ម។ បានឃើញលក្ខខណ្ឌតម្រូវនៃវិធាន២៩ នៃវិធានផ្ទៃក្នុង និងបទប្បញ្ញត្តិនៃវិធាន -- នៃមាត្រា៤ នៃសេចក្តីណែនាំអនុវត្តអំពីវិធានការការពារ អ.វ.ត.ក/០៣-២០០៧/វ០១ អង្គជំនុំជម្រះសម្រេចបង្គាប់ឲ្យមានវិធានការពារដូចខាងក្រោមនេះៈ

១) សំឡេង និងរូបភាពរបស់សាក្សីមិនត្រូវបញ្ចេញជាសាធារណៈ។ ២) ព័ត៌មានលម្អិតសម្រាប់ធ្វើទំនាក់ទំនងព័ត៌មានគ្រួសារ រួមទាំងឈ្មោះសហព័ទ្ធ និងកូន និងអាសយដ្ឋាន និងទីកន្លែងធ្វើការមិនត្រូវបញ្ចេញជាសាធារណៈ។ ៣) ព័ត៌មានទាំងអស់ដែលអាចបង្ហាញពីទីតាំងកន្លែងរស់នៅ ឬធ្វើការត្រូវកោសលុបចេញពី ឯកសារសាធារណៈ។

[១៣:៣៧:៥១]

ដើម្បីឲ្យមានប្រសិទ្ធភាពដល់វិធានការការពារខាងលើនេះ នៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មរបស់

សាក្សីរូបនេះ អង្គជំនុំជម្រះបង្គាប់ឲ្យប្រើបច្ចេកទេសវិទ្យាបំលែងសំឡេង និង រូបមុខសាក្សីនេះ នៅក្នុងការផ្សាយពីកិច្ចនីតិវិធីនៅអំឡុងពេលសាក្សី 2-TCW-865 ផ្តល់សក្ខីកម្ម និងបង្គាប់ឲ្យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងអស់មិនត្រូវបោះពុម្ពផ្សាយនូវរូបភាពណាមួយ ឬក៏រូបភាពទាំងឡាយរបស់សាក្សី 2-TCW-865 នេះ ដោយមិនគិតថា រូបភាពទាំងនោះថតនៅពេលណានោះទេ។ ក្នុងនោះរួមទាំងវីដេអូ ឯកសារ ឬក៏ព័ត៌មានផ្ទាល់ខ្លួនលម្អិត ដូចជាអាសយដ្ឋានរស់នៅ និងឈ្មោះសមាជិកគ្រួសាររបស់គាត់។

សំអាងហេតុនៃសេចក្តីសម្រេចលាយលក្ខណ៍អក្សរ នៃសេចក្តីសម្រេចនេះ នឹងចេញនៅពេលសមស្របខាងមុខ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ជម្រាបសួរលោកសាក្សី។ មុននេះយើងបាននិយាយអំពីនីតិវិធីក្នុងការដាក់លេខអ្នកទោសដែលលោកបានថតរូប។ ឥឡូវនេះខ្ញុំចង់សួរលោកអំពី<ការផ្លាស់ប្តូរ>លេខ<អត្តសញ្ញាណ ដែលត្រូវបានគេប្រើលើ>អ្នកទោសដែលយើងឃើញនៅក្នុងរូបថតនោះ។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់នូវឯកសារពីរបីទំព័រ <ពីបណ្តុំរូបថតថ្មី> ដែលយើងបាន<ដាក់ទៅក្នុងសំណុំរឿង គឺឯកសារលេខ> E394.1 គឺទំព័រ <P01223718> និង <P01223766>។ ខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារនេះ ជូនទៅដល់សាក្សី។ សូមលោកប្រធានអនុញ្ញាត។

[១៣:៣៩:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំចង់ឲ្យលោកចាប់អារម្មណ៍ទៅលើពីរទំព័រដែលខ្ញុំប្រគល់ជូនលោក។ ទី១ គឺមើលរូបថតស្ត្រីនៅលេខ១៧៨។ ខ្ញុំសូមអនុញ្ញាតដាក់បង្ហាញផងដែរ នៅលើអេក្រង់កុំព្យូទ័រ។ សូមលោកប្រធានមេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ប្រសិនបើលោកមើលទៅលើរូបថតស្ត្រីលេខ១៧៨ គឺថាយើងឃើញថាលេខ ផ្លាកលេខដែលគាត់ពាក់ គឺលេខ២៦ <ឬ>២៨ គឺថាមានពីរលេខ<ខុសគ្នា>ដែលគេចងព្យួរនៅករបស់គាត់ ដើម្បីបង្ហាញអំពីលេខរៀងរបស់គាត់នោះ<នៅថ្ងៃនោះ>។ ហើយខ្ញុំចង់ធ្វើការប្រៀបធៀបជាមួយនឹងអ្វីដែលលោកមើលនៅទំព័របន្ទាប់ គឺរូបថតដែលយើងឃើញ<>ចុះ<កាលបរិច្ឆេទ>ឆ្នាំ៧៨។ <ហើយបើលោកមើលទៅទំព័របន្ទាប់ ដែលខ្ញុំបានប្រគល់ឲ្យលោក> ឧទាហរណ៍ យើងមើលទៅលេខរូបថត៤៥៤ និង៤៥៧។ បុគ្គលទាំងពីរនេះមានលេខផង មានឈ្មោះផង ហើយមានកាលបរិច្ឆេទ ហើយនិងមានលេខថែមទៅទៀត។ ដូច្នេះខ្ញុំចង់សួរលោកថា តើនីតិវិធីក្នុងការថតរូបមានការផ្លាស់ប្តូរដែរឬទេ? គឺថាតើគេចាប់ផ្តើមផ្លាស់ប្តូរការប្រើប្រាស់ព័ត៌មានលម្អិតហ្នឹង នៅពេលណាដែរ? ហើយ<មូលហេតុដែលខ្ញុំសួរគឺថា វាគួរតែមានពេលខ្លះដើម្បីធ្វើកាតសម្គាល់ទាំងនេះ មុនពេលគេថតរូបបុគ្គលទាំងនោះ> ដូច្នេះតើលោកអាចពន្យល់បានទេ ថាគេផ្លាស់ប្តូរនីតិវិធីហ្នឹង<យ៉ាងម៉េច>នៅពេលដែលគេចាប់ផ្តើមប្តូរពីព័ត៌មានខ្លីៗ សង្ខេបៗ មកជាព័ត៌មានលម្អិតអ៊ីចឹង? តើលោកអាចពន្យល់ឲ្យបានច្បាស់បន្តិចបានទេ?

[១៣:៤២:២៧]

**លោក ញ៉ែម អេន៖**

**ឆ៖** លោកព្រះរាជអាជ្ញា ខ្ញុំសូមពន្យល់បន្តិច ទាក់ទងនឹងស្ត្រីម្នាក់ដែលមានពាក់លេខ២ លេខ ២-២៦នេះ ជួនកាលលេខកាលនុ៎ង យើងការបច្ចេកទេស យើងមានការធ្វើជាបន្តៗមក ដូច្នេះបើគាត់ចូលរៀង២៦ ត្រូវតែដាក់លេខ២។ លេខ២ និង៦ អាហ្នឹងលេខរៀង២៦បាទ។ បន្ទាប់មកទៀត ទាក់ទងនឹងរូបខាងក្រោយនេះ ដែលបានដាក់ខែឆ្នាំ លេខផង ហ្នឹងគឺជាកាតព្វកិច្ចមួយរបស់ តាឌុច គាត់ឲ្យមានការប្រែប្រួល។ បាទមានការប្រែប្រួលហើយ មានការប្រែប្រួលនេះគឺរៀបចំឲ្យមានខែថ្ងៃ និងលេខ ជាប់នៅនឹងឈ្មោះតែម្តង។ ដោយទី១ ស្រួល យើងពាក់ព័ន្ធនៅមើលនូវប្រវត្តិរូប និងចម្លើយរបស់គាត់។ នេះគឺជាបញ្ហាពី សុន សេន និង តាឌុច តែម្តង។

**ស៖** តើអ្នកណាជាអ្នកបង្កើតស្លាក ឬក៏ឈ្មោះ ស្លាកឈ្មោះថ្មី មានឈ្មោះផង មានកាលបរិច្ឆេទផង មានលេខផងហ្នឹង? តើអង្គភាពរបស់លោក<ធ្វើវា ឬក៏អង្គភាពរបស់> សួស ធី <ធ្វើឲ្យលោក>?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ លោកព្រះរាជអាជ្ញា នេះគឺការធ្វើនេះ អត់មានបុគ្គលណាធ្វើសម្រេចខ្លួនឯងបានទេ សម័យនោះ គឺមានការសម្រេចចិត្តមកពីទាំងបី។ ទី១ តាឌុច, ទី២ តាហ៊ុ, ទី៣ តាចាន់ អ្នកឲ្យធ្វើ ព្រោះតាឌុច គាត់ឲ្យផ្លាស់ប្តូររហូត។

[១៣:៤៤:០១]

**ស៖** ប្រហែល<ជាសំណួររបស់ខ្ញុំសួរមិនបានល្អ> ដូច្នេះខ្ញុំចង់ដឹងថាតើអ្នកណាជាអ្នកធ្វើស្លាកឈ្មោះ ដែលថាមានឈ្មោះផង មានកាលបរិច្ឆេទផង? ខ្ញុំចង់សួរថា អ្នកណាជាអ្នកធ្វើអាក្ការ ឬក៏អាស្លាកដែលមានឈ្មោះ មានអីទាំងអស់ហ្នឹង?

**ឆ៖** លោកព្រះរាជអាជ្ញា នេះខាងពួកខ្ញុំក្រុមជាងថតហ្នឹង អ្នកធ្វើខ្លួនឯងតែម្តង មានការបទបញ្ជាពី តាឌុច ឲ្យធ្វើតែម្តង។ គឺបច្ចេកទេសខ្លួនឯង ដើម្បីសម្រួលដល់ការធ្វើប្រវត្តិរូបផង ហើយសម្រួលងាយស្រួលនឹងធ្វើកិច្ចការទាំងអស់។

**ស៖** ប្រសិនបើសិនបើលោកមើលលេខ៤៥៤ និង៤៥៧ វិញ មើលរូបបុរសពីរនាក់វិញ ហើយខ្ញុំសូមអនុញ្ញាតលោកប្រធានបង្ហាញនៅលើអេក្រង់ផងដែរ។ គឺជាអ្នកទោសបុរស។ ខ្ញុំចង់សួរលោកថា តើ<ពេលខ្លះមាន>អ្នកទោស<ទៅដល់កន្លែង>លោក<>ថត<រូបនោះ>មើលទៅដូចត្រូវគេវាយដំរួចទៅហើយ<ទេ? បើសិនណាលោកមើលរូបថតទាំងពីរនេះ នៅក្នុងរូបថត បុរសទាំងពីរនាក់នេះមើលទៅហាក់ដូចជាគេវាយលើ>មុខមាត់អស់ទៅហើយ។ តើលោកអាចឃើញទេថាវាមានករណីបែបហ្នឹង?

**ឆ៖** នេះជារឿងពិត មានរូបភាពជាច្រើនដែលទៅថតមានគេវាយ មានគេវាយហើយ ក៏ហើមមុខហើមមាត់ ពីកន្លែងគេដឹកឡាន បានយើងថត មានៗជាច្រើន មិនមែនមានតែមួយសន្លឹក មានច្រើន។

**ស៖** ហើយប្រធានបទបន្ទាប់ដែលខ្ញុំចង់សួរលោកគឺ អំពីបញ្ហាកូនក្មេង។ <>ថាតើមានកូនក្មេងដែលគេបញ្ជូនទៅស-២១ ហើយយកមកឲ្យអង្គភាពលោកថតរូបដែរឬទេ?

[១៣:៤៦:០៨]

**ឆ៖** សូមជម្រាបជូនព្រះរាជអាជ្ញាថា រឿងនេះវាជារឿងពិត កូនក្មេងយកមកក៏អង្គការតម្រូវឲ្យថតដែរ។ ប៉ុន្តែអង្គការតម្រូវឲ្យថតនេះគឺ ភាគច្រើនដែលតែក្មេងៗដែលមានជាប់ពូជស្រឡាយ គឺថាកូនអ្នកធំ ឬក៏កូនរាជការមួយចំនួនដែលពាក់ព័ន្ធនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង ប៉ុន្តែកុមារភាគច្រើន ក៏អត់បានថតដែរ។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** ខ្ញុំនឹងសួរលោកនៅពេលក្រោយបន្តិចទៀត អំពីក្មេងដែលមិន<>បានថតរូប។ ប៉ុន្តែឥឡូវនេះខ្ញុំសូមអនុញ្ញាតលោកប្រធានផ្តល់នូវរូបថតពីរបីសន្លឹកទៀតជូនដល់សាក្សី ដើម្បីឲ្យសាក្សីកំណត់អត្តសញ្ញាណ។ ទី១) គឺជារូបថតចំនួន៥.000 ដែលបានទទួលរួចមកហើយហ្នឹង ហើយរូបថតនេះគឺមានលើឯកសារ E3/8639 ហើយមានលេខរៀង<ជាបន្តបន្ទាប់។> ឯកសារ<ដំបូងដែលខ្ញុំស្នើសុំគឺ> <E38639.171, .649, .705, .698 និង .1896> *(ស៊ីក)*។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតប្រគល់ជូនសាក្សីនូវរូបថតមួយចំនួន<បួន ដែលត្រូវបានទទួលស្គាល់រួចហើយ>គឺ <> E3/8058 <ដែលមានម្តាយនិងកូនង៉ែតមួយចំនួន។> ដូច្នេះខ្ញុំសូមអនុញ្ញាតពីលោកប្រធានដើម្បីប្រគល់ឯកសារនេះជូនដល់សាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**សៈ** សូមលោកមើលទៅលើរូបថតនេះ។ ទី១ គឺថា តើលោក<ស្គាល់>រូបថត<ទាំងនេះទេ?> ក្រុមទី១ <គឺជារូប>ថតក្មេង ឬក៏ពួកជំទង់ៗនៅស-២១<> ហើយក្រុមទី២ គឺរូបថតម្តាយដែលមានកាន់ ឬក៏ដែលមាន<>កូនក្មេងនៅ<ជាមួយ>?

លោកប្រធានក្នុងពេលដែលសាក្សីកំពុងពិនិត្យខ្ញុំសូមអនុញ្ញាតផងដែរ លោកប្រធានដើម្បីដាក់បង្ហាញនៅលើអេក្រង់។

[១៣:៤៩:១៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**សៈ** លោកសាក្សី តើលោក<ស្គាល់>រូបថតនេះដែរទេ គឺរូបថតដែលថតនៅមន្ទីរស-២១នេះ?

**លោក ញ៉ែម អេន៖**

**ឆៈ** បាទ លោកព្រះរាជអាជ្ញា ខ្ញុំចាំបាន។ រូបភាពមួយនេះគឺឈ្មោះ យាយស្រ៊ុន។ យាយស្រ៊ុននេះគឺគាត់ជាប្រពន្ធរបស់លេខានៅតំបន់-២៥។

**សៈ** ខ្ញុំចង់ឲ្យលោកមើលទៅលើទំព័រទី១ គឺទៅមើលតែរូបម្តាយទី១ដែលកាន់កូន គឺ<ឯកសារ E3/8058> រូបភាព <P0000046> គឺជា<>ម្តាយគឺមានស្លាកលេខ២៤៦។ ខ្ញុំចង់សួរលោក ថាតើ

លេខរៀង២៤៦នៅលើគាត់ហ្នឹង គឺមានន័យថា គាត់ជាអ្នកទោស<>លេខ២៤៦ដែលត្រូវថតនៅថ្ងៃនោះតើមែនទេ?

**ឆ៖** បាទ លោកព្រះរាជអាជ្ញា នេះជារឿងពិត ព្រោះក្នុងលេខ២៤៦នេះបានន័យថាក្នុងមួយថ្ងៃដល់២៤៦ ប៉ុន្តែអាចមានលើសនេះទៅទៀត ប៉ុន្តែអានេះជាគេកំណត់ក្នុងមួយថ្ងៃ មួយថ្ងៃ២៤ម៉ោង។

[១៣:៥១:១២]

**ស៖** ស្ត្រីនេះគាត់កាន់កូនង៉ែត<>មួយនៅនឹងដៃ តើលោកដឹងទេថាមានអីកើតឡើងចំពោះកូនក្មេងហ្នឹងនៅពេល<>ដែលគេបញ្ជូនម្ដាយទៅបន្ទប់ឃុំឃាំង<នៅស-២១>ហ្នឹង តើ<មានអ្វីកើតឡើងចំពោះ>កូនតូចហ្នឹង<>?

**ឆ៖** សូមជម្រាបជូនលោកប្រធាន លោកព្រះរាជអាជ្ញាថា កូនក្មេងទាំងអស់ដែលបានយកមកនៅគុកទួលស្លែងនេះ មកទាំងម្ដាយទាំងកូន ខ្លះមកជាកូនពីរកូនបីក៏មាន ប៉ុន្តែស្ទើរតែ១០០ភាគរយ អត់បានរស់ទេ រស់តិចណាស់ បាទតិចណាស់ គេយកទៅសម្លាប់ចោលទាំងអស់។ ជួនកាលគេបំបែកៗកូនចេញ គេយកកូនទៅវៃចោលមុនក៏មាន។ នេះដឹង ករណីខ្ញុំដឹងពិតនៅក្នុងគុកទួលស្លែង។

**ស៖** <សំណួរចុងក្រោយរបស់ខ្ញុំអំពីកូនក្មេង ឬក៏ង៉ែត។> នៅពេលដែលកូនង៉ែត ឬក៏ក្មេងៗ<ត្រូវបាននាំទៅស-២១>ជាមួយម្ដាយឪពុកហ្នឹង តើគេថតក្មេងហ្នឹងដែរឬទេ ហើយគេបានចុះបញ្ជីកត់ឈ្មោះអីដែរឬទេ? តើ<ញឹកញាប់ប៉ុនណាដែរ ដែល>គេបានថតរូបកូនង៉ែត ឬក៏ក្មេងៗ<>ហើយ<>ចុះបញ្ជីទៅក្នុង<កំណត់ហេតុ>ស-២១<>?

**ឆ៖** បាទ តាមរឿងពិតដែលខ្ញុំបាទដឹង គឺដូចជាអត់បានចុះបញ្ជីឈ្មោះទេ កូនក្មេងច្រើនណាស់ មិនមែនតែមួយពីរបីហ្នឹង ច្រើន។ ជួនកាលក៏អត់បានថត គេយកទៅពិឃាដទាំងអស់ យកទៅសម្លាប់ចោល ប៉ុន្តែដូចខ្ញុំជម្រាបជូនពីខាងដើមអ៊ីចឹង មិនអាចទេ មិនអាចសល់ទេ តិចណាស់បាទ។

**ស៖** តើលោកអាចប៉ាន់ប្រមាណមើល ថាតើក្មេងៗមានចំនួនប៉ុន្មាននាក់ដែលគេបញ្ជូនទៅស-២១ ហើយត្រូវបានគេយកទៅសម្លាប់ចោល គឺថាក្មេងៗដែលគេមិនចាំបាច់មានថតរូប មានចុះឈ្មោះអីទេ ប៉ុន្តែយកទៅតែម្ដងហ្នឹង លោកអាចប៉ាន់ប្រមាណចំនួនបានទេ?

[១៣:៥៣:៤១]

**ឆ៖** ខ្ញុំបាទសូមជម្រាបជូនរឿងនេះ វាជារឿងអយុត្តិធម៌ណាស់សម្រាប់ប្រជាជនកម្ពុជា អ្នករងគ្រោះ។ កូនក្មេងដែលខ្ញុំបានឃើញការដឹកមកទាំងឡានៗ ដឹកឪពុកម្ដាយមកហើយគេចាប់កូនមក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

និយាយរួមទៅទាំងមួយពូជៗក៏មាន។ ប្រហែលមិនក្រោម១.០០០នាក់ជាង ឬក៏២.០០០ច្រើនណាស់ កូនក្មេងមក តែឪពុកម្ដាយមក ៗដែរ។ អ៊ីចឹងថាការចាប់សម័យនោះ គឺគ្មាន តែចាប់ម្ដាយឪពុកហើយគឺក្មេងអត់រួចទេ។ អ៊ីចឹងថាទាំងពូជៗ ប៉ុន្តែអត់បានថតរូបទេ។ នេះជាការពិតដែលខ្ញុំឃើញបាទ។ ជួនកាលអាក្មេងដែលបៅដោះក៏មកតាមមក អាក្មេងអត់បៅដោះត្រឹមអាយុប្រាំពីរ ប្រាំបីឆ្នាំគេប្រលេះយកទៅអស់។ មានក្រុមឆ្មាំរបស់គេ ៗអត់ឲ្យចូល នេះជាឃើញជាការពិត។ ច្រើន ខ្ញុំឃើញនឹងផ្ទាល់ភ្នែកមិនក្រោមពី១.០០០នាក់ទេកុមារ គេយកទៅសម្លាប់ក្រោយគុកទួលស្លែងហ្នឹង។

**ស៖** ហើយឥឡូវនេះខ្ញុំចង់សួរលោក ប្រធានបទចុងក្រោយ <តើអ្នកទោស>--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់ព្រះរាជអាជ្ញារង!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំចាំឲ្យព្រះរាជអាជ្ញាគាត់សួរសំណួរ <>ថាតើសាក្សីដឹងថាមានអីកើតឡើងចំពោះក្មេង<ៗ>ហ្នឹង <ព្រោះ>ថាមាន<>ភ័ស្តុតាងជាច្រើនដែលថា ក្មេង<ៗតូចៗ>ត្រូវបានបញ្ជូនទៅព្រៃស – ស-២៤ ក៏ប៉ុន្តែគាត់គ្រាន់តែធ្វើការទាយស្មានប៉ុណ្ណោះ។ <គាត់មិនបានដឹងរឿងនោះទេ។> ដូច្នេះយ៉ាងហោចណាស់ ក៏ព្រះរាជអាជ្ញាសួរថា តើសាក្សីដឹងដោយរបៀបណា។

[១៣:៥៥:១៥]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<លោកមេធាវី ហេតុអ្វីបានជាលោកមិនសួរខ្លួនឯងទៅ នៅពេលដល់វេនរបស់លោកនោះ?>

**លោក វ៉ិចទ័រ កូប៉េ៖**

<ព្រោះខ្ញុំអត់មានពេលវេលាគ្រប់គ្រាន់។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<លោកនៅមានពេលម្តងទៀត។>

**លោក ឌេល លីសាក់៖**

<លោកប្រធាន សូមជំទាស់នឹងមេធាវីការពារក្តី ដែលធ្វើការបង្ហាញអំពីអ្វីដែលជាភ័ស្តុតាងនោះ។> ខ្ញុំមិនដឹងអំពីបញ្ហាទាំងអស់<ទាក់ទងនឹងភ័ស្តុតាងដែលគាត់និយាយនោះ។> ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំនឹងអាចសួរទៅសាក្សី។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី តើលោកសាក្សីដឹង<យ៉ាងម៉េច>ថា មានអ្វីកើតឡើងចំពោះក្មេងៗនោះ ក្រោយពេលដែលគេបំបែកចេញពីឪពុកម្ដាយ?

**លោក ញ៉ែម អេន៖**

**ឆ៖** បាទ រឿងនេះ វាជាការពិត ពេលណាដែលបំបែកពីចេញពីឪពុកម្ដាយហើយ ក្មេងនោះគឺគេយកទៅសម្លាប់ចោលតែម្ដង។ បើថានៅរស់ គឺនៅរស់តិចដែរ ព្រោះនៅព្រៃសក៏ដូចគ្នា ការបញ្ជូនទៅក៏ដូចជាអត់ឃើញក្មេងដែរ។ អ៊ីចឹងថាខ្ញុំមិនសន្និដ្ឋានទេ អាហ្នឹងវាជាការពិតតែម្ដង គឺគ្មានទេ បាត់បង់ជីវិតទាំងអស់ហ្នឹង។

[១៣:៥៦:១៧]

**ស៖** ខ្ញុំចង់ដឹងថា តើលោកដឹងដោយរបៀបណា? មានអ្នកណាប្រាប់លោកថា គេសម្លាប់ក្មេង? ថាតើសន្តិសុខប្រាប់លោក ឬក៏លោកបានឃើញដោយផ្ទាល់? ដូច្នេះខ្ញុំចង់ដឹងថា លោកធ្វើយ៉ាងណា បានដឹងថា គេសម្លាប់ក្មេងទាំងនោះចោល?

**ឆ៖** បាទ លោកព្រះរាជអាជ្ញា ដែលខ្ញុំឃើញ ពេលដែលគេប្រលេះក្មេងចេញពីឪពុកម្ដាយ គេដឹងទាំងឡានៗយកទៅបាទ យកទៅ ដឹងគេយកទៅណា ថាយកទៅព្រៃស។ ប៉ុន្តែដល់ពេលសម័យនោះ ដូចជាអត់ឃើញមានមជ្ឈមណ្ឌលចិញ្ចឹមកុមារកំព្រាដូចសម័យឥឡូវផង។ ដល់ទៅ អត់ដែលឃើញផងកុមារអស់នុ៎ង មិនដឹងជាទៅណា។ បើសន្និដ្ឋានរបស់ខ្ញុំជាការពិត គឺក្មេងនុ៎ងប្រហែលជាស្លាប់អស់ ព្រោះអត់មានចិញ្ចឹមផង។

**ប្រធានអង្គជំនុំ៖**

សាក្សីយើងរំឭកម្ដងទៀត ទី១គឺសួរអ្វី ខ្លឹមសារនៃសំណួរ ឲ្យចាំបាច់តបទៅនឹងសំណួរ ចាំបាច់គ្រប់គ្រាន់តបទៅនឹងសំណួរដែលសួរបានហើយ។ ជៀសវាងពន្លាតអត្ថាធិប្បាយផ្សេង លើកលែងតែសំណួរ អ្នកសួរឲ្យលោកធ្វើអត្ថាធិប្បាយរៀបរាប់។ បាទ ហើយនេះគឺច្បាស់លាស់។

ហើយបញ្ហាទី២ សាក្សីត្រូវផ្ដល់អ្វីដែលដឹង ដែលឃើញ ដែលធ្វើការសង្កេត មិនផ្ដល់សេចក្ដីសន្និដ្ឋានទេ។ ការសេចក្ដីសន្និដ្ឋានគឺជាភារកិច្ចអ្នកជំនាញ ដោយសារអ្នកជំនាញមិនមែនសាក្សីទេ មែនអ្នកដឹងរឿង មិនមែនអ្នកឃើញ មិនមែនអ្នកព្រឹត្តិហេតុផ្ទាល់ពាក់ព័ន្ធនឹងសំណួរទេ ទើបគេធ្វើសន្និដ្ឋាន ដូច្នេះចម្លើយសន្និដ្ឋាន វាស្មើអត់ប្រយោជន៍។ វាអត់មានចូលនៅក្នុងរឿងដែលអត្ថន័យក្នុងការយកមក

វាយតម្លៃជាសក្ខីកម្ម ដើម្បីស្វែងរកការពិតនៅក្នុងរឿងក្ដីទេ វានាំឲ្យទៅជាសេចក្ដីសន្និដ្ឋានរបស់សាក្សី។ អ៊ីចឹងគឺសាក្សីឆ្លើយតែកម្រិតណា ដែលលោកបានដឹង បានឮ បានឃើញ ដោយច្បាស់លាស់។ បើឮ គឺឮពីប្រភពណា ដែលមានប្រភពច្បាស់លាស់ សុំឆ្លើយ ឲ្យបានច្បាស់លាស់។ ពុំដូច្នោះទេ គឺអាចមានបញ្ហានូវបច្ចេកទេសក្នុងការដំណើរការសវនាការ វាអាចថយ ឬក៏វាអត់មានតម្លៃ។

[១៣:៥៨:២១]

ហើយបញ្ហាមួយទៀត លោកមិនគប្បីប្រើពាក្យនៃពាក្យថា "យុត្តិធម៌, អយុត្តិធម៌" ទេ។ ពាក្យនេះជាពាក្យច្បាប់ វាគប្បីទុកឲ្យអង្គជំនុំជម្រះពិនិត្យពិចារណា។ ភាគីផ្សេងទៀតពាក់ព័ន្ធ គេនឹងធ្វើការវាយតម្លៃសេចក្ដីសន្និដ្ឋានចុងបញ្ចប់ ហើយនិងអង្គជំនុំជម្រះនឹងពិនិត្យពិចារណាសម្រេចបញ្ហានេះ។ វាពាក្យនេះ វាពាក្យជ្រៅ មិនមែនពាក្យសាមញ្ញទេ។ យើងនិយាយពាក្យហ្នឹង អយុត្តិធម៌ យុត្តិធម៌ វាសាមញ្ញ ប៉ុន្តែពាក្យនេះគឺជាការបកស្រាយ គេបង្កើតស្ថាប័នរដ្ឋមួយណា មិនមែនជាធម្មតាទេ។

សូមអញ្ជើញបន្តទៀត លោកសហព្រះរាជអាជ្ញាអន្តរជាតិ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកបានប្រាប់មេធាវីព្រឹកមិញ ថាលោកបានទៅព្រៃសទៅថតរូបជារៀងរាល់អាទិត្យ។ ហើយនៅពេលដែលលោកទៅព្រៃសហ្នឹង តើលោកមានបានឃើញក្មេងៗនៅទីនោះដែរឬទេ? តើលោកមានឃើញសាលារៀន ឬក៏ឃើញកន្លែងថែរក្សាកូនក្មេងដែរឬទេនៅពេលដែលលោកធ្វើដំណើរជារៀងរាល់សប្ដាហ៍ទៅព្រៃសនោះ?

**លោក ញ៉ែម អេន៖**

**ឆ៖** បាទ ខ្ញុំពិនិត្យនៅលើតំបន់ព្រៃស កាលហ្នឹងគេហៅឈ្មោះថា កន្លែងហ៊ុយស្រែ។ ហ៊ុយស្រែហ្នឹងកន្លែង ហ៊ុយ ធ្វើស្រែហ្នឹង។ ប៉ុន្តែខ្ញុំបាទធ្វើដំណើរទៅថតរូប យកមកធ្វើប្រវត្តិរូបអ្នកដែលមានពាក់ព័ន្ធនិន្នាការនយោបាយមួយចំនួន អត់មានឃើញកុមារសោះ ដឹងជាទៅណាអស់។ អានេះជាការពិតដែលខ្ញុំឃើញ ព្រោះធម្មតាតែយកពីគុកទួលស្លែងទៅ គេបញ្ជូនដាក់កន្លែងហ្នឹងហើយ ហ៊ុយស្រែ កន្លែងធ្វើស្រែតែម្ដង។ កុមារហ្នឹងអត់មានឃើញ ដឹងគេយកទៅទុកឯណា។ អាហ្នឹង វាជាក់ស្ដែងអ៊ីចឹង។

[១៤:០០:១១]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះជាប្រធានបទបញ្ចប់របស់ខ្ញុំហើយ។ <អ្នកទោស> ដែលលោកថត<រូប>នៅស-២១នោះ តើគេមានបានរួមបញ្ចូលទាហានវៀតណាម<ទេ ជាពិសេស>

គឺថាតើលោកបានថតរូបថតទាហានវៀតណាមដែលនៅពាក់ឯកសណ្ឋានជាទាហានវៀតណាមដែរ ឬទេ?

**ឆ៖** បាទ រឿងនេះគឺជារឿងសំខាន់មួយដែរ។ កាលនុំងមានការវាយចូលទៅខាងវៀតណាម វៀតណាមក៏វាយចូលមកកម្ពុជា។ ដូច្នេះគេចាប់ពីព្រំដែន ពីស្វាយរៀង ពីយើង និយាយរួមព្រំដែនកម្ពុជាទាំងមូល ឲ្យតែចាប់បានវៀតណាមមក គេបញ្ជូនមកទួលស្លែង ហើយខ្ញុំថតៗជាច្រើន រូបថតអាចមានជាច្រើនតែម្តង។ គឺពិតប្រាកដហើយ គឺទាហានវៀតណាមអត់មានមក មកស្លៀកបំពាក់ខោអាវវៀត-ណាមអី គឺចាប់សុទ្ធៗពីព្រំដែនតែម្តង។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ដល់សាក្សីនូវឯកសារ E3/8063.3 គឺជាកម្រងប្រមូលផ្តុំរូបថតមនុស្សជាច្រើន<> ដើម្បីឲ្យមានការកំណត់អត្តសញ្ញាណ ដូច្នេះសូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក ខេល លីសាក់៖**

នៅពេលដែលសាក្សីគាត់កំពុងពិនិត្យមើលនេះ ខ្ញុំសូមអនុញ្ញាតលោកប្រធានបង្ហាញរូបថត គឺលេខ P000015 សូមលោកប្រធានអនុញ្ញាតផងដែរ។

[១៤:០២:០៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ខេល លីសាក់៖**

**ស៖** សូមលោកមើលទៅលើរូបថតមួយនេះ ហើយលោកប្រាប់បានទេ ថាតើរូបថតនេះ គឺជារូបថតដែលថតនៅស-២១ដែរឬទេ? ហើយថាមនុស្សដែលនៅក្នុងរូបថតហ្នឹង គឺជា<>អ្នកណាដែរ?

**លោក ញ៉ែម អេន៖**

**ឆ៖** សូមជម្រាបជូនលោកប្រធាន និងលោកព្រះរាជអាជ្ញាថា រូបថតវៀតណាមនេះ គឺសម័យនោះមានការវាយ ខ្ញុំឲ្យត្រង់ទៅ ខ្ញុំបានចូលទៅវាយដែរ ប៉ុន្តែខ្ញុំមិនចូលទៅវាយ ខ្ញុំទៅថត ដូចជានៅក្រុងដូចតែនិញ ដូចជាអានយ៉ាង ខេត្តមាត់ជ្រូក។ ទាហានហ្នឹង គឺទាហានវៀតណាម គេចាប់មកគឹកងទ័ព

ខ្មែរក្រហម គឺបញ្ជូនតែម្តង។ កាលនុ៎ងគឺ តាម៉ុក បញ្ជូនពីអានយ៉ាងមកច្រើនណាស់ ចាប់បាននៅភ្នំដិន។ នេះគឺជារូបថតវៀតណាម គឺពិតប្រាកដ អត់មានក្លែងក្លាយទេ។

**ស៖** សូមអរគុណ។ ហើយមានរូបថតចុងក្រោយមួយទៀត ដែលខ្ញុំចង់សួរលោកផងដែរ លោកសាក្សី។ សូមអនុញ្ញាតពីលោកប្រធានដើម្បីបង្ហាញរូបថតនេះ គឺរូបថតនៅលើឯកសារ E3/2634 នៅ ERN មានលេខ 00658495។ សូមអនុញ្ញាតពីលោកប្រធាន ដើម្បីប្រគល់ជូនសាក្សី។

[១៤:០៣:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**លោក ខេល លីសាក់៖**

ហើយខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់ផងដែរ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំចង់សួរលោក ថាតើលោកចាំរូបថតនេះដែរឬទេ ឬក៏ថាតើលោកចាំមនុស្ស <ណាម្នាក់>នៅក្នុងរូបថតនេះដែរឬទេ?

**លោក ញ៉ែម អេន៖**

**ឆ៖** លោកប្រធាន លោកព្រះរាជអាជ្ញា រូបថតនេះ ខ្ញុំចាំច្បាស់ណាស់ ១០០ភាគរយតែម្តង។ថ្ងៃនេះ គឺថ្ងៃការគាត់ បាទ រៀបអាពាហ៍ពិពាហ៍នៅជិតផ្ទះ តាឌុច និងទួលស្លែងហ្នឹងឯង។ ហើយឈ្មោះនេះឈ្មោះ តាហ៊ុយ គេហៅ ហ៊ុយស្រែ។ ប្រពន្ធគាត់នេះឈ្មោះ បងគឿន គាត់ជាអ្នកកាត់ដេរនៅអង្គភាព ៧៥ នៅៗទួលទំពូងបាទ។ ប៉ុន្តែអ្នកទាំងពីរនេះ ត្រូវគេសម្លាប់ចោលទាំងពីរដែរ។ ខ្ញុំស្គាល់ច្បាស់ណាស់នេះគាត់ តាហ៊ុយ នេះ ហ៊ុយស្រែ គ្រប់គ្រងនៅតំបន់ព្រៃសទាំងមូល។ ហើយប្រពន្ធគាត់នេះ ជាអ្នកកាត់ដេរនៅ៧៥ នៅទួលទំពូង ខ្ញុំស្គាល់ច្បាស់ណាស់។ ខ្ញុំថតដៃឯងទៀត រៀបអាពាហ៍ពិពាហ៍គាត់។

[១៤:០៥:១១]

**ស៖** តើនេះគឺជារូបថតអាពាហ៍ពិពាហ៍របស់ពួកគាត់ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវលោកព្រះរាជអាជ្ញា។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើអ្នកនៅខាងក្រោយហ្នឹង គឺអ្នកដែលនៅឈរខាងក្រោយដែលមើលទៅហាក់ដូចជាអធិបតីហ្នឹង តើលោកចាំទេថា គាត់ហ្នឹងគឺជាអ្នកណាដែររូបអ្នកនៅខាងក្រោយនោះ?

**ឆ៖** រូបអ្នកនៅពីក្រោយហ្នឹងឈ្មោះ ស្រ៊ី បាទឈ្មោះ ស្រ៊ី។ ឈ្មោះ ស្រ៊ី ហ្នឹងបើនិយាយឲ្យចំទៅ គាត់ជាមនុស្សមួយនៅក្នុងទួលស្លែងហ្នឹងដែរ ការរៀបចំពិធីការ ការរៀបចំពិធីទទួលអី បើប្រៀបធៀបរាល់ថ្ងៃទៅយើងទៅជាអ្នកការងាររដ្ឋបាលសម្រាប់ការងារទួលស្លែងហ្នឹងដែរបាទ។

**ស៖** តើគាត់ហ្នឹងគឺជាអ្នករៀបចំពិធី រៀបការរបស់ ហ៊ុយស្រែ និងប្រពន្ធរបស់គាត់ ឬមួយក៏អ្នកផ្សេងទេជាអ្នករៀបចំពិធីហ្នឹងឲ្យ?

**ឆ៖** បាទ អ្នករៀបចំហ្នឹងគឺ តាឌុច អ្នករៀបចំតែម្តង ការរៀបអាពាហ៍ពិពាហ៍ហ្នឹង តាហ៊ី ក៏តាឌុច រៀបការឲ្យ តាហ៊ុយ ហ្នឹងក៏ តាឌុច ការឲ្យ គឺរៀបអាពាហ៍ពិពាហ៍នៅទួលស្លែង ហើយមានកម្មវិធីជប់លៀងទៀត រូបថត។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

[១៤:០៦:៥៨]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ មេធាវីនាំមុខសូមប្រគល់សិទ្ធិជូនលោក សំ សុគង់ ដើម្បីសួរ ហើយខ្ញុំនឹងអាចសួរបន្តពីលោក សុគង់ ក្នុងរយៈពេលខ្លី។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

សូមអញ្ជើញលោកមេធាវី សំ សុគង់!

**លោក សំ សុគង់៖**

បាទ សូមគោរពអង្គសវនាការ ហើយសូមជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរមួយចំនួន

សួរទៅលោកសាក្សី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក សំ សុគង់៖**

**ស៖** ដំបូងខ្ញុំចង់សួរទាក់ទងទៅនឹងស-២១។ ស-២១ ខ្ញុំចង់ដឹងថាតើ ខ្ញុំចង់បញ្ជាក់ថា តើនរណាខ្លះដែលជាអ្នក -- តើនរណាជាអ្នកចាត់តាំងលោកឲ្យមកធ្វើការនៅស-២១ ក្រោយពីលោកមកពីរៀនប្រទេសចិនវិញ?

[១៤:០៨:០៤]

**លោក ញ៉ែម អេន៖**

**ឆ៖** បាទ សូមជម្រាបលោកមេធាវី ទី១ ឯកឧត្តម សុន សេន រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃរបបកម្ពុជាប្រជាធិបតេយ្យ។ ទី២ អ៊ំណាត អគ្គសេនាធិការភ្នំពេញនៃកងទ័ពកម្ពុជាប្រជាធិបតេយ្យ។ ទី៣ ទៀត បងពីន – អ៊ំពីន គាត់ជាជំនួយការ ហើយក៏ជាអតីតកងពល៧០៣ នៅសម័យនោះបាទ។

**ស៖** នៅពេលដែលលោកធ្វើការនៅស-២១ហ្នឹង តើលោកអាចរៀបរាប់បានទេថា នៅទីតាំង ស-២១ ហ្នឹងតើមានអគារអីខ្លះ ឬក៏មានផ្នែកអីខ្លះនៅក្នុងស-២១ហ្នឹង?

**ឆ៖** ខ្ញុំសូមជម្រាបលោកមេធាវីបាទ ទាក់ទងនៅក្នុងប្រព័ន្ធ យើងថាប្រព័ន្ធរដ្ឋបាលទៅចុះនៅក្នុងគុកទួលស្លែង មានប្រហែលជា ខ្ញុំចាំបានច្បាស់វាអាចជាង១០ក្រុម។ មានក្រុមតម្កល់ឯកសារ មានក្រុមសួរចម្លើយស្រាល ចម្លើយធ្ងន់ ចម្លើយមធ្យម មានខាងអង្គុលីលេខ មានទាំងខាងថតរូប មានឆ្មាំការពារ មានរក្សាសន្តិសុខជុំវិញហ្នឹង គឺគិតទៅ១០ផ្នែក ដែលខ្ញុំអត់ចាំបាន ប៉ុន្តែអ្នករក្សាទុកឯកសារ វាខុសគ្នាមួយ អ្នកកត់ត្រា មួយរក្សាទុក មួយខាងអង្គុលីលេខ ជាងថត ឆ្មាំការងារ គិតទៅមាន១០ផ្នែកនៅក្នុងគុកទួលស្លែងហ្នឹងបាទ។

**ស៖** បាទ សូមអរគុណ។ មួយទៀតខ្ញុំចង់សួលោកទាក់ទងទៅនឹងរថយន្ត។ នៅពេលដែលគេបញ្ជូន គេដឹកមនុស្សមកពី តើគេដឹកមនុស្សតាមរថយន្តមកទួលស្លែងហ្នឹង តើគេដឹករថយន្តហ្នឹង រថយន្តម៉ាកអី ហើយពណ៌អីរថយន្តហ្នឹង?

[១៤:១០:០៣]

**ឆ៖** បាទ លោកមេធាវីសូមជម្រាបផងដែរ រថយន្តសម័យនោះមាន ហ្សេ.អឹម.សេ, កាត់សង់កាត់ របស់អាមេរិកាំង។ រថនោះ ប៉ុន្តែដែលរថយន្តដឹកនាំអ្នកទោសចូលមកទួលស្លែងនេះ គេក្លែងបន្លំ

លោកមេធាវី គេដាក់សញ្ញាពេទ្យ អត់ដឹងថាអ្នកទោសទេ គេដឹកមកដាក់សញ្ញាពេទ្យ។ ប៉ុន្តែមានឡាន មួយទៀត ឡានពិសេសរបស់អង្គភាព ន.ស.ក ១ហៅថា "នីរសារក្រុង"។ ដូច្នេះ ធម្មតាខ្ញុំឃើញឡាន នេះញាក់សាច់ ឲ្យតែឃើញ ន.ស.ក មកនីរសារក្រុង។ បើប្រៀបធៀបរាល់ថ្ងៃ ដូចកងពិសេសរបស់ រដ្ឋាភិបាលអ៊ីចឹង។ គេដឹកចូលមក គេមានសញ្ញាគេក្លែងបន្លំទាំងអស់ គឺឡាន អត់មានឡានតូចទេ សុទ្ធតែ ឡានឃ្លុប១។ គឺមួយទៀត គេដាក់មានសញ្ញាភូមិភាគបស្ចិម អ្នកទោសដឹកមកពីភូមិភាគបស្ចិម។ បើ ឡានភូមិភាគពាយ័ព្យ គេដាក់មកពីភូមិភាគពាយ័ព្យ។ បើឡានបូព៌ា គេដាក់មកបូព៌ា។ ដូច្នេះ គេស្គាល់ ឡានស្រេច១តែម្តង។ ប៉ុន្តែភាគច្រើន គេធ្វើសញ្ញាពេទ្យ អត់ដឹងថាអ្នកទោស។

**ស៖** ទាក់ទងទៅនឹងឡាន តើខ្ញុំចង់បញ្ជាក់ពីលោកដែរ ថាតើឡានហ្នឹងមានពណ៌ ពណ៌ឡានដែល ដឹកអ្នកទោសមកហ្នឹងមានពណ៌ឡានពណ៌អី ហើយឡានហ្នឹងមានម៉ាកអ្វីខ្លះ?

**ឆ៖** បាទ លោកមេធាវី ឡានហ្នឹងគឺឡានពណ៌ត្រីអ៊ី ឡានពណ៌ទាហាន ហើយឡានគេដាក់ឃ្លុប អាឃ្លុបយើងជិត១តែម្តង។ ហើយពណ៌ គឺអត់មានពណ៌ក្រៅពីពណ៌ទាហានហ្នឹងទេ ប៉ុន្តែបើអ្នកដឹកអ្នក ពិសេស១ គេមានឡានក្រុងនេះមួយទៀត មានឡានក្រុង ប៉ុន្តែឡានក្រុមកម្រចូលមកណាស់ បាទឡាន ក្រុង។ ប៉ុន្តែឡានទាហាន៩០ភាគរយ គឺឡានទាហានដឹកយកមក និងឡានតូច១។ ឡានតូច១ពិសេសគេ បាទ ដូចថាទៅចាប់នៅកំពង់សោមអ៊ីចឹង គេមានឡានតូច១គេដឹកយកមក។

[១៤:១២:០៤]

**ស៖** លោក ១សាក្សីលោកអាចពិពណ៌នាបានទេ នៅពេលដែលគេដឹកមនុស្ស នៅពេលដែលគេដឹក មនុស្សដល់ស-២១ហ្នឹង ហើយនៅពេលដែលអ្នកដែលដឹកមកហ្នឹង ត្រូវចុះពីលើឡាន ឬក៏គេយកចេញពី លើឡាន តើលោកមានបានឃើញថា តើគេធ្វើអីខ្លះចំពោះពួកគាត់?

**ឆ៖** បាទ លោកមេធាវី ដែលខ្ញុំបានឃើញដឹកមក ជួនកាលយើងចាប់ស្គាល់ យើងដាក់អីសារ មន្ទីរទួលស្លែង ជួនកាលឡានបួនដប់ម្ភៃគ្រឿងតម្រៀបគ្នាអ៊ីចឹងមក។ ជួនកាលការធ្វើទៅលើពួកគាត់ ហ្នឹង ជួនកាលអ្នកទោសខ្លះគាត់ស្រែកជយឃោស។ បាទស្រែកជយឃោសថា ជេរសុទ្ធអាក្បត់ជាតិ អា ក្បត់បដិវត្តន៍ អញខំរើចក្រពត្តិអាមេរិកាំង រំដោះប្រទេសជាតិឲ្យផុតពីសង្គ្រាមដ៏ព្រៃផ្សៃ រឿងអីមកចាប់ អញដាក់គុកអ៊ីចឹង។ មានសកម្មភាពជាច្រើន ប៉ុន្តែដូច ជួនកាលគេចងមាត់ដែរ មានខ្ញុំឃើញ ជួនកាល គាត់ស្រែកជយឃោសយកម្តង។ ដូច្នេះខ្ញុំឃើញសកម្មភាពច្រើនដែរ ប៉ុន្តែវាមិនអាចទៅជាទ្រង់ទ្រាយ ព្រោះដៃគាត់ជាប់ខ្នោះ ចងមុខ។ គាត់មានសកម្មភាពដូចលោកមេធាវីសួរអ៊ីចឹង គឺមានច្រើនដែរ។

**ស៖** ទាក់ទងទៅនឹងសកម្មភាព អ្វីដែលលោកបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំអំមិញហ្នឹង គឺសកម្មភាពរបស់អ្នកដែលគេចាប់មក។ ចុះទាក់ទងទៅនឹងឆ្មាំគុក ឬក៏អ្នកដែលធ្វើការនៅស-២១ តើគាត់មានធ្វើសកម្មភាពអីខ្លះនៅពេលដែលអ្នកដែលត្រូវបានគេដាក់មកហ្នឹង នៅពេលដែលចុះពីលើឡានហ្នឹង?

[១៤:១៣:៥០]

**ឆ៖** បាទ លោកមេធាវី ខ្ញុំស្គាល់ច្បាស់ណាស់ អ្នកនៅក្នុងស-២១ នេះ។ ពួកនេះសុទ្ធតែរៀនស្វាន់ដូ ការ៉ាត់តេទាំងអស់។ ខ្ញុំមានរូបភាពហ្នឹងហើយ អាគេវ៉ៃ អាពេលល្ងាចឡើងគាត់នាំគ្នារៀនលើផ្ទះថ្ម គាត់ហាត់ស៊ីដូ ការ៉ាត់តេ។ ដូច្នេះអ្នកទោសមួយៗ គឺទាត់បាក់ៗថ្គាមក៏មានដែរ។ យើងថា គាត់រៀនបច្ចេកទេសស្វាន់ដូ ការ៉ាត់តេ ហើយការរៀនរបស់គាត់នេះ គឺគាត់មើលតាមកុនរបស់ជប៉ុន របស់កូរ៉េរបស់ថៃ។ ដល់អ៊ីចឹង ដល់ពេលយកអាបច្ចេកទេសគេមក គឺអ្នកទោស សកម្មភាពដែលគាត់មានបញ្ហា គឺពួកនេះគឺខ្លាំងណាស់។ ក៏ក្រុម តាហ៊ុយ បាទក្រុមតាហ៊ុយហ្នឹង គឺពួកស៊ីនៅតែម្តង អត់បានទេ អ្នកទោសតែកម្រើក តែគ្រឹបៗហើយ។ អានេះវាជាការពិតដែលខ្ញុំឃើញសកម្មរបស់ពួកឆ្មាំគុកហ្នឹង គឺមានការវ៉ៃដំច្រំធាក់ ជួនកាលដូចខ្ញុំថាអំមិញអ៊ីចឹង។ ថ្ងៃមួយនោះ សូមជម្រាបលោកប្រធានឲ្យដឹង លោកមេធាវីថា កាលនុំងរោងសហករណ៍មួយនៅជិតកន្លែងបាយហ្នឹង នៅជិតអាផ្លូវកែងហ្នឹង ចាក់មីក្រូទៅស្រែកពេញគុកទាំងអស់ ស្រែកពេញគុក ស្រែកជយឃោសពេញគុក។ ដល់អ៊ីចឹងគេឲ្យឈប់ចាក់មីក្រូទៅ។ ដូចគាត់ឈឺចាប់ណាស់ អញខំវ៉ៃចក្រពត្តិអាមេរិកាំងចង់ងាប់ រឿងអីមកចាប់អញដាក់គុកសម្លាប់ចោល។ អាហ្នឹងវារឿងច្រើនណាស់នៅទួលស្លែងមានរឿងច្រើន។ ហើយតែសកម្មភាពមួយទៀត ខ្ញុំប្រាប់លោកមេធាវីថា អ្នកទោសដាក់ដែលដាក់ក្នុងទួលស្លែងហ្នឹង ដាក់អ្នកថាល្មមៗទេ ប៉ុន្តែអ្នកធំៗដាក់អគារខាងក្រៅទាំងអស់ គេមានគុកពិសេសគេមួយបន្ទប់ៗ។

**ស៖** សំណួរមួយទៀតពាក់ព័ន្ធទៅនឹងការបញ្ជូនឯកសារ តើលោកអាចរៀបរាប់បានទេថា នៅមន្ទីរ២១ ហ្នឹងគឺថាទួលស្លែងហ្នឹង តើការបញ្ជូនឯកសារ តើគាត់បញ្ជូនឯកសារពីៗទួលស្លែងទៅណា? ហើយបញ្ជូនទៅនរណាគេ?

[១៤:១៥:៤៤]

**ឆ៖** បាទ ការបញ្ជូនឯកសារនេះ ខ្ញុំឃើញច្បាស់ ៗហើយច្បាស់ទៀត ឯកសារគឺមាន ស្ងួស ធីគាត់អ្នកធ្វើឯកសារ អ្នកទោសសម្លាប់ប៉ុន្មាន អ្នកទោសចូលប៉ុន្មាន អាហ្នឹងមួយ។ ពីរទៀតឯកសារទាំងអស់បញ្ជូនទៅឲ្យ តាឌុច តើឈ្មោះណាខ្លះដែលត្រូវសួរចម្លើយស្រាល ចម្លើយធ្ងន់។ ឯកសារទាំងអស់

នេះ អ្នកសំខាន់ៗគឺបញ្ជូនទៅ តានឿន និង តាប៉ង់។ តានឿន, តាប៉ង់ នេះបើប្រៀបធៀបសម័យនេះគាត់ប្រធាននីរសារក្រុងនៅភ្នំពេញតែម្តង បើយើងនិយាយឧទាហរណ៍សព្វថ្ងៃប្រើស្មើអង្គរក្ស ដូចថា ហ៊ីង ប៊ុនហៀង អ៊ីចឹងឧទាហរណ៍ណា។ ប៉ុន្តែការគ្រប់គ្រងឯកសារនោះ គឺបញ្ជូនឲ្យប៉ុល ពត ទាំងអស់ ខ្ញុំឃើញយកគូបៗទៅ។ ប៉ុន្តែឯកសារណាដែលឃើញស៊ីញេក្រហាមមកវិញ ឬក៏ស៊ីញេប្លែក អ្នកទោសហ្នឹងសុទ្ធសឹងតែសម្លាប់ចោលតែម្តង។ នេះជាការពិត ឯកសារគឺមានដំណាក់កាលរបស់គាត់ផ្ញើ អត់មានផ្ញើទៅតាមអ្នកណាផ្ដេចផ្ដាចបានទេ សុទ្ធតែអ្នកសំខាន់ៗណាស់បានទទួលឯកសារពីទួលស្លែងទៅបាន។ ជាពិសេស សុន សេន អ្នកទទួលផ្ទាល់ក៏មាន គ្នាគាត់មកយក។ នេះជារឿងពិត លោកមេធាវី។

**ស៖** នៅក្នុងៗសម័យនោះ តើលោកមានធ្លាប់បានថតរូបដែលគេធ្វើមីទ្ទីងនៅស្តាតអូឡាំពិកទេ?

**ឆ៖** បាទ លោកមេធាវី ខ្ញុំបាទបានថតជាច្រើនៗរយប៉ុស្តិ៍ដែរ នៅធ្វើមីទ្ទីង ធ្វើមហាសន្និបាតបក្ស ធ្វើមហាសន្និបាតកងទ័ព ឬក៏ប្រជុំសំខាន់ៗ គឺមានថតជាច្រើននៅស្តាតអូឡាំពិក ធ្វើមីទ្ទីងបាទ។

**ស៖** បាទសូមអរគុណ។ ហើយនៅពេលដែលលោកទៅធ្វើការថតរូបនៅពេលដែលគេធ្វើមីទ្ទីងដូចជានៅស្តាតអូឡាំពិក។ តើនៅក្នុងមីទ្ទីងហ្នឹង លោកអាចរៀបរាប់បានទេថា នរណាជាៗគណៈអធិបតី ហើយនរណាជាអ្នកនិយាយ ហើយគេនិយាយពីអ្វីខ្លះនៅពេលមីទ្ទីងហ្នឹង?

[១៤:១៧:៥៥]

**ឆ៖** បាទ លោកមេធាវី ការធ្វើមីទ្ទីងហ្នឹង ទី១ គឺអ៊ំប៉ុល ពត, ទី២ គឺអ៊ំនួន ជា ហើយទី៣ ក៏មាន សុន សេន ដែរ។ ខ្ញុំឃើញភាគច្រើនមានតែ អ៊ំសុន សេន មួយគាត់ទៅធ្វើជាគណៈអធិបតី ព្រោះគាត់បញ្ជាបញ្ជាការកងទ័ពផង ហើយគាត់ជារដ្ឋមន្ត្រីក្រសួងការពារជាតិសម័យនុ៎ង ហើយការនិយាយរបស់គាត់ទី១ បើអ៊ំ ប៉ុល ពត គាត់និយាយឡើងក៏ ទី១ ត្រូវតែរក្សាពីបូរណភាពទឹកដី រក្សាពីដែលបានរំដោះថ្ងៃ១៧ មេសា ពីចក្រពត្តិអាមេរិកាំង។ ហើយឲ្យប្រជាជនកម្ពុជាទាំងអស់កសាងកសិកម្មសម័យពី១៥ឆ្នាំ ទៅ២០ឆ្នាំ នេះៗដែលការខ្ញុំស្តាប់បាន។ ហើយសំខាន់បំផុតគឺការពារបូរណភាពទឹកដី ទាំងកើតទាំងលិច។ អានេះគឺជាការពិត។ ហើយឲ្យពង្រឹងនូវ គេថាសន្តិសុខជាតិ កាលហ្នឹងគាត់យកសន្តិសុខជាតិនៅក្នុងគុកទួលស្លែងជាសន្តិសុខជាតិទី១ និងព្រលានយន្តហោះនៅខាង តាម៉េត នោះជាទី២។ ដូច្នេះគាត់យកចិត្តទុកដាក់ណាស់នៅក្នុងសន្តិសុខទួលស្លែងនេះ ព្រោះគាត់ច្បាស់អារឿងបញ្ហាហ្នឹងតែម្តង។

**ស៖** សំណួរៗចុងក្រោយរបស់ខ្ញុំ គឺពាក់ព័ន្ធទៅនឹងត្រពាំងថ្ម។ លោកបានឆ្លើយរួចហើយ ទាក់ទងនឹងលោកទៅថតរូបនៅត្រពាំងថ្ម។ លោកថាទៅថតរូបត្រពាំងថ្ម លោកធ្លាប់ទៅត្រពាំងថ្មចំនួន

បីដង។ តើលោកអាចរៀបរាប់បានទេថា បីដងហ្នឹង តើនៅឆ្នាំណា នៅខែណា ដែលលោកទៅលើកទី១? ហើយលើកទី២ ឆ្នាំណាខែណា? ហើយលើកទី៣ ឆ្នាំណាខែណា?

**ឆ៖** បាទ លើកទី១ ខ្ញុំទៅចុងឆ្នាំ៧៦ ក្នុងហ្នឹងវាធ្លាក់ខ្យល់ដូចរាងរងារដែរ យកខែ១២ហ្នឹងឯង បាទ។ ហើយទី២ទៀត ខ្ញុំទៅទី២ ខ្ញុំទៅថតកុន បាទថតកុន។ ទៅថតកុនហ្នឹងគឺខ្ញុំធ្វើដំណើរថតកុនរហូតតាំងពីកំពង់ធំទៅដល់សៀមរាប ទៅដល់អាងត្រពាំងថ្មតែម្តង។ ទី៤ អំទី៣ ខ្ញុំទៅហ្នឹងពាក់កណ្តាលឆ្នាំ៧៨។ ឆ្នាំ៧៨ គឺទៅមើលការលើកទំនប់ហ្នឹងហើយៗ ទៅលើកហើយ ក៏ថតមក បានចុះទស្សនាវដ្តីហ្នឹង បាទ។

[១៤:២០:១៦]

**ស៖** បាទ សូមអរគុណ។ ហើយសំណួរនេះ សំណួរចុងក្រោយរបស់ខ្ញុំដែរ ខ្ញុំចង់ឲ្យលោករៀបរាប់បានទេ ថានៅពេលដែលលោកទៅអាងត្រពាំងថ្មទាំងបីលើកហ្នឹង តើលោកអាចរៀបរាប់ពីស្ថានភាពរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងអាងត្រពាំងថ្ម តើមានស្ថានភាពបែបម៉េចដែរ?

**ឆ៖** ខ្ញុំឃើញសកម្មភាពរបស់សហករណ៍ អាហ្នឹងវាជួនកាល គេឃើញពួកខ្ញុំទៅអ៊ីចឹង ឃើញដូចថា អ្នកកាសែតទៅចុះសម័យនោះ មានកាសែតមានតែមួយទេបង មានតែកាសែតបដិវត្ត ទស្សនាវដ្តីបដិវត្ត តែពីរហ្នឹងឯង។ ដូច្នេះទៅឃើញគេទទួលបាយ ទទួលទឹកខ្ញុំ ហើយមានគេកាប់ដូង កាប់អីញ៉ាំអ៊ីចឹងទៅ ក៏មានប្រជាពលរដ្ឋស្អាតៗ មកទទួលយើងស្លៀកពាក់ស្អាត។ ប៉ុន្តែជាអាថ៌កំបាំងទេ ខ្ញុំដឹងថាអាថ៌កំបាំង ការរៀបចំរបស់សហករណ៍នៅតំបន់ហ្នឹងទេបាទ។ ប៉ុន្តែការស្គមស្គាំងដែលប្រជាជនអត់បាយ ខ្ញុំដឹងថាអត់បាយទៅហើយ ខ្ញុំដឹងៗ។ ជួនកាលពេលខ្លះខ្សឹបប្រាប់ ដល់ពេលខ្ញុំឃើញសកម្មភាពទទួលខ្ញុំ មើលទៅដូចជាសកម្មភាពមួយគេទទួលអង្គការ បានន័យថា ខ្ញុំតំណាងអង្គការអ៊ីចឹង។ ហើយក៏មាន អ៊ំសុន សេន ទៅដែរ។ សុទ្ធតែឋានៈខ្ពស់ៗដែរ គណៈតំបន់ ដូចជាគណៈភូមិភាគ រស់ ញឹម អ៊ីចឹងទៅណា។ គេទទួលយើងសមរម្យណាស់ ប៉ុន្តែលក្ខណៈ ខ្ញុំមើលទៅសកម្មភាពហ្នឹង មើលទៅដូចជាល្អប្រសើរបាទ។ ប៉ុន្តែវិលត្រឡប់ទៅក្រោយវិញ មិនដឹងជាអាថ៌កំបាំងអី ខ្ញុំមិនដឹងដែរ អាហ្នឹងវា ព្រោះកិច្ចការក្នុងប្រទេសទាំងមូល យើងដឹងមិនអស់ទេ សូមទោស។

[១៤:២១:៤០]

**លោក សំ សុគង់៖**

បាទ សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ លោកប្រធាន។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរបន្ថែមខ្លីៗទេ ដើម្បីសួរលោកសាក្សី។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ សូមគោរពលោកសាក្សី។ សូមជម្រាបសួរ ខ្ញុំបាទឈ្មោះ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ជាមួយលោកស្រី ម៉ារី ហ្គីរ៉ូដ៍។ យើងតំណាងក្រុមរួមនៃដើមបណ្ដឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះ។ ខ្ញុំចង់សួរបញ្ជាក់បន្ថែមបន្តិច នៅលើបញ្ហាឡានរបស់ ដែលលោកបានឃើញហ្នឹង ជាពិសេសពាក់ព័ន្ធទៅនឹងឡានរបស់ ស-២១ ដែលលោកបានមានប្រសាសន៍ថា ពេលខ្លះគឺឡាន ស-២១ ដឹកអ្នកទោសចូលមកតែម្ដង ស-២១។ តើលោកអាចបញ្ជាក់ទេ ឡាននុំង គឺឡានមានលក្ខណៈយ៉ាងម៉េច លោកអាចរៀបរាប់ពីឡានហ្នឹងបានទេ? ឡានរបស់ស-២១ណា បាទពណ៌ ឬក៏ម៉ាក ធំ តូច បាទសូមអញ្ជើញ!

**លោក ញ៉ែម អេន៖**

**ឆ៖** បាទ លោកមេធាវី ឡាននៅក្នុងស-២១នេះ ខ្ញុំឃើញឡាន អាឡានយើងរបស់អាមេរិកាំង អាតូចៗហ្នឹង ហៅអី អាបើកម៉ាក អាហ្ស៊ីប មានបីគ្រឿង ហើយមានកាត់សង់កាត់ហ្នឹង មានកាប៊ីនបួនប្រាំគ្រឿង ហើយមានអាឡានឡង់វ៉ែរ អាហ្នឹងឡានឡង់វ៉ែរគឺដឹក បាទដឹកអ្នកទោស ដូចជាសំខាន់ៗទៅចាប់តាមភូមិភាគអី គឺបក្សក្រុម ហ៊ុយ ហ្នឹងហើយទៅ គេទៅចាប់។ ប៉ុន្តែឡានហ្សេ.អឹម.សេ ក៏មានបួនប្រាំគ្រឿងដែរ។ ហើយចំណតឡានហ្នឹង គេដាក់មុំយើងរាល់ថ្ងៃហ្នឹង កន្លែងឡានទឹកហ្នឹង មួយជួរហ្នឹងហើយមួយជួរឡានទឹកទៅដល់ថ្នល់ជាតិ សុទ្ធតែកន្លែង បើនិយាយទៅអង្គភាពស-២១ទាំងអស់ សំខាន់ៗ។ ហើយឡានសរុបទៅដែលខ្ញុំដឹង ឃើញទាំងអស់មិនក្រោម២០គ្រឿងទេ ទាំងតូចទាំងធំ។ អាធំៗសម្រាប់ដឹកអ្នកទោសចេញចូលអីចឹងទៅ។ ហើយប៉ុន្តែចំណែកមួយទៀត ឡានទាំងអស់នេះគឺប្រើប្រាស់តែក្នុង ស-២១ នេះតែម្ដង។

[១៤:២៣:៤៥]

**ស៖** តើឡានទាំងអស់នោះ ធ្លាប់ដឹកអ្នកទោសចូលមកញឹកញាប់ដែរឬទេ?

**ឆ៖** បាទ ឡានដែលខ្ញុំឃើញដឹក ដឹកមកចង់រាល់ថ្ងៃហើយ ជាស្ទើរនឹងរាល់ថ្ងៃ ប៉ុន្តែតិច និងច្រើន អាឡានឡង់វ៉ែរ អាដាក់បួនប្រាំនាក់ហ្នឹង បាទ ជួនកាលឃើញយកឡានហ្ស៊ីបមកម៉ាកមួយ ប៉ុន្តែពេលយប់។ បើជួនកាលដឹកច្រើនអីចឹងមក ដូចជាដឹកទៅពីព្រលានកំពង់ឆ្នាំងក៏មាន ដឹកពីតំបន់ដូចលោក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01247212



សួរអំមិញហ្នឹង នៅត្រពាំងថ្ម តំបន់៥ហ្នឹង គឺតំបន់៥ ដឹកមកច្រើនជាងគេ ដែលខ្ញុំឃើញ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងខ្ញុំចង់ចូលទៅចំណុចមួយទៀត នៅស-២១ដដែល អំពីបញ្ហាពេទ្យ។ ថាតើនៅស-២១ហ្នឹង មានពេទ្យព្យាបាលដែរឬទេ? ហើយបើព្យាបាល គាត់ព្យាបាលអ្នកណាខ្លះ បុគ្គលិករបស់ ស-២១? តើអ្នកទោស គាត់ព្យាបាលដែរឬទេ?

**ឆ៖** បាទ បើជាផ្នែកពេទ្យវិញ ខ្ញុំស្គាល់ច្បាស់ណាស់ ឈ្មោះ បងប៉ោល បាទឈ្មោះ បងប៉ោល គឺគាត់ជាពេទ្យមើលការខុសត្រូវអ្នកទោសហ្នឹងផង ហើយគាត់មើលការខុសត្រូវបុគ្គលិកហ្នឹងផង។ ប៉ុន្តែជាអកុសលរបស់គាត់ គឺថា តាឌុច បញ្ជាវាយចោលដែរបាទ។ គេចោទថាគាត់ សេ.អ៊ី.អា។ គាត់ស្លាប់ហើយបាទ ឈ្មោះ ប៉ោល។

**ស៖** តើពេទ្យនោះគាត់មានជំនួយការពេទ្យដែលជួយគាត់ដែរទេ? ឧបមាថាកិច្ចការផ្សេងៗចែកថ្នាំអីជាដើម តើមាន គាត់មានជំនួយការពេទ្យដែរឬទេ?

**ឆ៖** បាទ ខ្ញុំឃើញពេទ្យនៅក្នុងស-២១ហ្នឹង ដូចជាអត់មានតម្លាភាព តុល្យភាពទេបាទ មានតែម្នាក់គត់ ខ្ញុំឃើញឈ្មោះ ប៉ោល ដែលថាគេយកទៅវាយចោលហ្នឹង។ ប៉ុន្តែដូចជាអ្នកជំងឺ ជំនួយការគាត់អត់មានទេ ប៉ុន្តែពេលដែលអ្នកទោស អំពេល! អត់និយាយអ្នកទោស ថាអ្នកបុគ្គលិកស-២១ ឈឺហ្នឹងគឺមានអង្គភាពរបស់គេមួយហៅថាពេទ្យដែលមាននៅ ព-៩៨។ ព-៩៨ ហ្នឹងគេដាក់សម្រាប់ដាក់កងទ័ពអគ្គសេនាធិការ និងមន្ទីរជុំវិញហ្នឹងឯង មានពេទ្យខុសគ្នា។ ជំនួយការអត់ គាត់មានតែឯងទេ ទួលស្លែងអត់មានពេទ្យផង ឃើញឈ្មោះ ប៉ោល ហ្នឹងមួយបាទ។ អត់ស្គាល់ត្រកូលគាត់។

[១៤:២៦:០៩]

**ស៖** អ៊ីចឹងនៅពេលដែលអ្នកជំងឺឈឺ ឬថាអ្នកជាប់ទោស អ្នកទោសគាត់ឈឺ ថាតើមានអ្នកណាគេអ្នកផ្សេងទៀត ដើរចែកថ្នាំទៅអ្នកទោសដែរឬទេ? ឬមួយក៏ពេទ្យហ្នឹងជាម្នាក់ឯងធ្វើការងារទាំងអស់ហ្នឹង ចំពោះអ្នកទោសដ៏ច្រើនហ្នឹង?

**ឆ៖** បាទ ដែលខ្ញុំជាជាងថតរូបនៅគុកទួលស្លែង ដែលខ្ញុំពិនិត្យមើលឃើញទៅ អ្នកទោសបាទ អ្នកទោសដែលជាប់ហ្នឹង ការព្យាបាលខ្ញុំថាឲ្យហ្សេរ៉ូតែម្ដងទៅ។ វាដូចថាអ្នកទោសដូចវាស្លាប់ទៅហើយ ខ្ញុំអត់ឃើញផង តិចណាស់។ ប៉ុន្តែពេលដែលការមានវាយដំច្រំធាក់ពីឆ្នាំគុកសួរចម្លើយទៅ គាត់មានការយកទៅ ដូចថាគ្នា វ៉ៃធ្ងន់អ៊ីចឹងទៅ ក៏មានលោក ប៉ោល ហ្នឹងឯងដែលគាត់ទៅព្យាបាលអីអ៊ីចឹងទៅ។ ប៉ុន្តែ៩០ភាគរយ ស្ទើរ១០០ភាគរយគ្មានទេបាទ និយាយ អត់ៗ គ្រាន់តែទៅមើលលក្ខណៈមើល

ហ្នឹង សម័យនោះដូចអត់មានថ្នាំអីផង។

**ស៖** បាទ អរគុណច្រើនចំពោះការបំភ្លឺពីបញ្ហានេះ។ ខ្ញុំចង់សួរចំណុចមួយទៀតដែលបន្តពីសហព្រះរាជអាជ្ញាដែលគាត់សួរចំណុចចុងក្រោយគេ។ អំពីការរៀបការដែលលោកបានមានប្រសាសន៍អំម្បាញ់មិញ តំណាងសហព្រះរាជអាជ្ញាបានបង្ហាញរូបថតមួយជូនលោកហើយ អំពីការរៀបការរបស់ហ៊ុយស្រែ។ ហើយនៅក្នុងឯកសាររបស់លោក ដែលលោកបានចែកនៅព្រឹកមិញនេះ គឺមានទំព័រ៣២ នៅក្នុងនោះ គឺមានកម្មវិធីហូបជួបជុំគ្នា។ ថាតើ នៅក្នុងនេះខ្ញុំឃើញសរសេរថាជាកម្មវិធីសម្រាប់គូស្វាមីភរិយាថ្មី។ ខ្ញុំចង់សួរថា តើនេះជាកម្មវិធីតែមួយ ឬក៏ជាកម្មវិធីរៀបការផ្សេងគ្នា?

[១៤:២៨:៣៣]

**ឆ៖** បាទ ការទទួលទានអាហារនេះ គឺផ្ទះ តាឌុច តែម្តង នៅថ្ងៃរៀបអាពាហ៍ពិពាហ៍ ហ៊ុយស្រែ រៀបអាពាហ៍ពិពាហ៍ ហ៊ុយស្រែ ហ្នឹងរូបភាពហ្នឹងហើយ នេះៗ តាហ៊ុយ អង្គុយចុងនេះ។ ហ្នឹងឯងរូបភាពនេះមាន តាឌុច ឈរ គាត់ដើរក្រឡឹងមើល ហើយមានមិត្តភក្តិខ្ញុំ សុង ថត ខ្ញុំថតផ្ទប់គ្នាហ្នឹង មានរូបថត ជាងថតផ្ទប់ ខ្ញុំថតពីកើត គេថតពីលិច។ នេះជាការពិតបង នេះជប់លៀងថ្ងៃរៀបអាពាហ៍ពិពាហ៍ តាហ៊ុយស្រែ ហ្នឹងឯង។

**ស៖** បាទ អរគុណច្រើន។ ខ្ញុំចង់សួរលោក តើលោកស្គាល់គូស្វាមីភរិយាដែលរៀបការនៅថ្ងៃនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំសួរច្បាស់ណាស់ បងស្រីឈ្មោះ គឿន បាទឈ្មោះ បងគឿន ហ្នឹងគឺពីដើមមកគាត់ជាកងទ័ពវរសេនាតូចខ្លាំងដែរ។ ដល់ក្រោយមកអង្គការបានចាត់តាំងគាត់មកនៅកាត់ដេរ៧៥ នៅទួលទំពូង ក្រោយមកគាត់បានការជាមួយ បងហ៊ុយ ហ្នឹងឯង ឈ្មោះ គឿន។ ប៉ុន្តែអ្នកទាំងអស់ភាគច្រើនខ្ញុំអត់ស្គាល់ទេ ប៉ុន្តែខ្ញុំស្គាល់តែ បងគឿង ហ្នឹងមួយបង ដែលឈរអាពាហ៍ពិពាហ៍ជាមួយ តាហ៊ុយ ហៅ ហ៊ុយស្រែ ហ្នឹង។

**ស៖** បាទ អរគុណ។ អ្នកដែលលោកស្គាល់អំម្បាញ់មិញ ថាតើពួកគាត់ទាំងពីរនាក់ហ្នឹង ពីមុនគាត់ធ្លាប់ស្គាល់គ្នាដែរឬទេ មុនពេលការ?

[១៤:២៩:៥៨]

**ឆ៖** បាទ លោកមេធាវី ខ្ញុំទទួលស្គាល់ថាគាត់ស្គាល់។ ព្រោះ បងគឿន នេះ គាត់នៅក្នុងកងទ័ពនារី ក្នុងកងពល៧០៣ និងវរសេនាធំ០៩។ ប៉ុន្តែ តាហ៊ុយ នេះនៅក្នុងកងពល៧០៣ដូចគ្នា កាលពីធ្វើ

សង្គ្រាមណ៎ា។ ដល់ពេលក្រោយមក គឺអង្គការបានផ្គូផ្គងគ្នាទៅ ទៅជា បើខ្ញុំអត់ដឹងប្រវត្តិ ហ៊ុយស្រែនៅឯណាទេ ប៉ុន្តែដល់ពេលមកធ្វើការនៅនឹងទួលស្លែងហ្នឹង គាត់មានរឿងទៀត អ៊ីចេះបាទ មានរឿងរហូតដល់គេយកគាត់ទៅវ៉ៃចោល។

**ស៖** បាទ អរគុណ។ ខ្ញុំចង់សួរលោក ឲ្យបញ្ជាក់ថាតើទាំងករណីគូស្វាមី ហ៊ុយស្រែ ទាំងករណីអ្នកផ្សេងៗទៀតដែលជាគូស្វាមីភរិយាហ្នឹង តើពួកគាត់ហ្នឹងដែលគេៗ អង្គការ លោកមានប្រសាសន៍អម្បាញ់មិញថាគេរៀបចំ រៀបការជូនហ្នឹង ថាតើពួកគេរៀបការដោយស្ម័គ្រចិត្តអត់ទេ? ពួកគាត់ហ្នឹងគាត់ស្ម័គ្រចិត្ត ដោយការស្រឡាញ់គ្នាដែរទេ លោកអាចដឹងពីបញ្ហាហ្នឹងដែរទេ?

**ឆ៖** បាទ ខ្ញុំបានជួប បងគឿន នៅកន្លែងកាត់ដេរ៧៥ គាត់អត់សប្បាយចិត្តដែរទេ ប៉ុន្តែកាលនោះគឺអង្គការចាត់តាំងហើយ ឲ្យយក គឺយក មិនយកគេវ៉ៃចោលហ្នឹងឯង។ ប៉ុន្តែធ្វើម៉េចអាពាហ៍-ពិពាហ៍ដោយការបង្ខំ ដូចថាអត់ការស្រឡាញ់ ប៉ុន្តែធ្វើម៉េចរបបហ្នឹង បើលោកមេធាវីដឹងហើយសម័យហ្នឹងគ្មាននរណាអាចប្រកែកបានទេ។

[១៤:៣១:២៣]

**ប្រធានអង្គជំនុំ៖**

លោកសាក្សី យើងរំឭកម្តងទៀតលោកសាក្សីឆ្លើយ គួរតែឆ្លើយអ្វីដែលលោកដឹងច្បាស់។ លោកដឹងមិនច្បាស់ មិនអាចលើកឡើងៗ លោកឆ្លើយរបៀបសន្និដ្ឋានទេ របៀបការយល់ឃើញផ្ទាល់ខ្លួន អាហ្នឹងគេហៅថាការសន្និដ្ឋាន។ អ្វីដែលលោកដឹងច្បាស់គឺលោកដឹងច្បាស់ បើអត់ដឹង ដោយសារសំអាងហេតុមូលហេតុនៃការដឹងនោះច្បាស់លាស់ណាស់។ ឧទាហរណ៍ថាគ្រាន់តែធ្វើការនៅក្នុងកងពល១១៣ជាមួយគ្នា កងពល១១៣ វាមិនដឹងមានប៉ុន្មានម៉ឺននាក់។ ហើយវាមានមូលហេតុអីគ្រាន់តែ -- បានស្គាល់វាមិនមែនគ្រាន់តែធ្វើការនៅក្នុងកងពល១១៣ សន្និដ្ឋានថាស្គាល់គ្នាទេ ថាស្គាល់បែបនេះគេហៅថាស្គាល់ដោយការសន្និដ្ឋានហើយ។ បានន័យថា បើសិនជាយើងទាល់តែមានដឹងថាគាត់ធ្លាប់ប្រាស្រ័យទាក់ទងគ្នា ធ្លាប់អីៗ អាហ្នឹងបានវាច្បាស់លាស់។ ហើយយ៉ាងណាមិញ គឺចុងក្រោយនេះគឺដូចគ្នា សូមឲ្យលោកផ្តង់ការគិត ការរំឭករបស់យើងឲ្យបានច្បាស់លាស់ ពីព្រោះដើម្បីប្រយោជន៍យុត្តិធម៌ក្នុងការស្វែងរកការពិត រួមវិភាគទានក្នុងការស្វែងរកការពិត ទី១។ ទី២ លោកចាំច្បាស់ថា សក្ខីកម្មរបស់លោកគឺគេនឹងយកទៅផ្ទៀងផ្ទាត់ជាមួយនឹងសក្ខីកម្មសាក្សីដទៃទៀត ដែលមានចំនួនច្រើនដែលនៅអង្គជំនុំជម្រះនឹងកោះហៅមកផ្តល់សក្ខីកម្ម។ ផ្គូផ្គងប្រៀបធៀបគ្នា ដូចអ្វីដែលគេ ភាគីបានយកកំណត់ហេតុស្តាប់សក្ខី-

កម្មសាក្សីដទៃទៀតមកសួរ ផ្អែកជាមូលដ្ឋានក្នុងការតាំងសំណួរសួរបញ្ជាក់លើរូបលោកកន្លងមកហើយ។ អ៊ីចឹងសូមលោកនិយាយកម្រិតត្រឹមតែយល់ដឹងទៅបានហើយ បើថាបង្ខំហ្នឹង គឺថាវាមានមូលហេតុ វាមានស្ពាន វាមានស្អីដែលថាបង្ខំដែលលោកដឹងច្បាស់។ អានេះទាល់តែលោកដឹងច្បាស់ ឮច្បាស់អាហ្នឹងសូមឆ្លើយ ជៀសវាងឆ្លើយស្មានដែលឆ្លើយធ្វើជាសន្និដ្ឋានដោយផ្ទាល់ខ្លួន ដែលទីនេះគេអត់និយាយពីបញ្ហាស្មានទេ។ បាទបើពាក្យ “ប៉ាន់ប្រមាណ” គេប្រើ បើ “ស្មាន”មិនឱ្យនិយាយទេ មិនឱ្យឆ្លើយតប មិនឱ្យសួរទេ។

[១៤:៣៣:២០]

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ លោកសាក្សី អម្បាញ់មិញ លោកមានប្រសាសន៍ថាលោកបានជួប បងគឿន ហើយ បងគឿន បាននិយាយថា គាត់អត់សប្បាយចិត្តនឹងការរៀបការហ្នឹងទេ។ អ៊ីចឹងមែនទេ អាចបញ្ជាក់ឡើងវិញបានទេ?

**លោក ញ៉ែម អេន៖**

**ឆ៖** នេះវាជារឿងពិតមួយ ខ្ញុំបាទ ព្រោះពីៗទូលស្តែងទៅៗកន្លែងកាត់ដេរជិត*(ឮមិនច្បាស់)* ទួលទំពូង ជិតបង្គើយជិតស្ពានទូតចិនហ្នឹង ខ្ញុំបាទជិះកង់រាល់ថ្ងៃតាមហ្នឹងបាទ ដែលជិះកង់ទៅព្រែសទៅអីហ្នឹងបាទ ទៅកាត់តាមៗស្ទឹងមានជ័យហ្នឹង។ ដល់អ៊ីចឹងទៅការរៀបការហ្នឹង ថ្ងៃហ្នឹងគឺយកកាត់ដេរ៧៥ទាំងអស់មករៀបការ។ ក៏ប៉ុន្តែយើងៗសំឡឹងមើលដែលពេលខ្ញុំថតរូបទៅ គាត់ឱនមុខដូចជាគាត់មិនសប្បាយចិត្តសោះ ប៉ុន្តែអានេះជាគិតរបស់ខ្ញុំ បានន័យថាការស្គាល់របស់គាត់ខ្ញុំស្គាល់ច្បាស់គាត់នៅអង្គភាពកាត់ដេរ៧៥ហ្នឹងតាំងពីថ្ងៃទីប៉ុន្មានមក ដូចខ្ញុំដឹងថារៀបចំចុងឆ្នាំ៧៦ហ្នឹង គាត់រៀបកាត់ដេរហ្នឹងឯង។ ដល់អ៊ីចឹងការរៀបការហ្នឹង មិនមែនរៀបការតែមួយគូហ្នឹងទេបង ច្រើន រៀបឱ្យច្រើនបាទ ច្រើន ដូចជាកាលនុ៎ងដូចជា៤០គូបាទ ហើយមានទាំង តាហ៊ា ផង។ តាហ៊ាៗ យើងអនុប្រធានគុកទួលស្លែងហ្នឹងបាទ។ ប្រពន្ធគាត់ក៏នៅកាត់ដេរ៧៥ ដែរ។

**ស៖** បាទ អរគុណ។ លោកអាចបញ្ជាក់ថែមទៀតបានទេ លោកមានស្គាល់គូស្វាមីភរិយាផ្សេងទៀតទេដែលគាត់ធ្លាប់ស្គាល់គ្នាពីមុនមក?

[១៤:៣៤:៥៣]

**ប្រធានអង្គជំនុំ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កុំអាលទាន់! កុំអាលទាន់!

ឆ្លើយ!

**លោក ញ៉ែម អេន៖**

**ឆ៖** ខ្ញុំសូមជម្រាបជូនថា ការស្គាល់របស់ខ្ញុំ ស្គាល់តែពីរគូទេ។ គូទី១ ហ៊ុយស្រែ, ស្គាល់ទី២ ហ៊ុយ អនុគុកហ្នឹងឯង។ តែពីរហ្នឹង ដែលខ្ញុំស្គាល់គាត់។ ប៉ុន្តែក្រៅពីហ្នឹងទៀត ប៉ុន្តែដឹងថា អ្នកមករៀបអាពាហ៍ពិពាហ៍ហ្នឹង នៅកាត់ដេរ៧៥ហើយ ប៉ុន្តែខ្ញុំអត់ស្គាល់ឈ្មោះ។ ខ្ញុំស្គាល់តែ បងគឿន និងប្រពន្ធតាហ៊ា ហ្នឹងមួយ តែពីរគត់ ការចំណោម៤០គូហ្នឹង។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទអរគុណ។ អ្នកគូទី២ ដែលជាអនុប្រធានគុក ដែលលោកមានប្រសាសន៍អម្បាញ់មិញ ខ្ញុំចង់សួរបញ្ជាក់អំពីការស្ម័គ្រចិត្តរបស់គាត់វិញ ថែមទៀតថា តើគាត់រៀបការជាមួយគ្នានោះ គាត់ដោយគាត់ស្រឡាញ់គ្នា ឬក៏ថាស្ម័គ្រចិត្តនៅក្នុងការរៀបការដោយចិត្តនឹងចិត្តដែរឬទេ?

**ឆ៖** បាទ ដូចជាខ្ញុំពិនិត្យឃើញដូចជាការរៀបអាពាហ៍ពិពាហ៍នៅទួលស្លែងហ្នឹង ដូចជាអត់មានការបង្ខំ មានបង្ខិតបង្ខំ គឺតម្រូវអង្គការឲ្យយកគ្នាតែម្តង ឲ្យការតែម្តង ដូចអត់មានបង្ខិតបង្ខំអីផង។ ប៉ុន្តែអ្នកទាំងអស់ព្រម មិនព្រម ជាសិទ្ធិរបស់ពួកគាត់ ប៉ុន្តែវាជាកាតព្វកិច្ចអង្គការចាត់តាំង។ អាហ្នឹងនិយាយឲ្យអស់ទៅ ដូចជាវាមិនវែងឆ្ងាយប៉ុន្មានទេ។

[១៤:៣៦:២៧]

**ស៖** បាទ ចុះលោកមានដឹងថា មានគូណាដែលត្រូវបានអង្គការនៅទួលស្លែងស្នើឲ្យការ ហើយគាត់បានបដិសេធទេ?

**ឆ៖** ខ្ញុំឃើញសកម្មភាពនៅក្នុងដូចអត់។ ដូចជាអត់មានបដិសេធ អត់មានស្អីទាំងអស់ បានន័យថាវា ដូចខ្ញុំថាខាងដើមហ្នឹង យើងបកទៅក្រោយវិញថា គឺអង្គការចាត់តាំងតែម្តង គឺគ្មានប្រែប្រួលទេ អត់។ ហើយអ្នកធ្វើការនៅទួលស្លែង ខ្ញុំឃើញការប្រហែលជាសាមសែសិបគូដែរ ចាស់ៗហ្នឹងបាទ។

**ប្រធានអង្គជំនុំ៖**

អស់ពេលហើយ ណ៎ា។ បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់

សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៧ នាទី ដល់ម៉ោង ១៤:៥៩ នាទី)*

[១៤:៥៩:២០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុនផ្តល់វេទិកាជូនទៅក្រុមជូនទៅក្រុមសហមេធាវីការពារក្តីតាំងសំណួរដេញដោលចំពោះសាក្សីនេះ អង្គជំនុំជម្រះមាន ដោយសារកត់សម្គាល់ឃើញថា លើបញ្ហាពីរ។ ទី១ ដូចជាមានការបង្ហាញអំពីភាពត្រូវការចាំបាច់នៃពេលវេលាមួយចំនួនបន្ថែមពីសំណាក់មេធាវីការពារក្តី គឺលោក វ៉ិចទ័រ កូប៉េ ក្នុងការតាំងសំណួរសាក្សីរូបនេះ។ ហើយទី២ ការឆ្លងកាត់នូវការផ្តល់សក្ខីកម្មរបស់គាត់កន្លងមកនេះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថាមានបញ្ហាជាច្រើនដែលទំនងជាភាគីពាក់ព័ន្ធចង់សួរបញ្ជាក់បន្ថែមឲ្យបានច្បាស់លាស់។ ដូច្នេះអង្គជំនុំជម្រះ សូមសួរទៅលោកក្រុមសហមេធាវីការពារក្តីមុន ថាតើក្រុមលោកត្រូវការពេលវេលាបន្ថែមទំនងប៉ុន្មានដែរ ដើម្បីក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ លោកមេធាវី វ៉ិចទ័រ កូប៉េ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំក្រឡេកទៅមើលសហភាតារបស់ខ្ញុំ អង់តា ហ្គីសសេ គឺថាគាត់<អាចត្រូវការ>ពេល៤៥នាទី អ៊ីចឹងខ្ញុំសូម២០នាទី<ដែលនៅសល់>។ <អ៊ីចឹងខ្ញុំគិតថា -->

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងមិនមានសំណើសុំបន្ថែមពេលវេលាទេ។ ល្អហើយ។

[១៥:០១:១១]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមិនចង់ឲ្យមានបញ្ហាអ្វីទេ គឺវាអាស្រ័យទៅលើរបៀបនៃការឆ្លើយសំណួររបស់សាក្សី ទៅនឹង

សំណួររបស់ខ្ញុំ។ អ៊ីចឹងប្រហែលជាខ្ញុំអាច<ត្រូវការ>ពេល<បន្ថែម>ផង ក៏ថាបាន <>។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ចង់មានសំណួរដែរ។ ហើយឥឡូវសូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងសួរឲ្យបានខ្លីបំផុតតាមដែលអាចធ្វើទៅបាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី តាមរយៈសក្ខីកម្មរបស់លោកមួយថ្ងៃមកនេះ ខ្ញុំយល់ថា លោកមានឯកសារមួយចំនួនធំមកពីស-២១។ តើលោកអាចរៀបរាប់បានទេថា សព្វថ្ងៃហ្នឹងលោកមានឯកសារអ្វីខ្លះនៅក្នុងដៃរបស់លោក? ហើយឯកសារទាំងអស់ហ្នឹង ជាឯកសារអ្វីខ្លះ មានជាហ្វីល រូបថត ហើយជាហ្វីលដែលផ្តិតចេញនៅសម័យនោះ ឬក៏យ៉ាងម៉េច លោកអាចរៀបរាប់បានទេ ឯកសារទាំងអស់ដែលលោកមាននៅសព្វថ្ងៃនេះ ជារូបថត ជាហ្វីល ឬជាឯកសារអ្វីខ្លះ?

[១៥:០២:៤៩]

**លោក ញ៉ែម អែន៖**

**ឆ៖** បាទ អរគុណលោកចៅក្រម។ ឯកសារដែលខ្ញុំមានសព្វថ្ងៃនេះ ទី១ សៀវភៅខ្ញុំនៅរៀនចិន។ ទី២ រូបថតមួយចំនួនដែលខ្ញុំរក្សាទុកបាន ឬក៏ខ្ញុំអាចប្រមូលយកបានដែលការខ្ញុំចងក្រងជាឯកសារដែលរូបភាពនេះពិតៗ។ ហើយសំខាន់ម៉ាស៊ីនថតនៅខ្ញុំរាល់ថ្ងៃ ជាច្រើនគ្រឿង បាទជាច្រើនគ្រឿងដែលភ័ស្តុតាងនៅៗគុកទួលស្លែងតែម្តង។ ហើយបើជាហ្វីល ដូចជាអត់មានទេបង អត់មានសោះ។ បើរូបថតខ្ញុំមាន ឯកសារពាក់ព័ន្ធនឹងទួលស្លែងច្រើន។ ខ្ញុំអាចនិយាយប្រាប់បាន ព្រោះឯកសារខ្ញុំមិនបានយកមក វាមិនអាចអត្ថាធិប្បាយកើត។

**ស៖** តើឯកសារទាំងអស់នុំងមាននៅកន្លែងណា? ខ្ញុំដឹងថា មានឯកសារខ្លះលោកទុកនៅភ្នំពេញខ្លះទៀតនៅសៀមរាប ហើយប្រហែលជាអាចមានឯកសារខ្លះនៅអន្លង់វែង <ឬនៅកន្លែងផ្សេងទៀត>។ អ៊ីចឹងលោកអាចបញ្ជាក់បានទេថា ឯកសារទាំងអស់នុំង លោករក្សាទុកនៅកន្លែងណាខ្លះ?

**ឆ៖** បាទលោក លោកចៅក្រម សព្វថ្ងៃឯកសារនេះនៅផ្ទះខ្ញុំសៀមរាប មួយបាទ នៅជុំគ្នាទាំង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

អស់។ ខ្ញុំកំពុងធ្វើការិយាល័យមួយសម្រាប់ខ្លួនខ្ញុំនៅសៀមរាប។

**ស៖** អ៊ីចឹងឯកសារទាំងអស់ហ្នឹងគឺភាគច្រើន គឺសុទ្ធតែជារូបថតមែនទេ ហើយមានកូនសៀវភៅហ្នឹង មានតែមួយទេ ក្រៅពីហ្នឹង គឺរូបថតទាំងអស់មែនទេ?

[១៥:០៤:៣៨]

**ឆ៖** បាទ លោកចៅក្រម រូបថតក៏មាន ហើយទាក់ទងនឹងចម្រៀងខ្មែរក្រហម ខ្ញុំមានរាប់រយបទទៀត។ ហើយឯកសារមួយចំនួនច្រើនដែរ នៅក្នុងដែលខ្ញុំរក្សាទុកបាន បាទគឺៗពាក់ព័ន្ធ ខ្ញុំនិយាយប្រាប់លោកប្រធាន និងលោកចៅក្រមឲ្យត្រង់ទៅថា កន្លងមកខ្ញុំបាទ ញ៉ែម អេន ចង់ផ្ដល់សក្ខីកម្មដល់តុលាការខ្មែរក្រហមណាស់ ដើម្បីឲ្យកាន់តែច្បាស់ថែមទៀត។ ប៉ុន្ដែពេលនេះ គឺខ្ញុំបាទ សូមទោសផងដូចថាធ្វើការគ្រប់គ្រាន់ មិនគ្រប់គ្រាន់ក៏ដោយ គឺថ្ងៃក្រោយ ខ្ញុំផ្ដល់ព័ត៌មានជូនថែមទៀតសម្រាប់ឲ្យបានជាតុល្យភាពក្នុងតុលាការបាទ។

**ស៖** តើលោកអាចបញ្ជាក់ឲ្យបានច្បាស់បន្ដិចបានទេ នៅពេលដែលលោកនិយាយថា លោកមានឯកសារផ្សេងទៀតនោះ <តើលោកចង់មានន័យថាម៉េច? ខ្ញុំយល់ថា មានរូបថតជាច្រើន ហើយពេលនេះ>លោក<និយាយពី>ចម្រៀង <ហើយ>លោក<ក៏>និយាយ<ដែរថា លោក>មានឯកសារ<>ផ្សេងទៀត។ <តើឯកសារផ្សេងទៀតនោះជាអ្វីដែរ>? <តើយើងកំពុងនិយាយពីរបាយការណ៍ ឬក៏>កំណត់ហេតុកិច្ចប្រជុំ<>? <តើពេលនេះយើងកំពុងនិយាយពីអ្វីឲ្យច្បាស់លាស់ទៅ?>

**ឆ៖** បាទ លោកចៅក្រម ឯកសារនេះ បើនិយាយរឿងកំណត់ហេតុខ្ញុំបាទអត់មានទេ ប៉ុន្ដែអាចមានជាសំឡេង ប៉ុល ពត គាត់និយាយ ដូចជាកាសែតវីដេអូទាក់ទងការប្រជុំ មាន តាម៉ុក មានអ៊ីចឹងគឺខ្ញុំមានវាមិនច្រើនប៉ុន្មានទេ ប៉ុន្ដែអាចទទួលយកបាន ផ្ដល់ដល់សក្ខីកម្មតុលាការខ្មែរក្រហម។

**ស៖** តើលោកអាចជម្រាបបានទេ ចំនួនប្រហាក់ប្រហែល ឧទាហរណ៍ដូចជារូបថតអីអ៊ីចឹងលោកមានប៉ុន្មានសន្លឹកដែរ ឯកសារមានប៉ុន្មានអីប៉ុន្មាន លោកអាចប្រហាក់ប្រហែលបានទេ ប៉ាន់ប្រមាណមើលទៅ?

[១៥:០៦:៣៩]

**ឆ៖** បាទ ចំពោះរូបថត ខ្ញុំបាទមានប្រហាក់ប្រហែលជាង១.០០០សន្លឹក ហ្នឹងមួយ។ ចម្រៀងខ្មែរក្រហមមានប្រហែលចង់ខ្ទង់៥០០បទ ទី២។ ទី៣ទៀត ខ្ញុំមានកាសែតវីដេអូ ទាក់ទងនឹងការប្រជុំរបស់ តាម៉ុក និង ប៉ុល ពត មួយចំនួននៅសម័យនោះ។ ហើយក៏មានឯកសារដូចជាម៉ាស៊ីនថត ម៉ាស៊ីន

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ថតដែលមានការប្រើប្រាស់នៅសម័យនោះ គឺដូចជាច្រើន ដូចជានៅក្នុងហ្នឹង ខ្ញុំបានរៀបចំជាច្រើនទៀត ដូចជា សំខាន់ គឺឯកសារពាក់ព័ន្ធនឹងរបបខ្មែរក្រហមតែម្តង ដែលខ្ញុំបាទកំពុងតែចងក្រងជាការពិត លោកចៅក្រម។

**ស៖** លោកមានធ្វើជាកាតាឡុក ឬក៏បញ្ជីឯកសារដែលលោកប្រមូលបានហ្នឹងទេ? លោកមានធ្វើបញ្ជីរៀបរាប់ថា ឧទាហរណ៍ដូចជាដាក់រូបថត<> ដាក់ចម្រៀងអី លោកមានធ្វើជាបញ្ជីអ៊ីចឹងទេ?

**ឆ៖** បាទ លោកចៅក្រម ទុកជាមិនធ្វើបញ្ជីក៏ខ្ញុំចាំបានខ្ទង់៩០ភាគរយ ព្រោះគម្រោងខ្ញុំបាទ នឹងបើកសារមន្ទីរឆាប់ៗនៅខេត្តសៀមរាបដែរ។

**ស៖** ចំពោះរូបថតទាំងអស់នោះ ជារូបថតដែលលោកថតដោយផ្ទាល់ ឬក៏រូបថតអ្នកផ្សេងទៀតថតដែរ លោកប្រមូលទុកទាំងអស់ហ្នឹង ជារូបថតសុទ្ធតែលោកថតដោយផ្ទាល់ដៃ ឬក៏មានអ្នកផ្សេងទៀតជាអ្នកថតដែរ?

**ឆ៖** បាទ លោកចៅក្រម រូបភាពទាំងអស់៨០ភាគរយគឺខ្ញុំថត។ ២០ភាគរយទៀត គឺមានខ្ញុំប្រមូលបានពីមិត្តភក្តិខ្ញុំ ក្នុងចំណោមរូបថតកាលនោះវាច្រើនណាស់ ប៉ុន្តែ៨០ភាគរយ គឺរូបថតខ្ញុំថតផ្ទាល់ដៃតែម្តង។

[១៥:០៩:00]

**ស៖** សំណួរមួយទៀតពាក់ព័ន្ធទៅនឹងរបៀបដែលលោកទទួលបានឯកសារទាំងអស់នេះ។ បើតាមខ្ញុំស្តាប់ទៅ នៅពេលដែលលោកចេញពីភ្នំពេញនៅឆ្នាំ១៩៧៩ គឺលោកចេញទៅដោយដៃទទេ មិនមានយកអ្វីទៅតាមខ្លួនទេ។ អ៊ីចឹងលោកប្រមូលឯកសារហ្នឹងបាននៅឆ្នាំណា? ហើយលោករក្សាទុកយ៉ាងម៉េច?

**ឆ៖** បាទ លោកចៅក្រម ការរក្សាទុកឯកសារនេះ ក្រោយពីធ្វើសមាហរណកម្ម រួបរួមជាតិនៅអន្លង់វែងនៅឆ្នាំ១៩៩៨, ៩៧មក ៩៨ខ្ញុំបាទខំផ្ចិតផ្ចង់រក្សាទុកឯកសារ។ ជាពិសេសដែលខ្ញុំបានក្រោយពីសព ប៉ុល ពត លោកស្លាប់ទៅ ខ្ញុំបានទៅដល់ផ្ទះគាត់ ខ្ញុំបានយករូបភាពជាច្រើន ប៉ុន្តែពេលនោះរូបភាពដែលខ្ញុំយកមកបាន គឺសុទ្ធទាក់ទងនឹងសម័យនោះទាំងអស់។ ហើយក្រោយមកទៀតដែលខ្ញុំបានប្រមូលថែមទៀតនេះ គឺខ្ញុំបានប្រមូលតាមមិត្តភក្តិខ្ញុំដែលធ្វើការនៅក្នុងកងទ័ពកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺគាត់បានរក្សាទុក គឺខ្ញុំបានយកមកទុកជាច្រើន ជាច្រើនពាន់សន្លឹក សម្រាប់របបហ្នឹង។ ថ្ងៃក្រោយគឺខ្ញុំគិតថា ថ្ងៃក្រោយនឹងមានទទួលស្គាល់ពីតុលាការអន្តរជាតិដែលត្រូវការជាឯកសារពីខ្ញុំ។ វាមិនគ្រប់គ្រាន់

ទេ ប៉ុន្តែអាចទទួលយកបាន។

**ស៖** លោកអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចបានទេ លោកថាលោកយករូបថតខ្លះបានពីគេ អ៊ីចឹង លោកយកមកពី<>អ្នកណាគេ? ហើយលោកយកហ្នឹង យកតាមរបៀបម៉េច? ហើយអ្នកដែលគេឲ្យរូបថតមកលោកហ្នឹង គេ<រក្សាទុករូបថតនោះយ៉ាងម៉េចដែរ>? លោកអាចរៀបរាប់អំពីសង្វាក់នៃការទទួល និងរក្សាទុកឯកសារទាំងអស់ហ្នឹងបានទេ?

[១៥:១១:០៦]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោក ញ៉ែម អេន៖**

**ឆ៖** បាទ លោកចៅក្រម ខ្ញុំសូមបញ្ជាក់ថា រូបថតនេះ គឺទី១ ខ្ញុំថតខ្លួនឯង បើរូបថតទី២ទៀត គឺខ្ញុំបាទទៅយកនៅនឹងផ្ទះ អ៊ំប៉ុល ពត ក្រោយពីគាត់ស្លាប់។ ទី៣ រូបថតដែលខ្ញុំយកបាន គឺតាមមេបញ្ជាការកងទ័ព ឥឡូវនេះគាត់បានអនិច្ចកម្មអស់ហើយ។ ទី១ ឈ្មោះ ខឹម ងន់, ទី២ ទៀតឈ្មោះ លោកតេម បាទគឺឯកសារ គឺគាត់ឲ្យខ្ញុំរក្សាទុកជាច្រើន។ ពាក់ព័ន្ធនឹងម៉ាស៊ីនថត និងវីដេអូ ម៉ាស៊ីនថតឯកសារជាច្រើន គឺនៅខ្ញុំ នៅមានច្រើនទៀត។ ប៉ុន្តែរូបថតនេះ គឺខ្ញុំយកមកពីគណៈមេបញ្ជាការកងទ័ពនៃរបបខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យតែម្ដង។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកបាននិយាយថា លោកបានកប់របស់មួយចំនួន។ លោកអាចបញ្ជាក់ឲ្យបានច្បាស់ទេ លោកកប់ហ្នឹង កប់អ្វីខ្លះ? ហើយកប់នៅកន្លែងណាខ្លះ? ហើយលោកទៅគាស់យកមកវិញហ្នឹង នៅពេលណា? ខ្ញុំដឹងថា <លោក>មិនត្រឡប់មកភ្នំពេញវិញ<រយៈពេល>យូរ ព្រោះថាលោកនៅតស៊ូនៅអន្លង់វែងហ្នឹង អ៊ីចឹង លោកត្រឡប់មកគាស់យករបស់របរហ្នឹងវិញហ្នឹង នៅពេលណា?

[១៥:១២:៣៦]

**ឆ៖** បាទ លោកចៅក្រម រឿងនេះវែងឆ្ងាយណាស់។ នៅឆ្នាំ១៩៨៣ អ៊ំ៨២និង៨៣ ខ្ញុំបាទចាប់ផ្ដើមកាន់កាមេរ៉ាឡើងវិញ ថតនៅសមរភូមិខាងកើតបឹងទន្លេសាបទាំងមូល ពុះទន្លេសាបម្ខាង គឺខ្ញុំអ្នកថត។ ប៉ុន្តែនៅឆ្នាំ១៩៩៣, ៩០ ក្រោយពីរាជរដ្ឋាភិបាល ដែលមានត្រីភាគី មានសម្ដេចនរោត្តម សីហនុ, មានលោក តាសឺន សាន, មានលោក អ៊ំខៀវ សំផន និងភាគីកម្ពុជាប្រជាធិបតេយ្យ និងមានខាងរដ្ឋាភិ-

បាលបូកគ្នា គឺខ្ញុំបាទចូលមកឆ្នាំ១៩៩០។ ដល់ចូលមកឆ្នាំ១៩៩០នេះ គឺខ្ញុំបានទៅមើលកន្លែងខ្ញុំ គឺគ្មានអ្នកណាដឹងទេ ខ្ញុំបានឡើងលើផ្ទះហ្នឹង ខ្ញុំយកមាសបាន២តម្លឹងទៀត។ ដោយខ្ញុំលាក់ក្នុងកន្លែងក្នុងក្រឡកន្លែងបាយហ្នឹង គឺម្ចាស់ផ្ទះឃើញខ្ញុំឡើងទៅ ប៉ុន្តែអត់ដឹងថាអ្នកណាឡើងទៅទេ។ ហើយម៉ាស៊ីនថត ខ្ញុំកប់ ប៉ុន្តែខ្ញុំកប់ពេលនោះ បានតែម៉ាស៊ីនថតតូចៗទេ តែម៉ាស៊ីនថតកុន បញ្ចាំងកុន និងម៉ាស៊ីនថតច្រើនខ្ញុំទុកដូចជា ម៉ាស៊ីនថត៨មិល្លីម៉ែត្រ, ម៉ាស៊ីនថត១៦ មានថតកុន គឺយកអត់បានទេ។ គឺខ្ញុំកប់តែអាពីររណ្តៅហ្នឹង គឺគេកាយយកបាត់ ប៉ុន្តែនៅអាមួយរណ្តៅ គឺម៉ាស៊ីនថតនៅរួមគ្នាទាំងអស់។ កប់នៅនឹងដើមដូងហ្នឹងតែម្តង មុខកន្លែងខ្ញុំនៅហ្នឹង មុខនៅទួលស្លែងហ្នឹង ដែលមុនចេញពីផ្ទះឆ្នាំ១៩៧៩ ក្រោយវៀត-ណាមចូលថ្ងៃ០៧ មករា។ ខ្ញុំបាទវិលត្រឡប់វិញ សូមបញ្ជាក់ម្តងទៀត ឆ្នាំ១៩៩០ ខ្ញុំមកដល់វិញ ខ្ញុំចូលមកភ្នំពេញ ដូចមានលោកអ៊ំ ខៀវ សំផន ត្រីភាគីកម្ពុជាប្រជាធិបតេយ្យប្រជុំនៅអង្គការសហប្រជាជាតិទាក់ទងនឹងយើងរួបរួមគ្នា ថ្ងៃ២៣ តុលា។ អ៊ីចឹងរឿងហ្នឹងវាវែងឆ្ងាយ លោកចៅក្រម ខ្ញុំ--។

**ស៖** ចំពោះរូបថត ឬក៏វីដេអូ <តើ>លោកដឹងថាមានឯកសារថតចម្លងផ្សេងទៀតទេ? <ហើយបើមានឯកសារថតចម្លង តើសាធារណជនអាចប្រមូលបានទេ> ឬក៏<>មានតែលោក<>ទេ<ដែលមានរូបថត និងឯកសារវីដេអូទាំងនេះ>? ដើម្បីបញ្ជាក់ឲ្យបានច្បាស់ម្តងទៀត តើលោកមានបានបង្ហាញជូនអ្នកស៊ើបអង្កេតដែលមកសម្ភាសលោកនូវឯកសារទាំងអស់ហ្នឹង ដែលលោកបានរក្សាទុកហ្នឹងទេ?

[១៥:១៥:១៤]

**ឆ៖** បាទ កន្លងមកខ្ញុំសូមជម្រាបលោកចៅក្រមថា ឯកសារកន្លងមកជួនកាលខ្ញុំបង្ហាញទៅអង្គចៅក្រម ដូចអ្នកស៊ើបអង្កេតដែរ។ ជួនកាលដូចជា ខ្ញុំនិយាយអស់ ដូចជាមជ្ឈមណ្ឌលកម្ពុជាឯកសារអាស៊ីខេមអឺ ខ្ញុំដូចជាខ្ញុំមិនសូវបណ្តោយដែរ។ ជួនកាលៗ គេអត់ឲ្យតម្លៃយើង ព្រោះយើងស្រឡាញ់ណាស់ប្រវត្តិសាស្ត្រ។ ប៉ុន្តែទាក់ទងនឹងកាសែតវីដេអូ គឺខ្ញុំបាទថតវីដេអូខ្លួនឯង រាល់ថ្ងៃនេះម៉ាស៊ីនថតវីដេអូនៅខ្ញុំ ១៩គ្រឿងទៀត។ អ្នកណាអ្នកទិញឲ្យខ្ញុំគឺតាម៉ុក និងប៉ុល ពតទិញឲ្យតែម្តង។ ខ្ញុំមានឯកសារម៉ាស៊ីនថតវីដេអូសមរភូមិនៅមាននៅទាល់សព្វថ្ងៃហ្នឹង ម៉ាស៊ីនថត។ ខ្ញុំស្រឡាញ់របស់ទាំងអស់ហ្នឹងណាស់ ទោះជារបស់នោះមិនប្រើការអត់កើតក៏ដោយ ក៏មានតម្លៃសម្រាប់ប្រវត្តិសាស្ត្រចំពោះជីវិតខ្ញុំ។

**ស៖** ខ្ញុំសូមចូលទៅប្រធានបទផ្សេង ខ្ញុំចង់ដឹងថានៅពេលដែលលោកធ្វើការនៅស-២១ តើលោកទទួលបញ្ជាពីអ្នកណា? លោកទទួលបញ្ជាតែពី ឌុច ម្នាក់គត់ ឬក៏លោកទទួលបញ្ជាពីមេដឹកនាំណាផ្សេងទៀតក្រៅពី ឌុច?

**ឆ៖** បាទ លោកចៅក្រម រឿងនេះដូចជាមិនភ្លេច ការទទួលបាន គឺទី១ គឺដូចខ្ញុំជម្រាបជូនអ៊ីចឹង គឺឯកឧត្តម សុន សេន រដ្ឋមន្ត្រីក្រសួងការពារជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ ទី២ គឺមានឯកឧត្តម ណាត បន្ទាប់ទៀតគឺមាន តាពីន ហើយគឺមាន តាឌុច ដែរ បាទបញ្ជា។ ក៏ប៉ុន្តែកិច្ចការមួយចំនួនដែលខ្ញុំត្រូវបញ្ជាពីលោក ឌុច ក្នុងគុកទួលស្លែងនេះ គឺទាក់ទងនឹងការថតរូប ថតរូបជាច្រើន គឺខ្ញុំអ្នកទទួលអ្នកថត ក៏ប៉ុន្តែមានក្រុមរបស់ខ្ញុំ ដូចខ្ញុំថាជម្រាបខាងដើម បកទៅក្រោយអ៊ីចឹង កន្លែងខ្ញុំគឺខ្ញុំមានទូរស័ព្ទ បាទ ទូរស័ព្ទលើតុ តេហៅអ្នកណា អ្នកហ្នឹងទៅៗបាទ។

[១៥:១៧:៣៣]

**ស៖** នៅពេលដែលគេឲ្យលោកជូនគណៈប្រតិភូទៅថតរូប ឧទាហរណ៍ដូចជាចុះទៅទស្សនកិច្ច នៅតាមទំនប់នានា ឬក៏ការដ្ឋាន ឬសហករណ៍នានា អ្នកណាជាអ្នកចេញបញ្ជាឲ្យលោកនាំគណៈប្រតិភូចុះទៅនុ៎ង ហើយឲ្យលោកថតរូបហ្នឹង ឌុច ឬក៏អ្នកណាផ្សេងជាអ្នកបញ្ជាលោក?

**ឆ៖** បាទ លោកចៅក្រម ការបទបញ្ជាហ្នឹងគឺ មានអ៊ំ សុន សេន និង តាណាត។ បាទ មានតែពីរហ្នឹងគត់បាទ ក្នុងសម័យនោះគឺក្នុងសន្តិសុខជាតិរបស់របបកម្ពុជាប្រជាធិបតេយ្យហៅថា គុកទួលស្លែង គឺថាមានតែពីរទេ មានតែ សុន សេន (ឯកឧត្តម សុន សេន) និងតាឌុច -- និងតាណាត។ តាឌុចគាត់បានបញ្ជាតែក្នុងគុកទួលស្លែងទេ ក្នុងទួលស្លែងគឺគាត់បញ្ជាថតអ្នកទោស គឺមានតែគាត់បញ្ជាថត ហើយក្នុងនោះគឺមានខ្ញុំ ប្រាំមួយនាក់ដែលធ្វើការនៅទីនោះ។ ហើយអមគណៈប្រតិភូទៅហ្នឹងគឺ ដូចជម្រាបជូនខាងដើមអ៊ីចឹង មានប្រាំមួយនាក់ ជូនកាលពេលវេលាខ្លះគឺខ្ញុំទៅ ពេលវេលាខ្លះគឺអ្នកផ្សេងដូចគ្នា។

**ស៖** ហើយនៅពេលដែលលោកនាំគណៈប្រតិភូចុះទៅហ្នឹង លោកថតតែរូបភាពទេ ឬក៏លោកថតជាខ្សែភាពយន្តឯកសារដែរ?

**ឆ៖** បាទ លោកចៅក្រម។ ទាក់ទងនឹងបញ្ហាហ្នឹងវាមានការស្មុគស្មាញពេក ថតរូបហើយ ថតជារូបភាពផង ថតជាកុនផង។ ហើយកុនសម័យនោះ គឺលោកចៅក្រមដឹងហើយ សម័យអតីតកាលវាថតអា១៨មិល្លីម៉ែត្រថតអត់បានទេ ប្រើតែ១៦មិល្លីម៉ែត្រ ឬ៣៥មិល្លីម៉ែត្រ។ ការប្រើប្រាស់ថតកុនវិញនោះរយៈពេលពី៣ខែ ពី២ខែទៅ៣ខែបានៗមើល នៅកាត់ត នៅលាងហ្វីល នៅបញ្ចូលសំឡេង អត់ដូចសម័យឥឡូវទេ គឺពិបាកណាស់លោកចៅក្រម ប៉ុន្តែការព្យាយាមរបស់ខ្ញុំ គឺខ្ញុំក៏មានមោទនចំពោះខ្លួនឯងដែលខ្ញុំខំរៀនបានចេះដឹងបន្តិចបន្តួចសម័យនោះ គឺវាច្រើនណាស់ វាច្រើនពណ៌នាវាច្រើន។

[១៥:១៩:៥៤]

**ស៖** ខ្ញុំដឹងថាភាគីបានមើលកុនជាច្រើនពាក់ព័ន្ធនឹងការសាងសង់ទំនប់ ហើយក្នុងហ្នឹងយើងឃើញមានប្រជាជននាំគ្នាសាងសង់ទំនប់។ ដូច្នេះខ្លួនលោកផ្ទាល់នោះ លោកមានធ្លាប់ថតកុនដែលមានរូបប្រជាជននាំគ្នាធ្វើការសាងសង់ទំនប់ទេ?

**ឆ៖** បាទ ជាការពិតលោកចៅក្រម ការថតកុននេះគឺបើនិយាយទៅខ្ញុំមានគ្នាដល់ទៅច្រើនទៀត ដូចជាមានលោក យ៉េ – លោកយ៉េ លោកៗលាង ហើយក្នុងហ្នឹងគឺមានអ្នកបច្ចេកទេស កាលហ្នឹងយើងនៅមានអ្នកបច្ចេកទេសសល់ពីសម័យឯកឧត្តម លន់ នល់ ប្រមុខរដ្ឋ។ ដូច្នេះយើងយកគាត់មកជួយពន្យល់បញ្ហាថតកុន។ ខ្ញុំបាទបើទៅជារឿងកុននៅភ្នំពេញនេះ មានរោងកុនកំពូលពេជ្រ រោងកុនចេនឡារោងកុនលុច្ស។ ដូច្នេះនៅតាមភាពយន្តទាំងអស់ ខ្ញុំបាទបានស្រាវជ្រាវទៅបានមានគាត់ខ្លះគាត់ចេះបច្ចេកទេសមួយចំនួនដែរ។ ហើយក្នុងហ្នឹងមានខាងសាធារណរដ្ឋប្រជាមានិតចិនហ្នឹង គឺមានម្នាក់ពីរនាក់ដែរ គាត់ដែលមកពន្យល់ដើម្បីថតកុនសម័យនោះ ហើយក៏មានចិនក៏មកថតកុនជាមួយដែរ។ ហើយពេលកាត់តទាំងអស់ អត់មានកាត់តស្រុកខ្មែរទេ ក៏បញ្ជូនទៅសាធារណរដ្ឋមានិតចិននៅប៉េកាំង។ បាទនៅភ្នំពេញអត់មានកាត់តទេបង អត់មានកាត់តទេ កាត់ត បានតែថត ប៉ុន្តែយកទៅកាត់តបញ្ចូលសំឡេងគឺនៅប្រទេសចិនទាំងអស់។

[១៥:២១:២៥]

**ស៖** ខ្ញុំប្រហែលជាសួរសំណួរខ្ញុំឡើងវិញម្តងទៀត ដើម្បីឲ្យលោកឆ្លើយត្រូវនឹងសំណួររបស់ខ្ញុំ។ ខ្ញុំសួរថាខ្លួនលោកផ្ទាល់នោះ លោកមានបានថតរូបសកម្មភាពប្រជាជនដែលកំពុងតែធ្វើការសាងសង់ទំនប់<ទេ?> ខ្ញុំចង់សំដៅលើរូបលោកដែលជាអ្នកថតផ្ទាល់តែម្តង?

**ឆ៖** បាទ លោកចៅក្រម ខ្ញុំបានថត ដូចជានៅទំនប់១មករា ទំនប់៣០កញ្ញា ទំនប់នៅយើងអាងត្រពាំងថ្ម និយាយរួមទំនប់ធំៗខ្ញុំធ្លាប់បានជិតគ្រប់កន្លែងដែរ។ ប៉ុន្តែផ្នែកភូមិភាគឧត្តរ និងភូមិភាគបស្ចិម និងភូមិភាគពាយ័ព្យ ខ្ញុំបានទៅញឹកញាប់ណាស់រឿងថតទំនប់ប្រឡាយហ្នឹង ជីកប្រឡាយ លើកទំនប់ប្រឡាយ។ ប៉ុន្តែងាកទៅខាងភូមិភាគបូព៌ា ងាកភូមិភាគឦសាន និងភូមិភាគនិរតីនេះ ខ្ញុំកម្របានទៅណាស់ ប៉ុន្តែខាងៗនោះខ្ញុំទៅញឹក បាទទៅញឹកថត ដូចជាសកម្មភាពឃើញចុះផ្សាយតាមព័ត៌មានមួយចំនួនហ្នឹង គឺៗក៏ខ្ញុំបានរួមចំណែកថតជាមួយនឹងសកម្មភាពទាំងអស់ដែរ។

**ស៖** ហើយលោកនៅចាំទេ ថាពេលហ្នឹងគេចេញបញ្ជាឲ្យកម្មករធ្វើការយ៉ាងម៉េចខ្លះ? <តើគេ

មានប្រាប់អ្នកធ្វើការហ្នឹង ឧទាហរណ៍ថា> ឲ្យ<>ធ្វើការដោយរត់<ទេ ដើម្បីឲ្យមានការចាប់អារម្មណ៍ថាពួកគេធ្វើការសស្រាក់សស្រាំ ឬក៏>គេមានប្រាប់ថា<>កុំឲ្យចេញនៅក្នុងកាមេរ៉ាអីអ៊ីចឹង? គេមានប្រាប់ណែនាំអីយ៉ាងម៉េចខ្លះ?

[១៥:២៣:០២]

**ឆ៖** លោកចៅក្រម ទាក់ទងនឹងបញ្ហាភាពយន្ត ខ្ញុំបានរៀនច្បាស់ណាស់ភាពយន្ត។ ធម្មតាការថតភាពយន្ត គឺតែងតែប្រយ័ត្នប្រយែង ហើយ*ស្បង់ ឌីហ្សាញ* និងមើលទេសភាពនឹងមុខ ដូច្នេះដូចជាកម្មករ ខ្ញុំបានថតជាច្រើន ចាប់តាំងពីក្បាលថ្នល់ទៅ រួមមានរោងចក្រដែក រោងចក្រក្រឡឹង រោងចក្រដែកគោល រោងចក្រមង រោងចក្រកង់ រោងចក្រស្បែកជើង និយាយរួមចាប់តាំងពីចាក់អង្រែលើរហូតពីក្បាលស្ពានថ្នល់ ទៅដល់តាខ្មៅ ខ្ញុំថតជាច្រើន។ ប៉ុន្តែសកម្មភាពនោះ ធម្មតាទេ ធម្មតាថតភាពយន្តគេមិនដែលយករូបអាក្រក់មកដាក់ទេ ហើយការថតរបស់យើង ក៏មិនដែលយករូបភាព*(ឮមិនច្បាស់)*មកថតដែរ។ ដូច្នេះការផ្ចិតផ្ចង់ភាពយន្តនេះ លោកចៅក្រមដឹងហើយ គឺការមានការប្រយ័ត្នប្រយែងជាទីបំផុតដើម្បីទាញអារម្មណ៍អ្នកមើលបាទ។

**ស៖** អ៊ីចឹងមានន័យថា គេបញ្ជាឲ្យលោកហ្នឹងថតតែរូបភាពដែលមានលក្ខណៈវិជ្ជមាន ហើយនិងថតតែសមិទ្ធផលរបស់អង្គការទេ តើអ៊ីចឹងមែនទេ?

**ឆ៖** រឿងនេះលោកចៅក្រម វាជាការត្រឹមត្រូវហើយ ប៉ុន្តែបើសិនណាជាយើងថតរូបភាពអាក្រក់ វាជាមុខមាត់ប្រទេសនៃរបបមួយអ៊ីចឹង ជាការពិតបាទ។

**ស៖** តើលោកធ្លាប់ស្តាប់ឮអំពីការធ្វើដំណើរ ឬក៏ទស្សនកិច្ចរបស់អ្នកកាសែតយូហ្គោស្លាវីទេ? ហើយក្រុមអ្នកកាសែតនេះគេបានថតកុនដែរ លោកធ្លាប់ឮអំពីរឿងហ្នឹងទេ?

**ឆ៖** មិនធ្លាប់ទេ ឃើញតែម្តងបាទ។ ឃើញមកថតជុំគ្នាទៅមុខវាំង ទៅតាមកំពង់ចាម ដូចជាច្រើនដែរមកយូហ្គោស្លាវី, រ៉ូម៉ានីមក មាន ខ្ញុំឃើញជាពិត។ ថតជាភាពយន្តក៏មាន បើថត*ហ្វិក*ហ្នឹងច្រើនណាស់ ខ្ញុំឃើញថតច្រើន។

[១៥:២៥:២១]

**ស៖** តើលោកដឹងទេថា ការចាក់ផ្សាយកុនដែលថតដោយក្រុមអ្នកកាសែតយូហ្គោស្លាវីហ្នឹងបណ្តាលឲ្យមានប្រតិកម្មអីទេ? តើមានការសរសើរ ឬក៏បង្កើតទៅជាបញ្ហា?

**ឆ៖** បាទ លោកចៅក្រម អានេះវាជារឿងកាតព្វកិច្ចរបស់សារព័ត៌មាន ប៉ុន្តែក្នុងសម័យនោះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដែលខ្ញុំដឹងច្បាស់ នៅលើពិភព ប្រទេសប្លុកកុម្មុយនីស្ត គឺដូចជាប្រទេសយូហ្គោស្លាវី, រ៉ូម៉ានី, ម៉ុងហ្គោលី ចិន, កូរ៉េខាងជើង គឺមកប្រទេសកម្ពុជានេះ គឺមានការស្វាគមន៍ បាទមានការស្វាគមន៍ពីអ៊ំ ប៉ុល ពត និង គណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យ។ បើចងក្រងប្រទេសលទ្ធិកុម្មុយនីស្តនៅលើពិភពលោក គឺខ្ញុំឃើញ ជាការជាក់ស្តែងមែន។ ដូចការប្រតិកម្មចំពោះការភាពយន្ត ដូចអត់ឃើញមានផង អត់ឃើញមានការ ប្រតិកម្មពីអ្នក ប៉ុន្តែប្រតិកម្មស្ងាត់ ខ្ញុំអត់ដឹង ប៉ុន្តែឲ្យជាជំហរ ដូចជាផ្សាយតាមប៉ុស្តិ៍វិទ្យុ ឬក៏ពាក់ព័ន្ធនឹង ផ្សេងៗ ដូចជាអត់មាន។ ប៉ុន្តែសម័យនោះ ប្រទេសកុម្មុយនីស្តមកតិចណាស់ មកប្លុកប្រទេស វារយៈ ពេល៣ឆ្នាំ៨ខែ២០ថ្ងៃ វាស្ថានទូតប្រចាំនៅកម្ពុជាហ្នឹងវាតិចពេក។ ដូច្នេះវាៗថាតម្លាភាពថាដូចបាន ដូច អត់តម្លាភាពក៏ថាបាន វាទន្ទឹមគ្នាអ៊ីចឹងដែរ។

**ស៖** នៅស-២១ អ្នកទោសមួយចំនួនទុំងត្រូវគេឲ្យសារភាព ហើយគេថតសំឡេងសារភាពទាំង ហ្នឹង ហើយបន្ទាប់មកគេយកសំឡេងសារភាពទុំង យកទៅចាក់ផ្សាយតាមវិទ្យុនៅភ្នំពេញ។ ដូច្នេះខ្ញុំចង់ ដឹងថា អ្នកណាជាអ្នកទទួលបន្ទុកក្នុងការថតសំឡេងចម្លើយសារភាពរបស់អ្នកទោសនៅស-២១?

**ឆ៖** បាទ ខ្ញុំដូចអត់ភ្លេចទេ បាទអ្នកសួរចម្លើយគឺ ខ្ញុំមានក្រុមហ៊ុន -- ក្រុមតាស្រ៊ី, តាស៊ីន, តា ម៉េង គេសួរចម្លើយ។ ដូច្នេះខាង ឆេន ហ្នឹងនៅជាមួយ តាឌុច ហ្នឹងគាត់បាន នៅផ្ទះ តាឌុច គាត់មានម៉ា ញ៉េរហួតដល់១០គ្រឿង ២០គ្រឿងនោះ ម៉ាញ៉េសម័យពីដើមហ្នឹងថត។ ថតសំឡេងអ្នកទោសហ្នឹង យក ទៅចាក់ផ្សាយតាមវិទ្យុ។ ប៉ុន្តែសំខាន់ទៀតបំផុតគឺ សំឡេងវៀតណាម បាទសំឡេងវៀតណាមដែល ចាប់បានហ្នឹង គាត់ឲ្យសម្អាស ទាក់ទងក្នុងៗម៉ាញ៉េថតទៅ ហើយមានអ្នកបកប្រែហ្នឹងគឺ តាចាន់ អ្នក បកប្រែវៀតណាមហ្នឹង ហើយចាក់ផ្សាយទាក់ទងនឹងបំប៉ោងសំឡេងទៅដោយសារអី? ដោយសារតែ ទាក់ទងនឹងបញ្ហាវៀតណាមរំលោភចូលប្រទេសកម្ពុជា។ អានេះជាការពិត មិនអាចប្រែក្លាយបាន ដឹង ច្បាស់ណាស់គឺ មេក្រុម តាឌុច គាត់អ្នកមកថតសំឡេងយក។ ហើយជាពិសេសទៀត អ្នកសួរចម្លើយ ហ្នឹងតែម្តង បាទអ្នកសួរចម្លើយហ្នឹងតែម្តង គាត់ថតឲ្យតែម្តង ដូចជាថ្នាក់ដឹកនាំធំៗ ខ្ញុំចាំមិនអស់ទេ ប៉ុន្តែអត់មានកាឡៃបាន គឺការពិត។

[១៥:២៨:១៨]

**ស៖** ដូច្នេះអ្នកថតរូបមិនចូលរួមនៅក្នុងការថតសំឡេងចម្លើយសារភាពទេ គឺតែអ្នកសួរចម្លើយ ទេ ដែលជាអ្នកថតខ្លួនឯងផ្ទាល់ អ៊ីចឹងមែនទេ? អ្នកក្រុមអ្នកថតរូបលោកអីហ្នឹង មិនចូលរួមទេ មែនទេ?

**ឆ៖** បាទ លោកចៅក្រម រឿងនេះវាជាពិត។ សម័យនោះគឺគេដាក់ដាច់ៗពីគ្នា អត់មានសួរអ្នក

ណាបាន ការងារណាដឹង ការងារយើងដឹង អត់មាន គឺត្រឹមត្រូវ។

**ស៖** ឥឡូវនេះខ្ញុំចូលទៅប្រធានបទផ្សេងទៀត។ ក្នុងចំណោមរូបថតស-២១ហ្នឹង នៅក្នុងសំណុំរឿង យើងមានរូបថតសាកសពជាច្រើន។ គេបានសួរលោកអំពីរូបថតទាំងអស់នេះ។ ដូច្នេះលោកអាចជម្រាបបានទេ អ្នកណាជាអ្នកចេញបញ្ជាឲ្យថតរូបទាំងអស់ហ្នឹង? ហើយវាជារឿងធម្មតា ជាប្រចាំថ្ងៃមែនទេ ដែលត្រូវថតរូបទាំងអស់ហ្នឹង?

**ឆ៖** បាទ លោកចៅក្រម រឿងនេះវាពាក់ព័ន្ធច្រើន ខ្ញុំសូមអត្ថាធិប្បាយបន្តិចទាក់ទងបញ្ហានេះ។ ទី១ អ្នកទោសដែលស្លាប់នៅទួលស្លែង ពេលដែលគាត់សួរចម្លើយហើយ រើធ្ងន់ៗពេក ឬក៏ឆ្នាំគុក អ្នកសួរចម្លើយ រើធ្ងន់ដៃទៅស្លាប់ អាហ្នឹងថតមួយ។ ពីរទៀត ក្រោយពីថតសួរចម្លើយហើយ អ្នកទោសដែលសំខាន់ៗបំផុតហ្នឹង គឺគាត់យកទៅសម្លាប់ដូចគ្នា។ ក៏ប៉ុន្តែលោកចៅក្រមឃើញ អារ-ក បាទអារ-កក៏ឲ្យថតដែរ។ ប៉ុន្តែក្រុមថតហ្នឹង មានម្នាក់គត់ដែលថតសពទាំងអស់នេះគឺឈ្មោះ ស្រ៊ុ។ មិត្តស្រ៊ុ ហ្នឹងគឺគាត់ឆ្នាំគុកដែរ គឺខ្ញុំ គាត់បានរៀនសូត្រពីខ្ញុំទៅថត។ ពេលដែលគាត់ថតហើយ គាត់អត់ឲ្យអ្នកណាឃើញទេ គាត់យកឲ្យខ្ញុំផ្តិត។ ដូច្នេះរូបថតនៅគុកទួលស្លែងដែលមានឃើញអារ-កៗ ហ្នឹងគឺៗ ៩០ ភាគរយសុទ្ធតែថ្នាក់ដឹកនាំធំៗទាំងអស់។ ដូច្នេះពេលថតរូបភាពហើយ យកឲ្យអ្នកណាមើល? លោកចៅក្រម បញ្ជូនទៅឲ្យ សុន សេន, សុន សេន បញ្ជូនទៅឲ្យអ៊ំប៉ុល ពត។ សួរថាសម្លាប់ហើយនៅ? សម្លាប់។ ដូច្នេះវាជាភស្តុតាងមួយមិនអាចប្រកែកបានទេ នេះជាការពិតណាស់ ខ្ញុំៗអ្នកផ្តិតផ្ទាល់ដៃ គឺអ្នកថតឈ្មោះ ស្រ៊ុ។ ប៉ុន្តែ ស្រ៊ុ ហ្នឹងទីចុងបញ្ចប់ក៏គេរើចោលនៅទួលស្លែងដែរបាទ។ ហើយរះយកប្រមាត់ទៀត មានពេទ្យ ប៉ោល ហ្នឹងរះយកប្រមាត់ទៀត លោកប្រធានឃើញហើយក្នុង បាទ។

[១៥:៣១:០១]

**ស៖** ដូច្នេះមានន័យថា ស្រ៊ុ ជាអ្នកថត។ អ៊ីចឹងរូបទាំងអស់ហ្នឹង ថតតែនៅស-២១ទេ ឬក៏ ស្រ៊ុ ហ្នឹងគាត់ទៅថតនៅ ដូចជានៅជើងឯកផងដែរ?

**ឆ៖** បាទ លោកចៅក្រម រឿងនេះខ្ញុំមិនសន្និដ្ឋានបានទេ ប៉ុន្តែរូបភាពដែលយកមក គឺប្រហែលជាអាចយកមកពីហ្នឹងខ្លះ រូបភាពដែលខ្ញុំផ្តិតហ្នឹងណ៎ា អាចយកមកពីបឹងជើងឯកខ្លះ។ ប៉ុន្តែនៅប្លុក នៅក្រោយទួលស្លែងនេះ ខាងអ្នកប្រមូលសព ឆ្អឹងសព ក្បាលខ្មោចអីហ្នឹង ខ្ញុំមិនដឹង ប៉ុន្តែនៅប្លុកខាងក្រោយ អាផ្លូវមួយនៅបឹងកេងកងហ្នឹង គឺសម្លាប់ច្រើនណាស់។ ប៉ុន្តែខមាទោស ពេលដែលស្លាប់ហើយ គឺដើមឈើងាប់ទាំងអស់ ដើមឈើងាប់ ដើមដូង ដើមស្វាយ ដើមសេមាន់ ដើមល្មុតងាប់ឡើងវាល ដល់ពេល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01247228



សម្លាប់ហ្នឹងឆ្អែតហើយ វាអត់កន្លែងសម្លាប់ បានយកទៅសម្លាប់នៅបឹងជើងឯក។ ប៉ុន្តែបឹងជើងឯក ខ្ញុំអត់ដឹងថាយកទៅសម្លាប់បឹងជើងឯកទេ លោកចៅក្រម ក៏ប៉ុន្តែនៅឆ្នាំ១៩៩៥ ដែលខ្ញុំធ្វើសមាហរណកម្មចូលរួមជាមួយរដ្ឋាភិបាលនេះមក ខ្ញុំបានធ្វើដំណើរទៅបឹងជើងឯក។

**ស៖** ខ្ញុំមិនសូវយល់ចម្លើយរបស់លោកតាមរយៈការបកប្រែ ក៏ប៉ុន្តែអ្វីដែលខ្ញុំយល់នោះ គឺថាមុនឆ្នាំ៩៥ លោកមិនដែលទៅជើងឯកទេ ទាល់តែ៩៥ បានលោកបានទៅជើងឯកហ្នឹង។ អ៊ីចឹងចម្លើយអ៊ីចឹងត្រឹមត្រូវទេអម្បាញ់មិញហ្នឹង?

[១៥:៣២:៤៧]

**ឆ៖** បាទ លោកចៅក្រម។ ខ្ញុំបាទនៅឆ្នាំង១៩៩៥ ខ្ញុំចាំបានហើយថ្ងៃខែ១១ ឆ្នាំ៩៥ ខ្ញុំបាទមកធ្វើសមហរណកម្មជាមួយរាជរដ្ឋាភិបាល។ ដូច្នេះថ្ងៃនោះឯងដែលជាថ្ងៃមួយពិសេស ដែលខ្ញុំបាទផ្សាយព័ត៌មាននៅតាមបណ្ដាញសង្គមព័ត៌មាននៅ ខេមបូឌាថែមស៍ គេចុះផ្សាយរឿងខ្ញុំជាអតីតអ្នកថតគុកទួលស្លែងហ្នឹងឯង អ៊ីចឹងបានខ្ញុំគេឲ្យទៅមើល ខ្ញុំឃើញ បានថាអ៎! អ្នកទោសដែលដឹកទាំងឡានៗ គឺយកមកវ៉ៃចោលនៅបឹងជើងឯកហ្នឹង គឺលើកទី១ ដែលខ្ញុំឃើញសាកសពនៅបឹងជើងឯកនៅឆ្នាំ១៩៩៥ ខែ១២ និងខែ១១នេះឯង។

**ស៖** តើលោកធ្លាប់កត់សម្គាល់ថា មានឡានដឹកអ្នកទោសមកស-២១ ហើយដឹកទៅសម្លាប់តែម្ដង ដោយមិនមានថតរូប លោកធ្លាប់ជួបករណីបែបហ្នឹងទេ?

**ឆ៖** លោកចៅក្រម រឿងនេះច្រើនណាស់ ច្រើនករណីណាស់ វាជាការពិត។ ជួនកាលឃើញចាប់ ខ្ញុំនិយាយឲ្យអស់ រៀបរាប់សម័យនោះគេចាប់ខ្លាំងជាងគេ ទី១នៅព្រលានយន្តហោះកំពង់ឆ្នាំងក៏ដឹកមកហ្នឹងដែរ។ ចាប់នៅបូព៌ាក៏ដឹកមកហ្នឹងដែរ។ ដូច្នេះដឹកមកពីតំបន់ក-៥ ហៅថាតំបន់ត្រពាំងថ្មយកមកហ្នឹងដែរ។ ដូច្នេះខ្ញុំច្បាស់ណាស់ គឺអត់បានថតទេ គឺដឹកយកទៅវ៉ៃចោលតែម្ដង។ ដូចថាពិនិត្យទៅអត់មានឯកសារ ជួនកាលឡានគ្រាន់តែឃើញទៅបាត់។ មែន! ជាការពិតលោកចៅក្រម។

**ស៖** ដើម្បីបំភ្លឺ លោកឃើញថាមានគេដឹកឡានយកមនុស្សមក ហើយក្រោយមកគេយកមកមន្ទីរស-២១ ហើយបន្ទាប់មកទៀត គេបញ្ជូនទៅកំពង់ឆ្នាំង ទៅព្រលានយន្តហោះកំពង់ឆ្នាំង ដើម្បីឲ្យយកទៅសម្លាប់នៅទីនោះ ឬក៏យ៉ាងម៉េច? លោកជួយបញ្ជាក់វិញបានទេ?

[១៥:៣៥:០៤]

**ឆ៖** លោកចៅក្រម ដឹក បាទដឹកគឺដឹកៗមកពីកំពង់ឆ្នាំងទេ មិនដឹកពីស-២១ ទៅកំពង់ឆ្នាំង ដឹក

ពីកំពង់ឆ្នាំងមក។ ដឹកពីកំពង់ឆ្នាំងមក ដឹកមកពីតំបន់៥នៃភូមិភាគពាយ័ព្យ ហើយក៏បូព៌ានេះ ក៏យកមកច្រើនដែរ សុទ្ធតែទាហានទាំងអស់។ ទាហានចងមុខ ចងដៃ ខោអាវយើងអាចម៏សេះហ្នឹង យកទៅកំប្លែ១។

**ស៖** អ៊ីចឹងគឺមានអ្នកដែលមកពីកំពង់ឆ្នាំង ហើយមកពីកន្លែងផ្សេងទៀត ដឹកមកមន្ទីរស-២១ ហើយចំពោះអ្នកទាំងអស់ហ្នឹង គេអត់បានថតរូបគាត់ទេ គឺនៅក្នុងពេលដែលគេចាប់មនុស្សច្រើនមែនទែន នៅពេលនុំង។ ហើយពេលនុំងហើយ ដែលគេអត់បានថតរូបអ្នកដែលគេនាំមកមន្ទីរស-២១ហ្នឹងទេ។ លោកចង់និយាយអ៊ីចឹង ឬក៏យ៉ាងណា?

**ធ៖** បាទ លោកចៅក្រម នេះវាជារឿងពិតហើយ។ នៅឆ្នាំ១៩៧៧នេះ ច្រើនណាស់ ចាប់មកច្រើនមែន ប៉ុន្តែថតក៏បានថត អាអ្នកមិនថតហ្នឹង ក៏ច្រើនដែរ។ បាទ លោកចៅក្រម។

**ស៖** ខ្ញុំយល់ថា ក្នុងចំណោមសកម្មភាពរបស់លោកដែលជាអ្នកថតរូបនោះ លោកក៏ជានីរសារដែរ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើលោកជានីរសារដល់ពេលណា? ហើយលោកនាំសារទៅអ្នកណាដែរ? តើនាំសារទៅ ប៉ុល ពត ឬក៏ទៅ សុន សេន ឬក៏ទៅ តាណាត ឬក៏ ទៅនួន ជា? លោកនាំសារទៅអ្នកណាដែរ?

[១៥:៣៧:០១]

**ធ៖** បាទ លោកចៅក្រម រឿងរ៉ាវនេះ មើលទៅដូចជាវែងឆ្ងាយ ខ្ញុំនិយាយច្រើនបន្តិចចុះ សុំទោស។ កាលនុំងគេមានបង្កើតគុកមួយនៅ១តាខ្មៅ អាពេទ្យឆ្កួតហ្នឹង។ ខ្ញុំបាទបាននាំសារហ្នឹងពី១១តាខ្មៅមក ប៉ុន្តែការនាំសារខ្ញុំបាទហ្នឹងជិះកង់ទេ។ តែខ្ញុំជិះកង់ថ្មើរហ្នឹង ល្ងាច១ ខ្ញុំជិះកង់មកដល់យើង ពេទ្យព-៩៨ កន្លែងពេទ្យមុនីវង្សហ្នឹង ប៉ុន្តែទៅ ខ្ញុំឃើញចារក្រហម១។ ចារក្រហមនៅក្នុងហ្នឹង ខ្ញុំនិយាយឲ្យអស់ទៅ វានិយាយទាក់ទងនឹងព្រះមហាក្សត្របន្តិច។ ក្នុងនៅនុំង ក៏មានពូជពង្សព្រះមហាក្សត្រដែលគេសម្លាប់ចោលនៅនោះដែរ ប៉ុន្តែបើសិនណាជាឆ្អឹងហ្នឹងអាចយកមកផ្គុះបញ្ជាំងបាន ដូចជាឆ្អឹងអាមេរិកាំងអី អាចរកឃើញ ឆ្អឹងព្រះ ពូជពង្សព្រះមហាក្សត្រ។ ច្បាស់ណាស់លោកចៅក្រម ខ្ញុំហ្នឹងអ្នកនាំសារ។ ដូច្នោះការយកទៅនេះ គឺខ្ញុំជិះកង់បាទ ប៉ុន្តែជិះកង់ខ្ញុំមិនដែលប៉ានហែកមើលទេ។ ប៉ុន្តែឃើញ១សរសេរក្រហម១ យកទៅឲ្យហើយ។ បាទមាន និយាយរួមមានទាហានអាមេរិកាំង អំមានទាហានរដ្ឋាភិបាលសម័យ លន់ នល់ ច្រើន ស្លាប់នៅច្រើនណាស់ អ្នកបើកពីឡុតយន្តហោះ អ្នករោងចក្រច្រើន លោកចៅក្រម នៅ១យើងវត្តក្រពើហាហ្នឹង អំនៅវត្ត! នៅពេទ្យឆ្កួត។ ពេទ្យឆ្កួតនុំង គុកធំណាស់ ត្រង់នុំង

បាទ គុកឆ្នាំចិតសិប ដើម៧១ធំតែម្តងគុក។ ប៉ុន្តែនាំសារមួយទៀត គឺខ្ញុំបាទនាំពីទួលស្លែង តិចណាស់ ស្មើរតែនឹងអត់ ដូចជាខ្ញុំទៅពីរដង យកឯកសារទៅឲ្យ អ៊ំសុន សេន។ គាត់ឲ្យៗលើឡានទៀត អត់ស្គាល់ផ្ទះគាត់នៅទេ។ ហ្នឹងជាការពិត លោកចៅក្រម។

**ស៖** នៅពេលដែលលោកទៅនៅពេទ្យឆ្កួត នៅតាខ្មៅ លោកជានីរសារនៅពេលនុំ៎ង។ តើពេលហ្នឹងៗ គឺថា មុនពេលលោកទៅចិន ឬក៏ក្រោយពេលដែលលោកមកពីចិនវិញហើយ បានលោកធ្វើជានីរសារនៅទីនោះៗ?

[១៥:៣៩:០៤]

**ឆ៖** ខ្ញុំរៀបចំឯកសារហ្នឹង ក្នុង -- លោកចៅក្រម ក្នុងអំឡុងពេលមុនទៅចិន ចន្លោះពីខែ១០។ ចន្លោះខែ១០ និងខែ១២ហ្នឹង ខ្ញុំរៀនបច្ចេកទេសផង ខ្ញុំធ្វើជានីរសារផង។ ហើយបច្ចេកទេសហ្នឹង ដូចខ្ញុំប្រាប់លោកចៅក្រមថា កុមារដែលយកមករៀនហ្នឹង គឺប្រហែលជា៣.០០០នាក់ បូកសរុបទាំងអង្គភាពកងទ័ពផង ប្រហែលជាប្រាំ ប្រាំមួយពាន់នាក់។ រៀន គឺរៀនសម្បើមណាស់ រៀនបច្ចេកទេសគ្រប់បែបយ៉ាងទាំងអស់។ ប៉ុន្តែរៀនហ្នឹង ដូចជាកងទ័ពជើងគោក កងទ័ពអាកាសផង កងទ័ពនាវា និយាយរួមរៀនទាំងអស់តែម្តង បច្ចេកទេសយោធា ដើម្បីការពារព្រំដែន។ ហើយប្រទេសកម្ពុជាលើកនោះ លោកចៅក្រមដឹងថា វាងើបពីសង្គ្រាមផង ខ្វះធនធានមនុស្ស។ ហើយខ្ញុំនេះ ឆ្លៀតពេលគឺខ្ញុំពេលនោះ ហាក់ដូចជាមោទនៈបន្តិច។ ខ្ញុំបាទរៀបចំខ្លួនស្អាតបាត ខ្ញុំជាមនុស្សមួយឧស្សាហ៍ព្យាយាម អ៊ីចឹងហើយបានអង្គការតម្រូវឲ្យខ្ញុំទៅរៀនចិន គឺខ្ញុំសម័យនោះខ្ញុំ ដូចទម្លាប់ខ្ញុំហ្នឹង មកទាល់ថ្ងៃនេះ ក៏ខ្ញុំត្រូវស្អាតដដែល។ ប៉ុន្តែអ្វីដែលជាមោទនៈរបស់ខ្ញុំទេ ព្រោះជាទម្លាប់ខ្ញុំ។ ដូច្នេះ អង្គការគាត់ចូលចិត្តរឿងស្អាត អ្នកមានរបៀប។ អ៊ីចឹងទៅ ខ្ញុំក៏មានកិត្តិយសដែរ ខ្ញុំមិនថាអួតខ្លួនទេ ចៅក្រម សុំទោសបាទ។

**ស៖** ខ្ញុំយល់ថានៅពេទ្យឆ្កួតតាខ្មៅនោះ មានការសម្លាប់មនុស្សមួយចំនួន ហើយបើខ្ញុំយល់មិនច្រឡំទេ លោកនិយាយអំពីអតីតមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរ<ដែលគេបានសម្លាប់នៅទីនោះ>។ តើលោកអាចនិយាយឲ្យបានលម្អិតបានដែរឬទេ ទាក់ទងនឹងប្រធានបទនេះ? តើមានមនុស្សអតីតមន្ត្រីរដ្ឋការត្រូវបានសម្លាប់ច្រើន ឬក៏យ៉ាងណា? តើមានគោលនយោបាយកាប់សម្លាប់ទៅលើអតីតមន្ត្រីរដ្ឋការនៃសាធារណរដ្ឋខ្មែរនេះដែរឬទេ?

[១៥:៤១:០០]

**ឆ៖** បាទ លោកចៅក្រម សូមជម្រាបដល់លោកប្រធាន តុលាការទាំងមូល។ ខ្ញុំឃើញច្បាស់

នៅបណ្ណាល័យ ៗយើងនៅម្តុំផ្សារថ្មីហ្នឹង បញ្ចាពី សុន សេនមក លោកចៅក្រម លោកប្រធានតុលាការ លោកដឹងថា គាត់ធ្វើយ៉ាងម៉េចទេ? នៅបណ្ណាល័យគឺឲ្យប្រមូលឯកសារទាំងអស់។ ឯកសារទាំងអស់ហ្នឹងប្រហែលជាប្រាំឡាន ហ្សេ.អឹម.សេ។ ប្រាំឡានហ្សេ.អឹម.សេហ្នឹង គឺស្រាវជ្រាវរាជការតែម្តង រាជការរបស់សាធារណរដ្ឋ លន់ នល់ តែម្តង។ ដូច្នេះការចាប់នេះ គឺក្នុងអំឡុង៧៥ ខ្ញុំឃើញញាក់សាច់តែម្តង គឺខ្ញុំឃើញច្បាស់ណាស់។ ពេលឯកសារ ពេលយកនៅបណ្ណាគារ បណ្ណល័យមកនៅឃើញឯក-សារទាំងអស់។ ដូច្នេះចុចឈ្មោះ ចុចឈ្មោះយកៗបណ្តោយ។ ដូច្នេះនៅក្នុងពេទ្យឆ្លួតតាខ្មៅហ្នឹង ខ្ញុំចាំដូចថា មិនភ្លេច ដូច សុង សាក់ ក៏សម្លាប់ចោលនៅហ្នឹងដែរបាទ។ ស័ក្តិ៥ ស័ក្តិ៤ ស័ក្តិ៣ រាជការរបស់រាជរដ្ឋាភិបាល លន់ នល់ គឺសម្លាប់ចោលនៅហ្នឹងទាំងអស់ ហ្នឹងមួយ។

ពីរទៀត អាចដល់ទាក់ទងនឹងពូជពង្សព្រះមហាក្សត្រទៀត ដូចថា ព្រះអង្គតែងមានបន្ទូលថាបាត់បង់ព្រះមហាក្សត្រនៅនោះឯង។ លោកចៅក្រម ប៉ុន្តែបើសិនណា យើងពិបាករកឆ្អឹង ព្រោះបើដូចឆ្អឹងអាមេរិកាំង គេចេះយកកោសល្យវិច័យឃើញថា អូ៎ឆ្អឹងនេះព្រះមហាក្សត្រ ឆ្អឹងនេះវាស្រ្តទៅ។ នេះវាការពិត ខ្ញុំឃើញច្បាស់ណាស់។ ហើយទូទាំងប្រទេស គឺមកហ្នឹង ចុះឯកសារឡើងប្រាំឡានហ្សេ.អឹម.សេហើយ ស្រាវជ្រាវចាប់បានទាំងអស់។

**ស៖** បើសិនខ្ញុំយល់មិនច្រឡំនោះទេ នៅបណ្ណាល័យនៃមន្ទីរឆ្កួតតាខ្មៅនោះ គេបានប្រមូលឯកសារដែលមានបញ្ជី ដែលនៅក្នុងនោះមានបញ្ជីមន្ត្រីរដ្ឋការ ឬក៏យោធា ដែលក្រោយមកគេចុចឈ្មោះហើយ យោធាទាំងអស់នោះត្រូវបានគេចាប់ខ្លួន។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ?

[១៥:៤៣:១៣]

**ឆ៖** បាទ លោកចៅក្រម រឿងនេះ លោកយល់គឺត្រឹមត្រូវហើយ។ ខ្ញុំឃើញក៏ដូចគ្នា ដូច្នេះការស្រាវជ្រាវរបស់ខ្មែរក្រហមគឺពូកែណាស់ គាត់ពូកែ ចុះបើបញ្ជីស្នាមគឺទាំងអស់តែម្តង ជាការត្រឹមត្រូវណាស់យកពីបណ្ណាល័យ។ និយាយរួមច្រើនណាស់លោកចៅក្រម ប្រាំឡានតិចណាស់ ដឹកប្រាំឡានអង្គុយមើលតែម្តង អ្នកណាធ្វើអី អ្នកណាធ្វើអី។ អ៊ីចឹងឯងបានរាជការរបស់រដ្ឋាភិបាល លន់ នល់ អស់ច្រើន ដោយសារអ៊ីចឹងបាទ។

**ប្រធានអង្គជំនុំ៖**

ឈប់ៗ! ឯកសារបណ្ណាល័យហ្នឹង បណ្ណាល័យនៅណា? នៅភ្នំពេញ នៅផ្សារថ្មី ឬក៏បណ្ណាល័យនៅក្នុងអតីតពេទ្យឆ្កួតនៅខេត្តកណ្តាលហ្នឹងតែម្តង?

**លោក ញ៉ែម អេន៖**

**ឆ៖** លោកចៅក្រម ខ្ញុំចាំអត់ភ្លេចទេ យើងម៉ុយើងប្រៃសណីយ៍ ៗអគារមួយកន្លែងយើងផ្ញើរបស់ទៅក្រៅប្រទេស ក្នុងប្រទេសហ្នឹង ហ្នឹងប្រមូលយកនៅហ្នឹងទាំងអស់ ម៉ុជួរហ្នឹង។ និយាយរួម ប្លុកៗរបស់ក្រសួងទូទាំងប្រទេសហ្នឹង គឺនៅក្នុងអាប្លុកហ្នឹងតែម្តង អ៊ីចឹងដឹកពីហ្នឹងទៅទាំងអស់។ ដឹកហើយទៅស្រាវជ្រាវតែម្តង ប្រាំឡានហេ្ស.អឹម.សេ។ ហើយអ៊ីចឹងទៅ មានគីបៗដូចយើងរាល់ថ្ងៃ គេស្រាវជ្រាវយកតាមហ្នឹង បានចាប់មន្ត្រីរាជការ លន់ នល់ ច្រើន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** តើលោកចាំថា ពេលដែលលោកឃើញរឿងហេតុហ្នឹង<>នៅពេលណា? <តើលោកបានឮអំពីការសម្លាប់ទាំងនោះនៅពេលណា? លុះណាតែលោកបានឃើញការសម្លាប់ទាំងនោះដោយផ្ទាល់ភ្នែក។ តើលោកបានឃើញការសម្លាប់ទាំងនោះ>ទេ? <បើ>លោក<មិនបាន>ឃើញដោយខ្លួន<ឯងទេ តើការ>សម្លាប់<ទាំង>នោះ<កើតឡើងនៅពេលណា>?

[១៥:៤៥:០៥]

**ឆ៖** សុំៗ ម្តងទៀត លោកចៅក្រម។ សុំម្តងទៀត ស្តាប់អត់សូវច្បាស់។

**ស៖** ខ្ញុំចោទសំណួរអម្បាញ់មិញ ពីរបីសំណួរ។ ខ្ញុំសួរលោកថា តើលោកសង្កេតឃើញថា គេប្រមូលឯកសារហ្នឹងដាក់ក្នុងបណ្ណាល័យហ្នឹង ដែលមានបញ្ជីមន្ត្រីរដ្ឋការ ហើយអតីតយោធាហ្នឹងនៅពេលណា លោកសង្កេតឃើញគេធ្វើការហ្នឹង នៅពេលណាដែរ?

**ឆ៖** លោកចៅក្រម ខែ១២ ខែ១២ ឆ្នាំ១៩៧៥ និងខែ១១ហ្នឹងឯង។ ដូចដែលខ្ញុំបានឃើញផ្ទាល់ភ្នែក គឺដូចជាស្រាវជ្រាវខាងពីឡុតយន្តហោះ ស័ក្តិ៥, ស័ក្តិ៤ សម័យសាធារណរដ្ឋ លន់ នល់ គឺដូចជាអត់យូរ លោកចៅក្រម គ្រាន់តែស្រាវជ្រាវទៅ ដូចជាលឿនដែរ បីបួនថ្ងៃ ១០ថ្ងៃ ឃើញមកបណ្តើរៗមក។ យកមក ដូចយកមកវៃចោលតែម្តង។ អត់មានឮទេ ឃើញតែម្តង លោកចៅក្រម នៅគុកតាខ្មៅ គុក មិនមែនហៅគុកទេ ដូចជាពេទ្យដែរ ពេទ្យកន្លែងពេទ្យឆ្កួត។ សម័យហ្នឹងគេយកធ្វើគុក ប៉ុន្តែសញ្ញាហ្នឹង ដាក់សញ្ញាពេទ្យដដែល ប៉ុន្តែតាមពិត ក្នុងហ្នឹងគុក។

**ស៖** តើលោកមានឃើញគេសម្លាប់មនុស្សដោយផ្ទាល់ភ្នែកដែរឬទេ?

**ឆ៖** លោកចៅក្រម ទាក់ទងនឹងបញ្ហាហ្នឹង ដូចជម្រាបត្រឡប់ទៅក្រោយវិញអ៊ីចឹង ការងារភារកិច្ចវារៀងខ្លួន។ ថាការងារគេ គេដឹង ការងារយើង យើងដឹង ក្បាលអ្នកណា សក់អ្នកហ្នឹង។ ដូចខ្ញុំ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ភារកិច្ចនីរសារ ដឹងតែនីរសារ ភារកិច្ចជាងថត ដឹងជាងថត។ ការកាប់សម្លាប់ វាមានផ្នែកពួកបក្សៗរបស់គេ។ ដូច្នេះភារកិច្ចខាងខ្ញុំបាទ គ្រាន់តែមួយថតទេ។

[១៥:៤៧:១៥]

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយពីពេលក្រោយវិញបន្តិច ទាក់ទងទៅនឹងរូបថតសាកសពវិញម្តង។ តើលោកបានផ្តិតរូបថតសាកសពនេះ ដោយខ្លួនឯងដែរឬទេ? លោកបាននិយាយថា ស្រ៊ី អ្នកយករូបថតទាំងអស់ហ្នឹង។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកជាអ្នកផ្តិតរូបថតហ្នឹង ខ្លួនឯងដែរឬទេ?

**ឆ៖** បាទ លោកចៅក្រម ទាក់ទងបញ្ហានេះ ឈ្មោះ ស្រ៊ី ហ្នឹង ខ្ញុំបង្ហាត់គាត់ថតរូបចេះទាំងអស់ធម្មតា កាលហ្នឹងយើងប្រើមិនយូរទេ ខ្ញុំបង្ហាត់តែ៥ថ្ងៃចេះ រៀនថតនេះ។ យើងប្រើម៉ែត្រ ប្រើល្បឿន ប្រើហ្វ្លាស់ ប្រើពន្លឺ។ ដល់អ៊ីចឹងទៅ ពេលគាត់ថតហើយ គាត់យកមកឲ្យខ្ញុំ។ គាត់ថា "អូនអេន ហ្វីលពិសេសហ្នឹង ប្រយ័ត្នប្រយែងផង។ ខ្ញុំថា ហ្វីលពិសេសអីទៅ? ថា អ្នំចាំទៅលាងទៅដឹងហើយ"។ លោកចៅក្រមដឹងថា ពេលលាងនោះ ខ្ញុំលាងខ្លួនឯងទៀត ហើយលាងហ្នឹង លោកចៅក្រម ប្រៀបបានដូចយើងចងបិទភ្នែកអ៊ីចឹង យើងរាវនឹងដៃទាំងអស់ ប្រើងងឹតទាំងអស់។ ដូច្នេះខ្ញុំប្រយ័ត្នណាស់។ ដល់ពេលខ្ញុំលាងហើយ ខ្ញុំដាក់នឹងកំប៉ុងលាងហើយ ដល់ពេលយកមករលាស់មើល សុទ្ធតែហ្វីលសម្លាប់ទាំងអស់។ ខ្ញុំថា អ្អូរឿងនេះជាហ្វីលពិសេសមែន។ ប៉ុន្តែបើខ្ញុំ គាត់ប្រាប់ថា មិនឲ្យនិយាយទៅណាទេ វាដូចជាករណីដូចនិយាយខាងដើម ត្រឡប់ទៅក្រោយអំមិញ គឺថ្នាក់ដឹកនាំធំៗណាស់ គឺដូចថា យុទ្ធជនធម្មតាមិនងាយសម្លាប់ទេ អារ-កទេ។ បើអ៊ីចឹងលោក លោកចៅក្រមឃើញហើយ នៅទួលស្លែង ឃើញមានរូបអារ-កហ្នឹង ហ្នឹងក៏មិនមែនអ្នកតូចទេ អន់បំផុត ក៏ត្រឹមវរសេនាធំដែរបាទ។

**ស៖** តើលោកមានចាំអំពីឥស្សរជនមួយចំនួននៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ហើយដែលមានគេថតរូប? លោកមានចាំឈ្មោះទេ ឥស្សរជនខ្មែរក្រហមមួយចំនួននោះ អ្នកធំមួយចំនួនដែលគេថតរូប ពេលគាត់ស្លាប់ហើយហ្នឹង លោកមាននៅចាំទេ?

[១៥:៤៩:៤៥]

**ឆ៖** ខ្ញុំបាទសូមជម្រាបលោកចៅក្រម ទាក់ទងនឹង អ៊ំហ៊ូ នឹម ទាក់ទងនឹងថ្នាក់ដឹកនាំធំៗមួយចំនួនដែលធំហ្នឹងគឺ ៨០ភាគរយ ខ្ញុំបាទអត់បានថតទេ ដូចជា តាឃួន អ៊ី ខ្ញុំអត់បានថតទេ។ ហើយគេមានបន្ទប់ពិសេសគេគឺ តាស្រ៊ី ហ្នឹងអ្នកថតដែរ តាស្រ៊ី ហ្នឹង។ ហើយខ្ញុំនេះ បានតែថតអ្នកទោសធម្មតាល្មមៗទេ ប៉ុន្តែអ្នកធំៗហ្នឹងមានគុកពិសេសគេ។ គុកពិសេសនៅខាង នៅមុខច្រកទ្វាររាល់ថ្ងៃដែលបើកថ្មី

ហ្នឹង បើកថ្មីហ្នឹង មួយប្លុកហ្នឹងទាំងអស់គឺសុទ្ធតែអ្នកគុកទាំងអស់បាទ។ គាត់ដែលចាប់មក ដូចជាៗ អ៊ំ គណៈតំបន់ គណៈស្រុក ឬក៏ជាពិសេសដែលខ្ញុំឃើញមកដូចជា អ៊ំហ៊ូ នឹម អឺមក ប៉ុន្តែខ្ញុំអត់បានទៅជិតគាត់បាន តាឃួន – កុយ ឃួន នេះ អត់បានថតទៅជិតបានទេបាទ ពីព្រោះគេមានកងពិសេសគេៗតឹងតែងណាស់ មានអាគុកពិសេសគេ ដូចខ្ញុំប្រាប់អ៊ីចឹងបាទ។

**ស៖** អ៊ីចឹងលោកចាំថាធ្លាប់ឃើញរូបសាកសពរបស់ ហ៊ូ នឹម អ៊ីចឹងមែនទេ? លោកគ្រាន់តែឆ្លើយថា បើចាំថាធ្លាប់បានឃើញ ប្រាប់ថាធ្លាប់បានឃើញមកបានហើយ បើអត់ក៏អត់អីដែរ។

**ឆ៖** សពទាំងអស់ហ្នឹងខ្ញុំប្រាប់លោកចៅក្រម អត់ដែលបានឃើញទេ ប៉ុន្តែត្រឹមតែមួយឃើញគាត់មកជាប់ បាទត្រឹមតែឃើញមកគាត់ជាប់គុកត្រឹមហ្នឹង។ ហើយប៉ុន្តែការសម្លាប់ ខ្ញុំនឹង -- អ្នកដឹកនាំទាំងអស់ ដូចជាអត់ឃើញ មិនដឹងយកទៅសម្លាប់ឯណា។ ហើយរូបពិសេសជាច្រើន គឺម្នាក់គត់ដែលឈ្មោះ ស្រ៊ី ហ្នឹង គាត់វរសេនាតូចដែរនៅក្នុងគុកទួលស្លែងហ្នឹង។ ប៉ុន្តែខ្ញុំសូមបញ្ជាក់លោកចៅក្រមបន្តិចថែមបន្តិច ស្រ៊ី ហ្នឹងទីចុងបញ្ចប់គេសម្លាប់គាត់ដែរ ខ្ញុំអត់យល់ពីរឿងការសម្លាប់ហ្នឹង ពាលស៊ីពាលហ្នឹង ប្រហែលជាអាចដឹងរឿងច្រើនពេក បានជា តាឌុច ធ្វើការដែរអាហ្នឹង។

[១៥:៥១:៥០]

**ស៖** ដើម្បីឲ្យច្បាស់ទាំងអស់គ្នា តើលោកធ្លាប់ឃើញរូបថតសាកសពរបស់ ហ៊ូ នឹម ដែរឬទេ?

**ឆ៖** លោកចៅក្រម ខ្ញុំអត់ដែលបានឃើញសពលោក ហ៊ូ នឹម សោះ ឯកឧត្តម ហ៊ូ នឹម។

**ប្រធានអង្គជំនុំ៖**

សួរត្រឹមតែកម្រិតរូបថតសាកសពទេ រូបថតដែលថតពេលគាត់ស្លាប់ហ្នឹង ដែលមានៗរូបថតនោះណា ក្នុងនាមជាអ្នក ថាជាអ្នកសំខាន់ ជាអ្នកជាន់ខ្ពស់។ សួរថាតើលោកដែលឃើញរូបថតដែរទេ មិនមែនសួរថាឃើញសាកសពទេ? ច្បាស់លាស់គឺសំណួរ ៗនេះច្បាស់លាស់ណាស់ គឺឃើញរូបថតដែលជារូបថតសាកសពរបស់ ហ៊ូ នឹម។

**លោក ញ៉ែម អេន៖**

**ឆ៖** ខ្ញុំបញ្ជាក់ចុងក្រោយឲ្យច្បាស់ដែរ ពេលដែលៗលោក ស្រ៊ី ហ្នឹងទៅថតសម្លាប់ហ្នឹង ជួនកាលអ៊ំៗហ្នឹងគាត់ស្គម បាទគាត់ស្គម ដល់អ៊ីចឹងទៅខ្ញុំមើលមិនចាំមិនច្បាស់ ប៉ុន្តែៗជាអាចហើយ អាចរូបថតទាំងអស់ហ្នឹង ប៉ុន្តែដល់ពេលគាត់ធម្មតាគាត់ជាប់គុកទៅ មួយខែ ពីរខែ បីខែទៅគាត់ស្គម ជួនកាលគាត់អត់ទទួល ជួនកាលដូចជាខ្ញុំដឹង កុយ ឃួន អីគាត់អត់ហូបបាយទេ គាត់អត់ហូបបាយតែ

ម្តង គាត់សុខចិត្តស្លាប់។ ដល់អ៊ីចឹងទៅខ្ញុំនឹកឃើញថា រូបថតដែលពេលថតហ្នឹង ៩០ភាគរយគឺស្គម លោកចៅក្រមឃើញហើយក្នុងហ្នឹង គឺដូចខ្ញុំថាអ៊ីចឹង អ្នកដែលអារ-កថតហ្នឹង គឺអត់មានអ្នកតូចទេ តូចបំផុតក៏ត្រឹមវរសេនាធំដែរបាទ លោកចៅក្រម។

[១៥:៥៣:១៨]

**ប្រធានអង្គជំនុំ៖**

សំណួរសួរថាលោកដែលឃើញដែរអត់? តែប៉ុណ្ណឹងទេ ច្បាស់លាស់ណ៎ា កាលណាវាឃើញ លោកចំណាំមិនបាន វាស្មើនឹងមិនឃើញ អានេះវាច្បាស់លាស់។ ដែលឃើញទេ?

**លោក ញ៉ែម អេន៖**

**ឆ៖** បាទ លោកប្រធាន ឃើញតែហ្វីលហ្នឹង ឃើញតែហ្វីលរូបថតហ្នឹងដែលយកមកឱ្យផ្តិតហ្នឹង ឃើញតែហ្វីល ប៉ុន្តែសាកសពដោយផ្ទាល់ខ្ញុំមិនបានឃើញ ៗតែហ្វីលយកមកផ្តិតរូបថតតែម្តង។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** តើលោកមានបានផ្តិតរូបថតសាកសពរបស់ ហ៊ូ នឹម និង កុយ ធួន ដែរឬទេ?

**ឆ៖** បាទ លោកចៅក្រម ដូចខ្ញុំមានប្រសាសន៍ខាងដើមអ៊ីចឹង ខ្ញុំបានផ្តិតក៏ប៉ុន្តែខ្ញុំចម្លែកមួយ បាទចម្លែកមួយថាអ៊ីចេះថា ពេលដែលផ្តិតរូបថតទាំងអស់ហើយ សួរថារូបថតហ្នឹងយកទៅណា? រូបថតហ្នឹងយកឱ្យ តាឌុច វាចម្លែកអ៊ីចឹង វាចម្លែកអ៊ីចឹង។ ហើយឱ្យផ្តិតពីរ១សន្លឹកទៀត។

**ប្រធានអង្គជំនុំ៖**

លោកឆ្លើយឱ្យចំសំណួរ ស្តាប់សំណួរបានទេនុ៎ង? ឆ្លើយនេះអត់មានត្រូវសំណួរសោះ។ យើងរំឭកច្រើនលើកហើយណ៎ា។ យើងប្រាប់អំពីកាតព្វកិច្ចរបស់សាក្សីតាំងពីព្រឹក អ៊ីចឹងឆ្លើយឱ្យចំនឹងសំណួរ ឱ្យត្រូវនឹងសំណួរ កុំឱ្យលៀនចេញផុតពីសំណួរអី។ លោកឆ្លើយអត់ទាន់ចំសំណួរផងហ្នឹង។ លោកដែលឃើញ ជួបប្រទះនូវហ្វីលរូបថតដែលលោកលាងនុ៎ង គឺបង្ហាញអំពីការថតរូបចំពោះលោក ហ៊ូ នឹម ហើយនិង កុយ ធួន ដែរឬទេ? នេះជាសំណួរជាក់លាក់ តែពីរនាក់ទេ កុយ ធួន ហើយនិង ហ៊ូ នឹម លោកដែលឃើញទេ? បើលោក ព្រោះពីមុនថា សួរពីរូបថត លោកថាអត់បាន លោកឆ្លើយពីហ្វីល ឥឡូវគេសួរពីហ្វីល។ អាហ្វីលដែលលោកថាលាងហ្នឹង តើលោកដែលបានឃើញដែរឬទេ? ពាក្យថា "ឃើញ" គឺឃើញច្បាស់ ហើយយកមកពិនិត្យគឺថាប្រាកដប្រជាថា ហ្វីលហ្នឹងគឺថត លោក សពហ៊ូ នឹម ឬក៏សព កុយ ធួន ដែរ មិនមែនប្រហែលទេ។ ប្រហែល អត់មានប្រើប្រាស់បានទេ នៅតុលាការនោះ។

[១៥:៥៥:៤៤]

**លោក ញ៉ែម អេន៖**

**ឆ៖** ខ្ញុំបាទសូមជម្រាបម្ដងទៀត អានេះនិយាយដូចថានិយាយបកទៅក្រោយទៀត។ ហ្វីលហ្នឹងខ្ញុំលាង ក៏ប៉ុន្តែពេលផ្ដិតឃើញហើយ រូបភាពហ្នឹងវាប្លែកពីនៅរស់ ហើយវាទៅជាស្គមស្គាំង ស្ដេកស្ដាំងអីចឹងទៅ គឺខ្ញុំក៏មិនបានចាប់អារម្មណ៍ដែរ។ អាហ្នឹង វាដូច ខ្ញុំមិនដឹងថាឆ្លើយថាម៉េចទៀត។ ប៉ុន្តែហ្វីលលាងជាច្រើនហ្នឹង សាកសពស្លាប់ហ្នឹងប្រហែលជាជាប់១០០នាក់ដែរហ្នឹង។

**ប្រធានអង្គជំនុំ៖**

នេះវា យើងអាចឃើញហ្វីល ប៉ុន្តែលោកមិនបានចំណាំទេ។ លោកមិនអាចចំណាំ ឬក៏ចំណាំមិនបានទេ? នេះវាច្បាស់លាស់ណា។

**ឆ៖** *(មិនក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** បាទ សូមលោកឆ្លើយម្ដងទៀត ព្រោះខ្ញុំអត់បានទទួលការបកប្រែមកជាភាសាបារាំង អ្វីដែលលោកប្រធានបានសួរអម្បាញ់មិញនេះ។ តើលោកមានស្គាល់ទេ ពេលមើលហ្វីលហ្នឹង ពេលលោកលាងហ្វីលហ្នឹង ថាស្គាល់ថារូបហ្នឹងជារូប កុយ ធួន ឬក៏ ហ៊ូ នឹម ហ្នឹងដែរឬទេ? ឬក៏ថា <លោកឃើញរូបថតមនុស្ស ដែល>ស្គមស្គាំងខ្លាំង <ប៉ុន្តែ>លោក<>មិនស្គាល់<ថាអ្នកទាំងនោះជានរណា>ទេ?

**លោក ញ៉ែម អេន៖**

**ឆ៖** ជាការត្រឹមត្រូវ លោកចៅក្រម។

[១៥:៥៧:៣៥]

**ស៖** មានជម្រើសពីរ ជួនគឺថាលោកឃើញហ្វីលរូបថតរបស់អ្នកដែលលោកធ្លាប់ស្គាល់ ថាជា កុយ ធួន ឬក៏ ហ៊ូ នឹម ឬជួនវាជារូបថតដែលជាហ្វីលរូបថតដែលវាមិនច្បាស់ ហើយរូបមនុស្សនោះស្គមពេក លោកមិនស្គាល់ទេ មើលមិនស្គាល់ទេ។ អីចឹងមានពីរ សំណួរខ្ញុំមានពីរថា មើលហ្វីលហ្នឹងឃើញថា ជាហ្វីលរូបថតរបស់ កុយ ធួន ហើយនិង ហ៊ូ នឹម ឬក៏អត់? ឬក៏លោកបានឃើញហ្វីលហើយមានឃើញរូបថតដែរ តែមិនដឹងរូបអ្នកណាទេ?

**ឆ៖** លោកចៅក្រម ហ្នឹងនិយាយឲ្យខ្លីគឺមិនស្គាល់តែម្ដង នៅពេលសម្លាប់ទៅវា និយាយឲ្យចំមិនស្គាល់តែម្ដង ព្រោះវាគ្រាន់ថា រូបភាពទាំងអស់ដែលថតហ្នឹងវាសំខាន់។ ខ្ញុំនិយាយអីចឹងបាទ ព្រោះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សពដែលស្លាប់ទៅហើយ វាប្រែពណ៌ច្រើន ហើយស្គមទៀត។

**ស៖** <បើសិនជា>លោកមិនស្គាល់រូបនុ៎ង <តើនៅពេលក្រោយមកមាននរណាប្រាប់>លោក <>ថា<រូបនោះជា>រូប<> ហ៊ូ នឹម ហើយ កុយ ធួន <ទេ? បើមានគេប្រាប់ តើនរណាជា>អ្នក<> ប្រាប់លោក <ឬវាគ្រាន់តែជាការសន្និដ្ឋានរបស់លោកទេ>?

**ឆ៖** ខ្ញុំដឹងថា អ្នកដែលសម្លាប់អារ-កហ្នឹងគឺយកពីគុកពិសេសទាំងអស់ យកពិសេសទាំងអស់ ដែលខ្ញុំផ្តិតហ្នឹង។ ប៉ុន្តែដូចខ្ញុំថា ខាងដើមហ្នឹង ខ្ញុំមើលមិនស្គាល់ គ្រាន់វាស្លាប់ទៅហើយ។ ស្លាប់ទៅហើយ គេអារ-កឡើងរយះអស់ទៅហើយ ងើយក្បាលទៅហើយ។ គ្រាន់តែគេថតថា គេជួនកាលគេថត យកត្រឹមបំពង់ក ខ្ញុំសុំទោសថា វាដូចជាមិនស្គាល់មិនច្បាស់ក៏បានដែរវា ប៉ុន្តែខ្ញុំអ្នកផ្តិត គឺឃើញអារ-ក ប្រហែលជា១០០នាក់នៅទួលស្លែងហ្នឹង។

[១៥:៥៩:៥៩]

**ស៖** បាទ សំណួរចុងក្រោយ។ លោកបាននិយាយថា បើខ្ញុំយល់មិនច្រឡំទេ លោកនិយាយថា ប៉ុល ពត ឬក៏អ្នកផ្សេងទៀត ចង់បានរូបថតទាំងអស់នេះ ដើម្បីឲ្យច្បាស់ក្នុងចិត្តថា អ្នកទាំងអស់នេះត្រូវបានគេសម្លាប់ហើយ ឬស្លាប់ហើយ។ ហើយអានេះជាអ្វីដែលលោកនិយាយ ហើយបើលោកនិយាយ អ៊ីចឹងថាប្រភពព័ត៌មានហ្នឹងចេញមកពីណា? គេប្រាប់លោក ឬក៏លោកខ្លួនឯងហ្នឹង យករូបថតហ្នឹងទាំងអស់ហ្នឹងទៅឲ្យ ប៉ុល ពត ហើយនិងទៅអ្នកផ្សេងទៀត?

**ឆ៖** បាទ លោកចៅក្រម។ រូបភាពវាចម្លែកថា មួយរូបមួយសន្លឹកឲ្យផ្តិតពីរ។ ទុកមួយ បញ្ជូនទៅឲ្យ តានឿន និងតាប៉ង់ ហ្នឹងមួយ។ ហ្នឹងអ៊ីចឹងថា បើបញ្ជូនដល់ តាប៉ង់ និង តានឿន ខ្ញុំគិតថាវានឹងទៅដល់អ៊ំ សុន សេន និងអ៊ំ ប៉ុល ពត ហើយ។ នេះវាព្រោះវាចង្កោមខ្សែតែមួយ ព្រោះ តានឿន ហ្នឹងក៏អ្នកពិសេស, តាប៉ង់ ក៏អ្នកពិសេស។ ហើយរូបថតចម្លែកផ្តិតពីរសន្លឹក បាទពីរសន្លឹក ទុកមួយនៅកន្លែងខ្ញុំ ទុកមួយយកទៅឲ្យ តាឌុច។ អានេះជាការពិត ដែលខ្ញុំផ្តិតខ្លួនឯង ដែលលោក ស្រ៊ី យកមកឲ្យបាទ។

**ស៖** ហេតុអ្វីបានជាលោកដឹងថា គេបញ្ជូនរូបថតទាំងអស់នេះទៅ សុន សេន? តើលោកខ្លួនឯងហ្នឹងជាអ្នកយករូបថតហ្នឹងទៅឲ្យ <សុន សេន> ឬក៏<>លោកដឹងថាអ្នកណាជាអ្នកយកទៅ<ឲ្យ សុន សេន ឬក៏មានគេប្រាប់លោក>? តើលោកអាចរៀបរាប់បានទេ ថាដំណើរការហ្នឹងយ៉ាងម៉េចដែរនៅពេលនោះ?

[១៦:០១:៥៣]

**ឆ៖** បាទ លោកចៅក្រម ផ្ទះតាឌុច មានពីរ។ ផ្ទះតាឌុច អាខាងមុខហ្នឹងនៅបែបជា ខ្ញុំចាំមិនបានប្រហែលអាចស្ពានទូតហុងគ្រី នៅទល់មុខក្រសួងផែនការ ហ្នឹងផ្ទះមួយ។ អាមានប្លុក ហើយមានបន្ទប់យាមមួយហ្នឹង ហើយផ្ទះខាងក្រោយមួយទៀតពីរ។ អាគាត់វៃជញ្ជាំង គាត់វៃជញ្ជាំងទៅបាន១ផ្ទះពីរ។ ដល់ពីរនេះ ឡានតានឿន និងតាប៉ង់ មកគាត់ជិះឡានហ្ស៊ីបមកដល់ ឈប់មុខផ្ទះហ្នឹងឯង។ ឈប់មុខផ្ទះ ពេលដែលខ្ញុំយកឲ្យ តាឌុច, តាឌុច កាលហ្នឹងគាត់មិនហៅ អ៊ំប៉ុល ពត ទេ ហៅបងទី១ ហៅបង ១ទី១ បងទី២។ អ៊ំនួន ជា, អ៊ំ ប៉ុល ពត ហ្នឹងហៅថាបង គាត់ហៅតែបង១ទេ។ ដល់អ៊ីចឹងទៅ ខ្ញុំឃើញការពិតគឺ តាឌុច មិនយកទៅណា។ មិនយកទៅណា ព្រោះ តាប៉ង់ និងតានឿន ទទួលពីខ្ញុំដៃផ្ទាល់ពីខ្ញុំទៅតែម្តងមុខ តាឌុច ហ្នឹងឯង។

**ស៖** ដើម្បីយល់ឲ្យច្បាស់ហ្នឹង គឺថាមាននីរសារដែលមកជួបលោក ដើម្បីសុំរូបថតទាំងអស់ហ្នឹងពីលោក ហើយបន្ទាប់មក គាត់យករូបថតទាំងអស់ហ្នឹងទៅឲ្យអ្នកផ្សេងទៀត។ តើអ៊ីចឹងមែនទេ? ហើយបើក្នុងករណីហ្នឹង តើគេមានប្រាប់លោកទេថា គេយករូបថតហ្នឹងទៅឲ្យអ្នកណា?

**ឆ៖** លោកចៅក្រម ផ្ទះខ្ញុំនិងផ្ទះ តាឌុច ហ្នឹងអត់ឆ្ងាយពីគ្នាប៉ុន្មានទេបាទ មួយកែងទេបាទ មួយកែងប្រហែលជា១០០ម៉ែត្រទេ។ ពីផ្ទះខ្ញុំទៅផ្ទះ តាឌុច វាមួយកែង ថាតែ២០០ម៉ែត្រចុះ។ អ៊ីចឹងបានថាឯកសារហ្នឹង គឺដូចខ្ញុំនិយាយបកទៅវិញ ព្រោះ តានឿន នេះវាជាមនុស្សសំខាន់របស់ អ៊ំប៉ុល ពត និង ឯកឧត្តម សុន សេន, តាប៉ង់ ក៏ជាមនុស្សសំខាន់របស់ឯកឧត្តម សុន សេន, ប៉ុល ពត ដែរ។ អ៊ីចឹងខ្ញុំដឹងថាម៉េចទៀត បើអ្នកទាំងពីរហ្នឹងទទួលពីខ្ញុំទៅហ្នឹង មិនដឹងគាត់យកឲ្យពីណា បើមិនឲ្យ អ៊ំប៉ុល ពត, ឯកឧត្តម សុន សេន តែប៉ុណ្ណឹងឯង។ ដឹងជាម៉េចទៀត វាព្រោះអ្នកទទួលពីខ្ញុំ គឺអ្នកពិសេសៗដែរ។

[១៦:០៣:៥២]

**ប្រធានអង្គជំនុំ៖**

យើងប្រាប់លោកហើយថា កុំឲ្យលោកឆ្លើយនូវអ្វីដែលជាការសន្និដ្ឋានផ្ទាល់ខ្លួនរបស់លោក។ អ្វីដែលលោកដឹងត្រឹមណា ឆ្លើយត្រឹមហ្នឹងបានហើយ។ រឿងបន្តទៅទៀត បើលោកមិនដឹងទេ កុំស្មាន។ កាលណាលោកធ្វើសន្និដ្ឋាន វាស្មើនឹងឆ្លើយស្មាន ចម្លើយស្មានហ្នឹងវាខាតពេលឥតប្រយោជន៍ ព្រោះអង្គជំនុំជម្រះមិនយកការឆ្លើយបែបស្មាន យកមកធ្វើភ័ស្តុតាងក្នុងការទៅបង្ហាញការពិតក្នុងរឿងក្តីតាមផ្លូវតុលាការទេ។ យើងបានរំឭកច្រើនហើយ។ សូមលោកគិតពីបញ្ហានេះឲ្យបានត្រឹមត្រូវ។

បាទ ឥឡូវពេលវេលាសវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ ហើយអង្គជំនុំជម្រះ

ប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី២១ ខែមេសា ឆ្នាំ២០១៦ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ញ៉ែម អេន បញ្ចប់ ហើយនិងចាប់ផ្ដើមសក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-865 ហើយទំនងជាអាចមានសាក្សីបម្រុង2-TCW-898 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក ញ៉ែម អេន សវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅថ្ងៃនេះ នៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃស្អែកទៀត។

ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សី និងសាក្សីបម្រុងថ្ងៃនេះ វិលត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅវិញ និងឲ្យគាត់ អញ្ជើញគាត់ ពួកគាត់មកកាន់កន្លែង -- មកចូលរួមផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការវិញនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៦ នាទី)*